ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា

# កម្មវិធីសាលាកុមារមេត្រី

## សមាសភាគទី ២ : ប្រសិទ្ធភាពនៃការបង្រៀន និង រៀន

# គោលវិធីសិស្សមជ្ឈមណ្ឌល



## ឯកសារគាំទ្រការអនុវត្ត

### សៀវភៅផ្នែកសម្របសម្រួល

# អារម្ភកថា

សៀវភៅប្រសិទ្ធភាពនៃការបង្រៀន និង រៀន ( ETL ) ត្រូវបានរៀបរៀងក្នុងក្របខណ្ឌសមាសភាគទី ២ នៃកម្មវិធី សាលាកុមារមេត្រី ជា ២ សៀវភៅ : សៀវភៅអ្នកសម្របសម្រួល និង សៀវភៅកំណត់ត្រាគ្រូ ។

ទំរង់នៃសំណេរមាន ២ គឺ :

-ទំរង់ជាការបំប៉ន

-ទំរង់ជាលំហាត់កិច្ចការដោយផ្អែកលើសកម្មភាពដែលបានបង្រៀនកន្លងមក ។

ខ្លឹមសារនៃសៀវភៅបានពណ៌នាចំនួន ៨ មេរៀនសំខាន់ៗ ដែលនឹងអាចពង្រីកសមត្ថភាពក៏ដូចជាបទពិសោធ ជូនគ្រូឈរថ្នាក់ឱ្យមានការអភិវឌ្ឍមួយកំរិតថែមទៀត ទាំងរបៀបរបបការងារ ទាំងបច្ចេកទេសបង្រៀន ។ ខ្លឹមសារមេរៀនបានផ្តល់នូវ គំនិតផ្តួចផ្តើមជាច្រើនសម្រាប់ការបង្រៀនដូចជា :

-ការបង្កើតល្បែងសិក្សាច្រើនបែបសម្រាប់មុខវិជ្ជាគោលទាំង ៤

-ការច្នៃប្រឌិតប្រើប្រាស់ប័ណ្ណផ្សព្វផ្សាយផ្សេងៗ : ផ្ទាំងរូបភាព ឯកសារ... ដែលបំរើឱ្យសេវាសង្គម ( **អប់រំ សុភាព ពាណិជ្ជកម្ម បរិស្ថាន... ។ល។** ) មកបំរើឱ្យការរៀនរបស់កុមារបានល្អប្រសើរ

-ល្បិចជួយកុមារដើម្បីអភិវឌ្ឍបំណិនអាន សំណេរ និង ការគិត ( បញ្ហា )... ។

សៀវភៅប្រសិទ្ធភាពនៃការបង្រៀន និង រៀន (ETL) មានគោលដៅតែមួយគត់ គឺអភិវឌ្ឍបុគ្គលិកលក្ខណៈ ពេញលេញរបស់កុមារគ្រប់រូប ។

គណៈកម្មការអភិវឌ្ឍកម្មវិធីសាលាកុមារមេត្រី នឹងចងក្រងសកម្មភាពមេរៀនជាលក្ខណៈប្រតិបត្តិបន្តបន្ទាប់ទៀត សម្រាប់ជាជំនួយស្មារតីជូនលោកគ្រូ អ្នកគ្រូជាទីស្រឡាញ់ និង រងចាំទទួលមតិកែលំអពីលោកអ្នកជានិច្ច ។

**អរគុណ !**

# <u>បញ្ជីប្រធានបទ</u>

ទំព័រ


-សេចក្តីផ្តើម គោលបំណង ខ្លឹមសាររួម..........................................................................................១

**ប្រធានបទទី ១ :** ការគ្រប់គ្រងថ្នាក់រៀន ៥ សកម្មភាព....................................................................២-៥

**ប្រធានបទទី ២ :** ការប្រើប្រាស់សំណួរ ៥ សកម្មភាព.....................................................................៦-១៨

**ប្រធានបទទី ៣ :** ការបង្កើតល្បែងសិក្សា ៦ សកម្មភាព...........................................................១៩-២៦

**ប្រធានបទទី ៤ :** ការប្រើប្រាស់ធនធានក្នុងថ្នាក់រៀនសំបូរបែប ៥ សកម្មភាព...............................២៧-៣១

**ប្រធានបទទី ៥ :** ការអភិវឌ្ឍអំណាន ៤ សកម្មភាព...................................................................៣២-៣៧

**ប្រធានបទទី ៦ :** ការអភិវឌ្ឍសំណេរ ៣ សកម្មភាព...................................................................៣៨-៤៣

**ប្រធានបទទី ៧ :** វាយតម្លៃ/កម្រងស្នាដៃសិស្ស ៤ សកម្មភាព.....................................................៤៤-៤៦

**ប្រធានបទទី ៨ :** ការឆ្លុះបញ្ចាំងគ្រូ ( ស្វ័យវាយតម្លៃ ) ៤ សកម្មភាព...........................................៤៧-៥១

**ឧបសម្ព័ន្ធ**

# ប្រសិទ្ធភាពនៃការបង្រៀន និងរៀន

## I.សេចក្តីផ្តើម

សាលាកុមារមេត្រី គឺជាក្របខណ្ឌទូលំទូលាយមួយដែលមានគ្រប់ផ្នែកនៃការងារទាំងអស់របស់សាលារៀន រួមមាន ការគ្រប់គ្រងសាលារៀន សុខភាព និងសុវត្ថិភាព យេនឌ័រ ទំនាក់ទំនងសាលារៀន និងសហគមន៍ និង ការគាំទ្ររបស់ប្រព័ន្ធអប់រំ ។ សកម្មភាពប្រសិទ្ធភាពនៃការបង្រៀន និងរៀន សមាសភាគទី២ នៃកម្មវិធីសាលាកុមារមេត្រី ត្រូវបានចងក្រងជា ២ ឯកសារដាច់ដោយឡែកពីគ្នា :

១.ឯកសារសម្រាប់គ្រូឧទ្ទេសធ្វើការបំប៉ន "**សៀវភៅអ្នកសម្របសម្រួល**"

២.ឯកសារសម្រាប់គ្រូឈរថ្នាក់ ហៅថា "**សៀវភៅកំណត់ត្រាគ្រូ**"

សៀវភៅអ្នកសម្រសសម្រួល គឺជាសៀវភៅណែនាំមានសារប្រយោជន៍ ចំពោះបុគ្គលិកអប់រំ ដែលត្រូវធ្វើសិក្ខាសាលាបំប៉នដល់គ្រូ សម្រាប់ប្រសិទ្ធភាពនៃការបង្រៀន និងរៀននេះ ។ សៀវភៅនេះអធិប្បាយយ៉ាងពិស្តារអំពីផែនការសកម្មភាពបំប៉នគ្រូនៅក្នុង សិក្ខាសាលាប្រាំមួយថ្ងៃដំបូងនៅខែកញ្ញា និងសិក្ខាសាលាពិនិត្យតាមដានចំនួន ១ ថ្ងៃនៅខែមេសា និង ១ថ្ងៃនៅ ខែកក្កដា ។ សៀវភៅនេះក៏សង្ខេបអំពីអ្វីដែលអ្នកសម្របសម្រួលមូលដ្ឋានត្រូវជួយគ្រូឱ្យរៀបចំ សម្រាប់ការប្រជុំប្រចាំខែក្នុងឆ្នាំសិក្សាផងដែរ ។ គ្រូឧទ្ទេសត្រូវយល់ឱ្យច្បាស់ផងដែរអំពីខ្លឹមសាររបស់សៀវភៅកំណត់ត្រាគ្រូ ។

## II.គោលបំណង

ដើម្បីឱ្យលោកគ្រូ អ្នកគ្រូកែលំអគុណភាពនៃការរៀនសូត្ររបស់សិស្ស ដោយការអនុវត្តវិធីបង្រៀន និងរៀនតាមបែបកុមារមេត្រី ។

## III.ខ្លឹមសារ

ប្រសិទ្ធភាពនៃការបង្រៀន និងរៀន រួមមាន :

១.ការគ្រប់គ្រងថ្នាក់រៀន : ១.១ ដល់ ១.៥

២.ការប្រើប្រាស់សំណួរ : ២.១ ដល់ ២.៥

៣.ការបង្កើតល្បែងសិក្សា : ៣.១ ដល់ ៣.៦

៤.ការប្រើប្រាស់ធនធានក្នុងថ្នាក់រៀនសំបូរបែប : ៤.១ ដល់ ៤.៥

៥.ការអភិវឌ្ឍអំណាន : ៥.១ ដល់ ៥.៤

៦.ការអភិវឌ្ឍសំណេរ : ៦.១ ដល់ ៦.៣

៧.រង្វាយតម្លៃ និងកម្រងស្នាដៃសិស្ស : ៧.១ ដល់ ៧.៣

៨.ការឆ្លុះបញ្ចាំង (ស្វ័យវាយតម្លៃ) : ៨.១ ដល់ ៨.៤

✦ ឯកសារឧបសម្ព័ន្ធ

## IV.សកម្មភាពអនុវត្ត

# ប្រធានបទទី១ : ការគ្រប់គ្រងថ្នាក់រៀន

## សកម្មភាព 1.1 កុមារនីមួយៗមានភាពខុសគ្នា 45 នាទី

**សម្ភារ** : ប័ណ្ណ VIPP ផ្ទាំងក្រដាសធំ ប៊ិកហ្វឺត ស្កុត ។

អ្នកសម្របសម្រួល ឱ្យអ្នកចូលរួមគិតពិចារណាអំពីអ្វីដែលធ្វើឱ្យកុមារមានភាពខុសគ្នា ។ ឧទាហរណ៍: តើអ្វីដែលធ្វើឱ្យកុមារនៃគ្រួសារអាជីវកម្មខុសពីកុមារជាកូនកសិករ ឬ កូនអ្នកព្រៃភ្នំ ជនបទដាច់ស្រយាល? តើអ្វីដែលធ្វើឱ្យកុមារកម្ពុជាខុសពីកុមារនៅអាហ្វ្រិក នៅអូស្ត្រាលី ឬ នៅអាមេរិក ? (អ្នកសម្របសម្រួលមិនរំពឹងថាបានចម្លើយគ្រប់គ្រាន់ពីសំណួរនេះទេ ប៉ុន្តែគាត់អាចទទួលចម្លើយបានយ៉ាងហោចណាស់ចំនួន ២ ឬ ៣ ដែលបញ្ជាក់ថាសិក្ខាកាមយល់បានច្បាស់លាស់ហើយ) ។

បន្ទាប់មកអ្នកសម្របសម្រួលឱ្យអ្នកចូលរួមធ្វើការងារជាក្រុមតូចៗដោយប្រើប័ណ្ណ VIPP សម្រាប់សរសេរចម្លើយសំណួរខាង ក្រោម:

**សំណួរផ្តោត** : ***តើកត្តាអ្វីខ្លះដែលធ្វើឱ្យកុមារមានភាពខុសគ្នា?*** (ប័ណ្ណ VIPP)

**ចម្លើយរំពឹងទុក** : អាចរួមបញ្ចូលនូវ : វប្បធម៌ តំណមរតក បរិស្ថាន ស្ថានភាពសង្គម-សេដ្ឋកិច្ច គ្រួសារ សុខភាព ចំណីអាហារ យ៉េនឌ័រ ជាតិសាសន៍ ... ។

ក្រុមនីមួយៗបិទប័ណ្ណរបស់ខ្លួននៅលើក្តារខៀន ឬ នៅលើផ្ទាំងក្រដាសធំមួយ ។ បន្ទាប់មកពួកគាត់ធ្វើចំណាត់ថ្នាក់ជាក្រុមដោយខ្លួនឯង រួចសរសេរឈ្មោះ សម្រាប់ក្រុមនីមួយៗនៅលើប័ណ្ណដែលមានពណ៌ខុសៗគ្នា ។

ជាបញ្ចប់អ្នកសម្របសម្រួលពិនិត្យឡើងវិញនូវឈ្មោះក្រុមផ្សេងៗដែលអ្នកចូលរួមបានជ្រើសរើស ។ ជម្រើសទាំងនោះមាន : សុខភាព គ្រួសារ ជីវសាស្រ្ត ស្ថានភាពសេដ្ឋកិច្ច វប្បធម៌ សាសនា ភាសា ជាតិសាសន៍ ទីកន្លែង ដែលគេរស់នៅ សុខភាព (ពិការភាព) បុគ្គលិកលក្ខណៈ និងសមត្ថភាព ... ។

ក្រុមភាគច្រើននឹងជ្រើសរើសឈ្មោះក្រុមផ្សេងៗគ្នា និងវិធីធ្វើចំណែកថ្នាក់ខុសៗគ្នា ប៉ុន្តែត្រូវសមហេតុផល និងអាចទទួលយកបាន ។ អ្នកចូលរួមគួរតែទទួលស្គាល់ថា ពុំមានចម្លើយ "ត្រូវ" ទោលឡើយ និងថាគំនិតខុសៗគ្នា និងវិធីឆ្លើយនានាអាចទទួលយកបានទាំងអស់ ។

★ **VIPP :** មើលការណែនាំក្នុងឧបសម្ព័ន្ធ ។

| **សកម្មភាព 1.2** | **ការទទួលស្គាល់ភាពខុសគ្នា** | **30 នាទី** |
|---|---|---|

**សម្ភារ :** រូបកុមារនៅក្នុងថ្នាក់ និងស្រូវនៅក្នុងស្រែមួយ ។

អ្នកសម្របសម្រួលនិយាយៈ ឥឡូវនេះខ្ញុំចង់ឱ្យអ្នកគិតអំពី លទ្ធផលនៃសកម្មភាពចុងក្រោយថាតើវាមានន័យអ្វីខ្លះចំពោះយើងក្នុងនាមជាគ្រូបង្រៀន ។

ដើម្បីជួយអ្នកចូលរួមឱ្យគិតអំពីសំណួរនេះ អ្នកសម្របសម្រួលត្រូវប្រើដ្យាក្រាមអំពីកសិករ និងស្រូវនៅក្នុងស្រែ និងរូបគ្រូជាមួយសិស្សនៅក្នុងថ្នាក់រៀន (រូបទាំង២នេះគួរប្រើផ្ទាំងតែមួយ) ។ **អ្នកសម្របសម្រួលសួរៈ** ***តើអ្នកគិតថាវាមានបញ្ហា ឬ ទេ ប្រសិនបើកសិករ យកចិត្តទុកដាក់ចំពោះស្រូវទាំងអស់ដូចៗគ្នា ? តើទង្វើនេះជះឥទ្ធិពលយ៉ាងដូចម្ដេចដល់ផលសម្រេច ? តើគ្រូអាចប្រព្រឹត្ត ចំពោះសិស្សទាំងអស់ដូចៗគ្នាឬទេ ? តើទង្វើនេះមានឥទ្ធិពលយ៉ាងដូចម្ដេចដល់ផលសម្រេច?***



កុមារនៅក្នុងថ្នាក់រៀន



ស្រូវនៅក្នុងស្រែ

សំណួរផ្ដោត សម្រាប់ក្រុមទាំងមូល : ***តើយើងបានព័ត៌មានអ្វីខ្លះអំពីកុមារនៅក្នុងថ្នាក់រៀនយើង ?***

-អ្នកសម្របសម្រួលសរសេរចម្លើយរបស់អ្នកចូលរួមនៅលើក្ដារខៀន/ផ្ទាំងក្រដាសធំ ...

**-ចម្លើយរំពឹងទុក :**

- ✧ពុំមាននរណាម្នាក់ដូចគ្នានឹងអ្នកផ្សេងឡើយ : កុមារទាំងអស់ខុសគ្នា
- ✧កុមារមានបទពិសោធន៍ផ្សេងៗគ្នានៅក្នុងជីវិតពួកគេ
- ✧កុមារក៏ប្រហែលជារៀនសូត្រតាមវិធីផ្សេងៗគ្នាដែរ
- ✧កុមារដែលពុំចេះភាសាខ្មែរជាភាសាយានទីមួយនឹងបាត់បង់អត្ថប្រយោជន៍
- ✧កុមារដែលមកពីគ្រួសារអ្នកមាននឹងទទួលបានអត្ថប្រយោជន៍
- ✧កុមារខ្លះរៀនយ៉ាងលឿន និងយ៉ាងងាយ កុមារខ្លះទៀតពុំដូច្នេះឡើយ
- ✧កុមារខ្លះទទួលការគាំទ្រ និងការលើកទឹកចិត្តពីមាតាបិតា កុមារខ្លះទៀតពុំបានទទួលឡើយ
- ✧កុមារខ្លះបានស្គាល់សៀវភៅ និងអក្សររួចហើយ កុមារខ្លះទៀតមិនទាន់ស្គាល់ឡើយ
- ✧កុមារភាគច្រើនមានបងប្អូនបង្កើត និងធ្វើអ្វីៗជាមួយគ្នា កុមារខ្លះទៀតពុំមានឡើយ
- ✧កុមារខ្លះមានចិត្តចង់ដឹងចង់ឮ និងចង់សាកល្បងរបស់ថ្មីៗជានិច្ច កុមារខ្លះទៀតមិនចង់ឡើយ ។ល។

**អ្នកសម្របសម្រួលសង្ខេបដោយនិយាយថា** សិស្សទាំងអស់មានភាពខុសៗគ្នា ហើយវិធីដែលគេរៀនសូត្រក៏ខុសគ្នាដែរ ។ ដូច្នេះគ្រូត្រូវតែផ្ដល់លទ្ធភាពច្រើនយ៉ាងដែលអាចធ្វើបាន ដើម្បីស្វែងយល់ពីរបៀបរៀនរបស់កុមារទាំងនេះ យើងមិនអាចប្រើប្រាស់វិធី ១ ឬ ២ ដូចគ្នានោះទេ អាចប្រើវិធីផ្សេងៗទៀតក្នុងការជួយសិស្សឱ្យសិក្សា ។

## សកម្មភាព 1.3 វិធីរៀនរបស់កុមារ 45 នាទី

**សម្ភារ** : ប័ណ្ណ VIPP ផ្ទាំងក្រដាសធំ ប៊ិក ហ្វឺត ស្កុត ។

**អ្នកសម្របសម្រួលនិយាយថា** : សូមពិចារណាអំពីសិស្សនៅក្នុងថ្នាក់របស់អ្នក និងរាល់វត្ថុទាំងអស់ដែលពួកគេដឹង ។

**បន្ទាប់មកអ្នកសម្របសម្រួលសួរថា** : *តើសិស្សរៀនគ្រប់អ្វីៗទាំងអស់នៅតែក្នុងសាលារៀនឬ?*

**ចម្លើយរំពឹងទុក:** *មិនមែនទេ ។*

**អ្នកសម្របសម្រួលសួរ:** *តើពួកគេបានរៀនអ្វីផ្សេងៗទៀតនៅឯណា ? តើពួកគេរៀនពីនរណា?*

**ចម្លើយរំពឹងទុក** : *ពួកគេរៀនបានខ្លះនៅសាលារៀន ប៉ុន្តែចំណេះដឹងជាច្រើនផ្សេងទៀត ពួកគេបានរៀននៅខាងក្រៅសាលារៀន ។ ពួកគេរៀនពីគ្រួសាររបស់ខ្លួន ពីបទពិសោធន៍ខ្លួនឯង និងពីកុមារដទៃទៀត ។*

**កិច្ចការរបស់អ្នកចូលរួម**

អ្នកសម្របសម្រួលប្រាប់អ្នកចូលរួមឱ្យធ្វើការងារជាក្រុមតូចៗ ដើម្បីឆ្លើយសំណួរ : *តើកុមារបានរៀនអ្វីៗទាំងនេះយ៉ាងដូចម្តេច?*

អ្នកសម្របម្រួលប្រាប់សិក្ខាកាមឱ្យប្រើប្រាស់លំនាំប័ណ្ណ VIPP ដើម្បីឆ្លើយសំណួរនេះ ។

**អ្នកសម្របសម្រួលពន្យល់ពីលំនាំប័ណ្ណ** VIPP និងរបៀបប្រើ (មើលឧបសម្ព័ន្ធ) ។

អ្នកចូលរួមពិភាក្សាសំណួរជាក្រុមតូចៗ និងរាយចម្លើយរបស់ខ្លួននៅលើប័ណ្ណ VIPP ។ អ្នកសម្របសម្រួលជួយពួកគាត់ឱ្យធ្វើចំណែកថ្នាក់ចម្លើយរបស់ខ្លួនទៅជាក្រុម និងសរសេរចំណងជើងក្រុមនីមួយៗនៅលើប័ណ្ណដែលមានពណ៌ខុសគ្នា ។ ក្រុមនីមួយៗដាក់តាំងគំនិតរបស់ខ្លួន ។ អ្នកសម្របសម្រួលចងក្រងគំនិតដាក់តាំងរបស់ក្រុមទាំងមូល ។

**សន្និដ្ឋាន :** អ្នកសម្របសម្រួលបញ្ជាក់ថា ការរៀនសូត្រប្រកបដោយប្រសិទ្ធភាព ភាគច្រើនអាចកើតឡើងដោយពុំចាំបាច់បង្រៀនក្នុងប្រព័ន្ធដោយប្រើសៀវភៅអាន និងសៀវភៅគ្រូ សរសេរចូលសៀវភៅអ្វីឡើយ ។ល។ វាគឺជាអ្វីដែលគេអាចហៅថា " ***ការរៀនសូត្របែបធម្មជាតិ*** " អ្នកសម្របសម្រួលនិយាយថា គ្រូអាចប្រើវិធីច្រើនយ៉ាងនៃការសិក្សាក្នុងថ្នាក់រៀនផ្ទាល់របស់គេនៅសាលារៀន ។

## សកម្មភាព 1.4 ការតុបតែងថ្នាក់រៀន ២០ នាទី

**សម្ភារ** : ផ្ទាំងក្រដាសធំ ប៊ិកហ្វឺត ។




អ្នកសម្របសម្រួលប្រាប់អ្នកចូលរួមឱ្យបង្កើតជាក្រុមតូចៗ និងពិភាក្សាសំណួរផ្តោត : **តើអ្វីខ្លះជាគំនិតល្អជាងគេដែលអ្នកធ្លាប់ប្រើដើម្បីធ្វើឱ្យបរិស្ថានថ្នាក់រៀនមានការទាក់ទាញសិស្សឱ្យចង់រៀន? តើអ្វីខ្លះទៀតជាគំនិតល្អជាងគេ ដែលអ្នកធ្លាប់ឃើញនៅក្នុងថ្នាក់រៀនដទៃទៀត?**

អ្នកចូលរួមធ្វើការងារជាក្រុមតូចៗដើម្បីរាយគំនិតនៅលើផ្ទាំងក្រដាសធំ និងបង្ហាញសម្រាប់ក្រុមទាំងមូល ។ ក្រុមទី១ បង្ហាញគំនិតទាំងអស់របស់ខ្លួន ក្រុមបន្ទាប់បង្ហាញគំនិតថ្មីៗដែលមាន ។ អ្នកសម្របសម្រួលចងក្រងបញ្ជីគំនិតរបស់ក្រុមទាំងអស់ ។

អ្នកចូលរួមអាចសុំឱ្យពន្យល់ជាពិស្តារនូវគំនិតណាមួយ ។ អ្នកចូលរួមដែលបានសរសេរគំនិតទាំងនេះ គួរតែពន្យល់វា ពុំមែន អ្នកសម្របសម្រួលជាអ្នកពន្យល់ឡើយ ។

## សកម្មភាព 1.5 ការគូរប្លង់ថ្នាក់រៀន 45 នាទី

**សម្ភារ** : សៀវភៅកំណត់ត្រាគ្រូ ដ្យាក្រាមបន្ទប់សិក្ខាសាលា ។

អ្នកសម្របសម្រួលប្រាប់អ្នកចូលរួមឱ្យមើលការពណ៌នាអំពីកិច្ចការទី១ ទី២ និងទី៣ នៃប្រធានបទទី១ និងពិភាក្សាវា ជាមួយអ្នកដែលអង្គុយក្បែរខ្លួន ។

អ្នកសម្របសម្រួលសួរសំណួរ : ***តើយើងគួរប្លង់ថ្នាក់រៀននៅពេលណាខ្លះ?***

**<u>ចម្លើយរំពឹងទុក:</u>** *ខែតុលា កុម្ភៈ និងមិថុនា ។*

អ្នកសម្របសម្រួលសួរអ្នកចូលរួម: ***ហេតុអ្វីបានជាយើងត្រូវគូរប្លង់បន្ទប់រៀន៣ នៅពេលវេលាពុខុសៗគ្នាក្នុងឆ្នាំសិក្សា?***

**<u>ចម្លើយរំពឹងទុក:</u>** *ពីព្រោះយើងចង់ឃើញអ្វីដែលប្រែប្រួលនៅទីនោះរៀងរាល់លើក ។ ការផ្លាស់ប្តូរនេះនឹងបង្ហាញថាគ្រូបានអនុវត្តជាក់ស្តែងនូវគំនិតថ្មីៗ ឬ មិនបានអនុវត្ត ។*

### កិច្ចការរបស់អ្នកចូលរួម

អ្នកសម្របសម្រួលប្រាប់អ្នកចូលរួមឱ្យរំលឹកពីរបៀបរៀបចំថ្នាក់រៀនគាត់កាលពីឆ្នាំសិក្សាកន្លងមក ហើយបន្ទាប់មកគូរដ្យាក្រាមថ្នាក់នេះ ។ អ្នកសម្របសម្រួលនិយាយថា រូបភាពពុំត្រូវការខ្នាតលំអិតច្បាស់លាស់ឡើយ ។

នៅពេលអ្នកចូលរួមបានបញ្ចប់ដ្យាក្រាមរបស់ខ្លួនហើយ ពួកគាត់គួរតែបង្ហាញវាដល់អ្នកអង្គុយជិតខ្លួនឱ្យមើលថាតើគាត់អាចយល់វាបានឬទេ ។

អ្នកសម្របសម្រួលបង្ហាញឧទាហរណ៍ខ្លះៗអំពីដ្យាក្រាមបន្ទប់រៀន និងបញ្ជាក់ថា វាជាឧទាហរណ៍យ៉ាងល្អអំពីអ្វីដែលគ្រូគួរធ្វើសម្រាប់កិច្ចការគូរប្លង់ថ្នាក់រៀនទាំងបី នៅក្នុងវគ្គប្រសិទ្ធភាពនៃការបង្រៀន និងរៀន ។

## ប្រធានបទទី 2 ការប្រើប្រាស់សំណួរ

## សកម្មភាព 2.1 ហេតុអ្វីបានជាត្រូវសួរសំណួរ 15 នាទី

**សម្ភារ** : សន្លឹកក្រដាស សម្រាប់សរសេរឧទាហរណ៍នៃសំណួរ ។



អ្នកសម្របសម្រួលប្រើសំណួរដើម្បីទាញយកសេចក្តីសង្ខេបគំនិតសំខាន់ៗអំពីការសួរសំណួរពីសិក្ខាកាមដែលពួកគាត់ប្រហែលជាពួកគាត់បានដឹងរួចហើយពីកាបំប៉នលើកមុន (ឧទាហរណ៍: ប្រធានក្រុមបច្ចេកទេស) ។

- **ហេតុអ្វីបានជាត្រូវសួរសំណួរ?** *ចម្លើយរំពឹងទុក :* ដើម្បីពិនិត្យមើលការយល់ ដើម្បីជំរុញការពិចារណា ដើម្បីឱ្យកុមារនិយាយ ដើម្បីប្រមូលគំនិត និងបទពិសោធពីកុមារ ។ល។
- **តើសំណួរទាំងអស់ដូចគ្នាឬទេ?** *ចម្លើយរំពឹងទុក :* មិនដូចគ្នាទេ ។
- អ្នកសម្របសម្រួលសួរសំណួរបន្ត : តើអ្នកអាចប្រាប់ខ្ញុំពីកម្រិតសំណួរទូទៅពីរបានឬទេ?
- *ចម្លើយរំពឹងទុក :* សំណួរចងចាំ និងសំណួរត្រិះរិះ ។
- **តើអ្វីជាការខុសគ្នារវាងសំណួរចងចាំ និងសំណួរត្រិះរិះ?**
- *ចម្លើយរំពឹងទុក :* សំណួរចងចាំអាចឆ្លើយបានដោយការ ចងចាំអ្វីមួយដែលគ្រូបាននិយាយ ឯសំណួរត្រិះរិះធ្វើឱ្យកុមារពិចារណាល្អិតល្អន់ដោយខ្លួនឯងមុននឹងផ្តល់ចម្លើយ ។

អ្នកសម្របសម្រួលប្រាប់សិក្ខាកាមធ្វើការជាដៃគូ និងសរសេរឧទាហរណ៍នៃសំណួរចងចាំមួយ និងសំណួរត្រិះរិះមួយ ។ អ្នកសម្របសម្រួលចែកក្រដាសពីរសន្លឹកដល់ដៃគូនីមួយៗឱ្យសរសេរសំណួរចងចាំមួយ និង សំណួរត្រិះរិះលើក្រដាសនីមួយៗ ។

អ្នកសម្របសម្រួលហៅសិក្ខាកាមមួយចំនួន ឱ្យស្ម័គ្រចិត្តឡើងបង្ហាញឧទាហរណ៍សំណួររបស់ពួកគាត់ទៅកាន់សិក្ខាកាមទាំងឡាយ ។ សិក្ខាកាមផ្សេងទៀតពិនិត្យមើលនឹងផ្តល់យោបល់យល់ស្រប ប្រសិនបើមិនយល់ស្របជាមួយចម្លើយ ត្រូវផ្តល់មូលហេតុ ។

## សកម្មភាព 2.2 ការធ្វើចំណែកថ្នាក់សំណួរ 60 នាទី

**សម្ភារ** ៖ អត្ថបទគំរូ និងសំណួរ ( អត្ថបទទី១) តារាងទី១ បង្ហាញពីសំណួរ ៦ កម្រិត និង លក្ខណៈរបស់វា ។

អ្នកសម្របសម្រួលនិយាយថា ៖ ប្រព័ន្ធនៃការធ្វើចំណែកថ្នាក់សំណួរភាគច្រើនបានបែងចែកជាច្រើនកម្រិត ។ កម្រិតទី១ គឺសំណួរចងចាំ ដែលសំណួរនេះមានលក្ខណៈងាយជាងគេបំផុត ។ បន្ទាប់មកមាន សំណួរ៥ កម្រិតទៀតដែលសំណួរនីមួយៗតម្រូវឱ្យមានការគិតច្រើនឡើងៗរហូតដល់សំណួរកម្រិតទី៦ គឺសំណួរវាយតម្លៃ ។ ប្រព័ន្ធនៃការធ្វើចំណែកថ្នាក់ត្រូវបានបែងចែកជា៦កម្រិតដោយចាប់ផ្ដើមពីកម្រិតងាយជាងគេបំផុត (ទាបជាងគេបំផុត) ទៅកម្រិត ស្មុគស្មាញបំផុត (កម្រិតខ្ពស់បំផុត) ត្រូវបានគេហៅជាភាសាអង់គ្លេសថា Taxonomy of questions (ការធ្វើចំណែកថ្នាក់ សំណួរតាមកម្រិត) ។

| ក្រុមកម្រិត | ឈ្មោះកម្រិតសំណួរ | អ្វីដែលតម្រូវឱ្យធ្វើ ( លក្ខណៈកម្រិតនៃការគិត ) |
|---|---|---|
| **ចងចាំ** | ចងចាំ | នឹកឃើញឡើងវិញនូវព័ត៌មានណាមួយ |
| **ត្រិះរិះ** | យល់ដឹង | ពន្យល់នូវអត្ថន័យនៃព័ត៌មានណាមួយ |
| | អនុវត្ត | អនុវត្តព័ត៌មានអ្វីមួយដែលបានយល់ ទៅក្នុងស្ថានការណ៍មួយផ្សេងទៀត ដើម្បីបង្កើតជាលទ្ធផលមួយ ។ |
| | វិភាគ | គិតអំពីព័ត៌មានមួយ ឬ ច្រើនហើយបកស្រាយព័ត៌មាននោះ ដើម្បីបង្កើតគំនិតថ្មីឬការសន្និដ្ឋានថ្មីខុសពីព័ត៌មានដែល បានផ្ដល់រួចហើយ |
| | សំយោគ | យកគំនិតពីព័ត៌មានផ្សេងគ្នាចំនួនពីរ ឬ ច្រើនមកបញ្ចូលគ្នា ដើម្បីបង្កើតជាគំនិតថ្មីមួយ ។ |
| | វាយតម្លៃ | ថ្លឹងថ្លែងទិន្នន័យច្រើនដើម្បីបង្កើតជាមតិយោបល់ ឬ ឈានទៅរកការសន្និដ្ឋានមួយ និងពន្យល់ហេតុផលសម្រាប់ការ ថ្លឹងថ្លែងនោះ ។ |

អ្នកសម្របសម្រួលនិយាយថា ឥឡូវនេះសិក្ខាកាមត្រូវគិតបន្ថែមទៀតអំពីការធ្វើចំណាត់ថ្នាក់សំណួរ ។ យើងនឹងយកសំណួរចងចាំដាក់ជាកម្រិតទី១ ប៉ុន្តែយើងបំបែកក្រុមកម្រិតសំណួរត្រិះរិះជា២ក្រុមគឺ សំណួរយល់ដឹង និងសំណួរពិចារណាហ្មត់ចត់។

| | | | |
|---|---|---|---|
| **ការធ្វើចំណែកថ្នាក់ចាស់** | សំណួរចងចាំ | សំណួរត្រិះរិះ | |
| **ការធ្វើចំណែកថ្នាក់ថ្មី** | សំណួរចងចាំ | សំណួរយល់ដឹង | សំណួរពិចារណាហ្មត់ចត់ |

អ្នកសម្របសម្រួលនិយាយថា ៖នៅក្នុងសិក្ខាសាលានេះយើងពុំមានពេលវេលាគ្រប់គ្រាន់ដើម្បីសិក្សា ឱ្យបានល្អិតល្អន់នូវសំណួរទាំង៦កម្រិតនោះទេ ដូច្នោះយើងនឹងនិយាយគ្នាតែអំពី ៖

-កម្រិតទី១៖ សំណួរចងចាំ

-កម្រិតទី២៖ សំណួរយល់ដឹង

-កម្រិតទី៣៖ សំណួរពិចារណាហ្មត់ចត់ ។

អ្នកសម្របសម្រួលនិយាយថា : កម្រិតនៃសំណួរពិចារណាហ្មត់ចត់រួមមាន សំណួរអនុវត្ត វិភាគ សំយោគ និងវាយតម្លៃ ។ សំណួរពិចារណាហ្មត់ចត់ មានលក្ខណៈខុសប្លែកពីសំណួរចងចាំ និងសំណួរយល់ដឹង ពីព្រោះអ្នកត្រូវតែបង្កើតគំនិតថ្មី ឬ ព័ត៌មានថ្មីដើម្បីឆ្លើយនឹងសំណួរទាំងនេះ ។ នៅពេលអ្នកគិតឱ្យបានច្រើនអំពីការប្រើប្រាស់សំណួរ ហើយព្យាយាមអនុវត្តនៅក្នុងថ្នាក់រៀនរបស់អ្នក អ្នកនឹងចាប់ផ្តើមស្គាល់ភាពខុសគ្នារវាងសំណួរពិចារណាហ្មត់ចត់ទាំងបួនកម្រិតនេះនៅពេលចាប់ផ្តើមវាជាការលំបាកមួយ ដូច្នេះយើងមិនព្យាយាមធ្វើនៅក្នុងសិក្ខាសាលានេះទេ ពីព្រោះយើងពុំមានពេលគ្រប់គ្រាន់ដើម្បីអនុវត្ត ។

អ្នកសម្របសម្រួលនិយាយថា : ដើម្បីបញ្ជាក់ឱ្យកាន់តែច្បាស់ យើងនឹងអនុវត្តទៅលើឧទាហរណ៍មួយរួមគ្នា ។ អ្នកសម្របសម្រួលចែក**អត្ថបទទី១** ( ឯកសារចែកជូន) ។

អ្នកសម្របសម្រួលឱ្យសិក្ខាកាមអានអត្ថបទ បន្ទាប់មកអានសំណួរ ។ អ្នកសម្របសម្រួលប្រាប់ឱ្យសិក្ខាកាម **ព្យាយាមឆ្លើយសំណួរ និងសរសេរចម្លើយ** ។ អ្នកសម្របសម្រួលប្រាប់ឱ្យសិក្ខាកាមពិភាក្សាជាមួយអ្នកដទៃទៀត ដើម្បីផ្លាស់ប្តូរយោបល់គ្នា ហើយណែនាំសិក្ខាកាមកុំទាន់សរសេរពីកម្រិតសំណួរ ។

នៅពេលសិក្ខាកាមបានសរសេរចម្លើយរួចហើយ អ្នកសម្របសម្រួលសួរពួកគាត់ពីអ្វីដែលបានសរសេរ សម្រាប់សំណួរទី១ និងបន្ទាប់មកទៀតសំណួរទី២ ។

អ្នកសម្របសម្រួលសួរ: **តើអ្នកដឹងចម្លើយសំណួរទាំងនោះដោយរបៀបណា?**

**ចម្លើយរំពឹងទុក:** *ដោយសារព័ត៌មាននៅក្នុងអត្ថបទព្រោះ ខ្ញុំបានចងចាំ ឬខ្ញុំបានអានវា* ។

អ្នកសម្របសម្រួលយល់ស្រប និងសួរ: **តើសំណួរទាំងនេះជាសំណួរកម្រិតអ្វី?**

**ចម្លើយរំពឹងទុក:** *សំណួរចងចាំ ។*

អ្នកសម្របសម្រួលឱ្យសិក្ខាកាមឆ្លើយសំណួរទី៣និងទី៤ ដោយសួរថា : **តើអ្នកដឹងចម្លើយសំណួរទាំងនោះ ដោយរបៀបណា ?**

**ចម្លើយរំពឹងទុក:** *តាមរយៈការស្វែងយល់អត្ថបទ* ។

អ្នកសម្របសម្រួលនិយាយថា: **ត្រឹមត្រូវ ព្រោះព័ត៌មាននោះ មិនបានបង្ហាញនៅក្នុងអត្ថបទទេ គឺទាល់តែអ្នកបានយល់អត្ថបទសិន ទើបអ្នកអាចរកចម្លើយឃើញ** ។ បន្ទាប់មកអ្នក សម្របសម្រួលបន្តសួរតទៅទៀតថា **តើសំណួរទាំងនេះជាសំណួរកម្រិតអ្វី?**

**ចម្លើយរំពឹងទុក:** *សំណួរយល់ដឹង* ។

បន្ទាប់មកទៀតអ្នកសម្របសម្រួលឱ្យសិក្ខាកាមឆ្លើយសំណួរទី៥ និងទី៧ ។

អ្នកសម្របសម្រួលសួរ: **តើអ្នកឆ្លើយនឹងសំណួរទាំងនោះបានដោយរបៀបណា ?**

**ចម្លើយរំពឹងទុក:** *វាគឺជាគំនិតរបស់ខ្ញុំដោយផ្អែកលើអ្វីៗដែលមាននៅក្នុងអត្ថបទ ។*

អ្នកសម្របសម្រួលសួរថា: **បើដូច្នោះ តើអ្នកត្រូវធ្វើអ្វីខ្លះ ?**

**ចម្លើយរំពឹងទុក:** *យើងត្រូវអានអត្ថបទ ស្វែងយល់អត្ថបទ បន្ទាប់មកប្រើគំនិតផ្ទាល់របស់យើង ដើម្បីឆ្លើយនឹងសំណួរ* ។

អ្នកសម្របសម្រួលសួរថា: *ត្រឹមត្រូវ ។* **បើដូច្នោះតើអ្នកគិតថា សំណួរទី៥ និងទី៧ស្ថិតនៅក្នុងសំណួរកម្រិតណា?**

**ចម្លើយរំពឹងទុក:** *សំណួរពិចារណាហ្មត់ចត់* ។

# អត្ថបទទី១

គ្រូបង្រៀនអានអត្ថបទខ្លីនេះ ឬ សរសេរនៅលើក្រដាស រួចហើយផ្តល់វាទៅឱ្យសិស្សក្នុងក្រុមតូចៗដើម្បីអាន និង ពិភាក្សា :

***មានម៉ូតូ រថយន្ត និងយានយន្តជាច្រើន កំពុងធ្វើចរាចរ នៅលើដងផ្លូវដីហុយ នៅខាង មុខផ្ទះរបស់ខ្ញុំ ដែលមានកុមារតូចៗ លេងនៅទីនោះជារឿយៗ ។ យានយន្តមួយចំនួនបើកក្នុង ល្បឿនលឿន ដែលបញ្ហានេះវាអាចបង្កឱ្យរងរបួសធ្ងន់ធ្ងរដល់ កុមារ និងអាចបណ្តាលឱ្យ កុមារស្លាប់បាត់បង់ជីវិតទៀតផង ។ ខ្ញុំមិនអាចដឹងពីរបៀបដោះស្រាយបញ្ហានេះបានទេ ។***

ក្នុងនាមជាគ្រូបង្រៀន តើអ្នកអាចប្រើសំណួរកម្រិតអ្វីដើម្បីសួរសិស្សអំពីអត្ថបទនេះ ? មានឧទាហរណ៍សំណួរខ្លះបានសរសេរបង្ហាញនៅខាងក្រោម ។ ចូរអាន និងពិភាក្សាជាមួយដៃគូ ហើយធ្វើការសម្រេចចិត្ត ថាតើសំណួរទាំងនេះស្ថិតនៅក្នុង សំណួរកម្រិតណា (សំណួរចងចាំ សំណួរយល់ដឹង ឬ សំណួរពិចារណាហ្មត់ចត់) ។

| ល.រ | សំណួរ | ចម្លើយដែលអាចឆ្លើយបាន | កម្រិតសំណួរ |
|---|---|---|---|
| ១ | តើមានយានយន្តអ្វីខ្លះ កំពុងចរាចរនៅលើផ្លូវ? | *ម៉ូតូ រថយន្ត និងយានយន្តផ្សេងៗ ទៀត* | *ចងចាំ* |
| ២ | តើផ្លូវនេះស្ថិតនៅឯណា? | *នៅខាងមុខផ្ទះរបស់ខ្ញុំ* | *ចងចាំ* |
| ៣ | តើនរណាដែលនឹងងាយទទួលរងរបួសជាងគេ? | *កុមារ* | *យល់ដឹង* |
| ៤ | ហេតុអ្វីកុមារត្រូវប្រឈមមុខនឹងការរងរបួស? | *ពីព្រោះពួកគេ កំពុងលេងនៅក្បែរផ្លូវ*<br>*ពីព្រោះផ្លូវនោះហុយ និងពិបាកមើលឃើញកុមារ*<br>*ពីព្រោះចរាចរតាមផ្លូវមានល្បឿនលឿន* | *យល់ដឹង* |
| ៥ | តើអ្នកគិតថា ហេតុអ្វីបានជាកុមារលេងនៅក្បែរផ្លូវ? | *ពីព្រោះកុមារតែងតែលេងនៅទីនោះ*<br>*ពីព្រោះពុំមានទីធ្លាផ្សេងសម្រាប់កុមារលេង*<br>*ពីព្រោះឪពុកម្តាយរបស់ពួកគេមិនការពារ* | *សំណួរពិចារណាហ្មត់ចត់* |
| ៦ | តើអ្វីទៅដែលអ្នកនិពន្ធព្រួយបារម្ភជាងគេបំផុត? | *កុមារកំពុងលេងលើផ្លូវដែលគ្រោះថ្នាក់*<br>*យានយន្តបើកបរក្នុងល្បឿនលឿន* | *យល់ដឹង* |
| ៧ | តើអ្នកគិតថា មនុស្សដែលរស់នៅក្បែរដងផ្លូវត្រូវធ្វើអ្វីខ្លះដើម្បីការពារកុមារកុំឱ្យរងរបួស ? | *សំអាត ឬ ស្រោចទឹកកុំឱ្យផ្លូវហុយ បញ្ឈប់យានយន្តធំៗដែលចរាចរលើផ្លូវនេះ*<br>*ដាក់ផ្លាកសញ្ញាបង្ហាញថា "កុមារកំពុងលេង"*<br>*កសាងទំនប់កាត់ផ្លូវដើម្បីបន្ថយល្បឿន*<br>*កសាងទីធ្លាដែលមានសុវត្ថិភាពឱ្យកុមារលេង* | *សំណួរពិចារណាហ្មត់ចត់* |

អ្នកសម្របសម្រួលដាក់តាំងតារាងទី១និងនិយាយ ៖ នេះជាតារាងដែលសង្ខេបសំណួរទាំងបីកម្រិត ។ ចូរពិនិត្យមើល និងពិភាក្សាជាមួយអ្នកដែលអង្គុយក្បែរ។ យើងនឹងប្រើតារាងនេះនៅក្នុងសកម្មភាពបន្ទាប់ ហើយអ្នកអាចអនុវត្តក្នុងការធ្វើចំណែកថ្នាក់កម្រិតសំណួរទាំងបី ដោយខ្លួនឯង។

| **កម្រិតសំណួរ** | **កម្រិតនៃការគិត/សកម្មភាព ដែលចាំបាច់ដើម្បីឆ្លើយ** |
|---|---|
| ចងចាំ | **នឹកឃើញ ចងចាំ**<br>អ្វីមួយដែល បានរៀនរួច |
| យល់ដឹង | **យល់ដឹង ពន្យល់**<br>ទៅតាមរបៀប ផ្សេងពីគំនិត ឬព័ត៌មានដែលបានផ្ដល់ឱ្យ |
| ពិចារណាហ្មត់ចត់ | **យល់ដឹង និងបង្កើតគំនិតថ្មី**<br>ប្រៀបធៀប បង្ហាញភាពផ្ទុយគ្នា បកស្រាយ អនុវត្ត ស្រាវជ្រាវ<br>រកហេតុផល វិភាគ ធ្វើសម្មតិកម្ម វាយតម្លៃ កំណត់អាទិភាព |

## សកម្មភាព 2.3 លំហាត់អំពីសំណួរទាំងបីកម្រិត 45 នាទី

### ក.ការណែនាំ

**សម្ភារ** ៖ អត្ថបទគំរូ និងសំណួរ (សកម្មភាពរៀនសូត្រទី១ និងសកម្មភាពរៀនសូត្រទី២) ឯកសារសង្ខេបនៃសកម្មភាពរៀនសូត្រ និងសំណួរ សម្រាប់វិភាគតាមក្រុមតូចៗ សម្រាប់គ្រូ ស្ដីអំពីការសួរសំណួរ និងការពិចារណាហ្មត់ចត់ ។

អ្នកសម្របសម្រួលប្រាប់អ្នកចូលរួមថា ឥឡូវនេះពួកគាត់នឹងអនុវត្តអ្វីដែលបានរៀននៅក្នុងសកម្មភាពមុន ។ អ្នកសម្របសម្រួលនិយាយថា ៖ អ្នកចូលរួមនឹងចែកចេញជាក្រុមតូចៗ ។ កិច្ចការដែលត្រូវធ្វើគឺត្រូវអាន និងពិភាក្សា លើការអធិប្បាយចំនួនពីរអំពីសកម្មភាពរៀនសូត្រ និងកម្រងសំណួរបន្ទាប់ពីអានចប់ការអធិប្បាយនីមួយៗ ។ ការអធិប្បាយ ទី១ គឺជាសកម្មភាពមុខវិជ្ជាវិទ្យាសាស្ត្រ និងទី២ក្នុងមុខវិជ្ជាគណិតវិទ្យា ។ ក្រុមពាក់កណ្ដាលនឹងធ្វើការវិភាគសកម្មភាពរៀនសូត្រទី១ និងពាក់កណ្ដាលទៀត វិភាគសកម្មភាពរៀនសូត្រទី២ ។ ពួកគេត្រូវយល់ស្របគ្នាលើចម្លើយ ចំពោះសំណួរដែលគ្រូកំពុងប្រើនៅក្នុងសកម្មភាពរៀនសូត្រនីមួយៗ ហើយធ្វើការសម្រេចចិត្តថា តើសំណួរនីមួយៗចូលទៅក្នុង កម្រិតមួយណាជាសំណួរចងចាំ យល់ដឹង ឬ ពិចារណាហ្មត់ចត់ ។

នៅពេលគ្រូបានបញ្ចប់ការវិភាគរបស់ខ្លួនហើយ អ្នកសម្របសម្រួលអញ្ជើញក្រុមមួយ ឱ្យឡើងបង្ហាញលទ្ធផលពួកគាត់អំពីសកម្មភាពរៀនសូត្រនីមួយៗ ។ អ្នកចូលរៀនដទៃទៀតអាចមិនយល់ស្រប ផ្ដល់មូលហេតុ និងពិភាក្សា ។

### ខ.លំហាត់ទី១

## សកម្មភាពរៀនសូត្រទី១

គ្រូបង្រៀន និងសិស្សដាំគ្រាប់ផ្កាតូចៗនៅក្នុងសួនច្បារ គឺគ្រាប់ផ្កាស្ពៃរឿង ។ សិស្សទាំងអស់ បែងចែកជា៦ក្រុមតូចៗ ។ សិស្សនៅក្នុងក្រុមត្រូវមានតួនាទីថែរក្សាផ្កានោះ (ស្រោចទឹក។ល។)។ សិស្សសង្កេតមើលផ្កាម្តងក្នុងមួយសប្តាហ៍ ហើយគ្រូសួរពួកគេឱ្យរៀបរាប់ ពីអ្វីដែលបានសង្កេតឃើញ ។ នៅលើកដំបូងពុំឃើញមានអ្វីកើតឡើងទេ តែក្រោយមកកូនរុក្ខជាតិក៏ដុះឡើង ។ បន្ទាប់ពីរយៈពេលមួយខែដែលសិស្សបានដាំគេឃើញផ្កាខ្លះរីកឡើងមានពណ៌លឿង និងផ្ការបស់ក្រុមមួយបានងាប់ ។ មួយថ្ងៃបន្ទាប់ពីផ្កានោះងាប់ គ្រូរៀបចំកិច្ចតែងការអំពីផ្កា និងសួនច្បារ ។ គាត់បានផ្តល់សំណួរចំនួន ៦ ឱ្យសិស្សធ្វើការពិភាក្សាជាក្រុមតូចៗ ។

| ល.រ | សំណួរ | ចម្លើយរំពឹងទុក | កម្រិតសំណួរ |
|---|---|---|---|
| ១ | តើរុក្ខជាតិនោះមានឈ្មោះអ្វី? | *ឈ្មោះ* | *ចងចាំ* |
| ២ | តើរុក្ខជាតិនោះមានអាយុប៉ុន្មានខែ? | *១ ខែកន្លងមកហើយ* | *ចងចាំ* |
| ៣ | តើផ្កាមានពណ៌អ្វី? | *ពណ៌លឿង* | *ចងចាំ* |
| ៤ | តើរុក្ខជាតិត្រូវការអ្វីដើម្បីលូតលាស់? | *ទឹក ដី ពន្លឺព្រះអាទិត្យ* | *យល់ដឹង* |
| ៥ | ហេតុអ្វីបានជាផ្កាមួយចំនួនងាប់? | *ទឹកច្រើនពេក*<br>*ពន្លឺច្រើនពេក*<br>*ទឹកមិនគ្រប់គ្រាន់*<br>*ផ្កាចាស់*<br>*ផ្កាមានជំងឺ* | *ពិចារណាហ្មត់ចត់* |
| ៦ | តើអ្នកគិតថា ហេតុអ្វីបានជាដើមផ្កាមួយចំនួនដុះ លូតលាស់បានខ្ពស់ និងមានផ្កាច្រើនជាងដើមផ្កា ផ្សេងៗទៀត? | *ដាំនៅលើដីដែលមានជីជាតិល្អ*<br>*ពូជមានគុណភាពល្អ*<br>*ផ្កាមានសុខភាពល្អ គ្មានជំងឺ*<br>*កុមារនៅក្នុងក្រុមយកចិត្តទុកដាក់ថែរក្សាបានល្អ*<br>*ផ្កាទទួលបានពន្លឺព្រះអាទិត្យគ្រប់គ្រាន់* | *ពិចារណាហ្មត់ចត់* |

សិស្សអាចឆ្លើយសំណួរបីដំបូង ដោយការចងចាំ ។ សំណួរទី៤ត្រូវការការយល់ដឹងខ្លះ ពីស្ថានភាពនៃការដាំផ្កា ។ សំណួរពីរចុងក្រោយតម្រូវឱ្យសិស្សប្រើប្រាស់ការយល់ដឹងរបស់ពួកគេ និងបទពិសោធបូករួមនឹងគំនិតថ្មីៗផ្ទាល់ខ្លួន ដើម្បីឆ្លើយសំណួរ ។

**គ.លំហាត់ទី២**

## សកម្មភាពរៀនសូត្រទី២

គ្រូបង្រៀនផ្ដល់គ្រាប់ឈើគួសចំនួន២០ ទៅក្រុមតូចនីមួយៗនៅក្នុងថ្នាក់ទី២ ។ បន្ទាប់មកគ្រូប្រាប់ឱ្យសិស្សធ្វើការរួមគ្នា ដើម្បីយល់ស្របគ្នា ទៅនឹងសំណួរដែលគ្រូនឹងសួរពួកគេ ។

| សំណួរ | ចម្លើយរំពឹងទុក | កម្រិតសំណួរ |
|---|---|---|
| តើមានគ្រាប់ឈើគួសចំនួនប៉ុន្មាន? | *២០* | *ចងចាំ* |
| គ្រាប់ឈើគួសចំនួន២០នេះ បើយើងបែងចែកមួយក្រុម៥ដើម ។ តើចែកបានប៉ុន្មានក្រុម? | *៤* | *ចងចាំ* |
| សិស្សម្នាក់មានកូនគ្លី២០ នៅក្នុងហោប៉ៅខោ ។ ហោប៉ៅខោនោះមានប្រហោង ហើយនៅពេលវាមកដល់សាលារៀនឃើញនៅសល់តែកូនគ្លី១៣ ។ តើកូនគ្លីបាត់អស់ប៉ុន្មាននៅតាមផ្លូវ ? | *៧* | *ចងចាំ??*<br>*យល់ដឹង* |
| កុមារម្នាក់មានកូនឃ្លី២០ ហើយវាបានឱ្យកូនឃ្លីទៅមិត្តរបស់វាម្នាក់ៗចំនួន៤ ។ តើកុមារនេះមាន មិត្តប៉ុន្មាននាក់? | *៥* | *ចងចាំ??*<br>*យល់ដឹង* |
| តើអ្នកអាចបង្កើតការេបានទំហំប៉ុណ្ណា?<br>តើអ្នកនៅសល់គ្រាប់ឈើគួសឬទេ?<br>តើអ្នកអាចបង្កើតការេដោយប្រើគ្រាប់ឈើគួសនោះឬទេ? | *១ជ្រុង ៥ គ្រាប់ឈើគួស* | *ពិចារណាហ្មត់ចត់* |
| តើអ្នកអាចបង្កើតចតុកោណកែង ដោយប្រើគ្រាប់ឈើគួសចំនួន២០ បានវែងប៉ុណ្ណា?<br>តើអ្នកអាចបង្កើតចតុកោណកែងដែលមានរូបផ្សេងៗទៀត ឬទេ? អ្វីខ្លះ? | *ប.៩ ទ.១ គ្រាប់ឈើគួស*<br>*ប.៨ ទ.២ គ្រាប់ឈើគួស*<br>*ប.៧ ទ.៣ គ្រាប់ឈើគួស*<br>*ប.៦ ទ.៤ គ្រាប់ឈើគួស* | *ពិចារណាហ្មត់ចត់* |

សិស្សអាចឆ្លើយសំណួរពីរដំបូងដោយ**ការរាប់** ។ សិស្សត្រូវស្ដាប់ចំណោទពីរបន្ទាប់ទៀត **ស្វែងយល់អត្ថន័យ** ហើយបន្ទាប់មកធ្វើតាមអ្វីដែលកើតឡើងនៅក្នុងចំណោទ ដើម្បីឆ្លើយសំណួរ ។ នៅក្នុងសំណួរពិចារណាហ្មត់ចត់ទាំងពីរ សិស្សត្រូវ**ស្ដាប់ ស្វែងយល់** និង**ប្រើការយល់ដឹង**របស់ពួកគេ អំពីអ្វីដែលជាការេ និងចតុកោណកែង ទៅក្នុងការពិសោធដើម្បីរកចម្លើយ ។

នៅពេលសិក្ខាកាមបំពេញកិច្ចការចប់ អ្នកសម្របសម្រួលហៅក្រុមចំនួន២ឱ្យស្ម័គ្រចិត្តឡើងបង្ហាញការរកឃើញរបស់ពួកគេមួយ សម្រាប់ឧទាហរណ៍ទី១ (លំហាត់ទី១) និងមួយទៀតសម្រាប់ឧទាហរណ៍ទី២ (លំហាត់ទី២) ។ នៅក្នុងខណៈក្រុមឡើងបង្ហាញ អ្នកសម្របសម្រួល សួរសិក្ខាកាមផ្សេងទៀត ថាតើពួកគេយល់ស្របទៅនឹងការសន្និដ្ឋាននេះដែរឬទេ ។

**សកម្មភាព 2.4 លំហាត់សរសេរសំណួរដែលមានកម្រិតខ្ពស់** 60 នាទី

**សម្ភារ** : ឯកសារសៀវភៅគោលមុខវិជ្ជាសិក្សាសង្គម ។

អ្នកសម្របសម្រួលនិយាយថា ឥឡូវនេះសិក្ខាកាមត្រូវធ្វើការជាក្រុមតូចដើម្បីអនុវត្តសរសេរសំណួរទាំងបីកម្រិតដោយខ្លួនឯង ដោយផ្អែកលើមេរៀនក្នុងសៀវភៅសិក្សាសង្គមរបស់ក្រសួងអប់រំ យុវជន និងកីឡាទៅតាមកម្រិតថ្នាក់របស់ខ្លួន ។

ដើម្បីធ្វើកិច្ចការនេះសិក្ខាកាមត្រូវជ្រើសរើសមេរៀនមួយក្នុងចំណោម ៣ មេរៀននៅក្នុងឯកសារ (មើលឯកសារខាងក្រោម) :

**មេរៀនចំនួន ៣ ក្នុងមុខវិជ្ជាសិក្សាសង្គម**

១.( គ្រូឧទ្ទេសស្រង់មេរៀនដាក់ឱ្យ) ឧទាហរណ៍ : **សីលធម៌**

២. ឧទាហរណ៍ : **ភូមិវិទ្យា និង ប្រវត្តិវិទ្យា**

៣. ឧទាហរណ៍ : **ពលរដ្ឋវិជ្ជា**

បន្ទាប់ពីអាន និងពិភាក្សាមេរៀនដែលបានជ្រើសរើសសិក្ខាកាមឯកភាពសរសេរសំណួរ ៦ អំពីមេរៀន ។ សំណួរ ២ ជាសំណួរចងចាំ សំណួរ ២ ជាសំណួរយល់ដឹង និងសំណួរ ២ ទៀតជាសំណួរពិចារណាហ្មត់ចត់ ។ សិក្ខាកាមបង្ហាញសំណួរទាំងនោះដល់ថ្នាក់ទាំងមូលដោយប្រើទម្រង់ដូចខាងក្រោម

| | |
|---|---|
| **សំណួរចងចាំទី១** | |
| **សំណួរចងចាំទី២** | |
| **សំណួរយល់ដឹងទី១** | |
| **សំណួរយល់ដឹងទី២** | |
| **សំណួរពិចារណាហ្មត់ចត់ទី១** | |
| **សំណួរពិចារណាហ្មត់ចត់ទី២** | |

នៅពេលអ្នកចូលរួមបានបញ្ចប់កិច្ចការរបស់ខ្លួនហើយ អ្នកសម្របសម្រួលគួរតែជ្រើសរើសឧទាហរណ៍ខ្លះ សម្រាប់ការបង្ហាញ និងដាក់តាំង ។ អ្នកសម្របសម្រួលគួរតែអញ្ជើញក្រុមផ្សេងទៀតឱ្យផ្តល់យោបល់អំពីអ្វីដែលបានបង្ហាញ ជាពិសេសពួកគាត់យល់ស្របថា តើការប្រើសំណួរទាំងនេះត្រូវតាមកម្រិតនីមួយៗឬទេ ។

## សកម្មភាព 2.5 សកម្មភាពរៀនសូត្រ ដើម្បីជំរុញការពិចារណាហ្មត់ចត់ 90 នាទី

**១. ការសិក្សាបែបស្រាវជ្រាវ** (ការប្រមូលភស្តុតាង/ទិន្នន័យ ធ្វើការសន្និដ្ឋាន)

**សម្ភារ** : ឧទាហរណ៍នៃកិច្ចការស្រាវជ្រាវ សម្រាប់ថ្នាក់ទី១, ទី៣ និងទី៥ ។

អ្នកសម្របសម្រួល : ការរៀបចំសកម្មភាពសិក្សាងាយៗសម្រាប់សិស្សគឺជារបៀបមួយប្រសើរណាស់ក្នុងការជំរុញការពិចារណាហ្មត់ចត់ ។ នេះដោយសារសិស្ស "កំពុងបង្កើត" ចំណេះដឹងសម្រាប់ខ្លួនរបស់ពួកគេតាមរយៈការស្រាវជ្រាវដែលពួកគេធ្វើគឺមិនមែនគ្រាន់ តែចាំស្តាប់ និងអានអ្វីមួយប៉ុណ្ណោះទេ ។

អ្នកសម្របសម្រួលនិយាយថាៈទោះបីជាយើងស្តាប់ទៅវាហាក់ដូចជាស្មុគស្មាញ និងលំបាក ប៉ុន្តែការងារស្រាវជ្រាវងាយៗនេះ គឺសិស្សគ្រប់អាយុទាំងអស់នឹងអាចធ្វើបាន ។ គ្រូបង្រៀនគួរសួរសំណួរឱ្យបានច្បាស់ និងផ្តល់នូវសេចក្តីណែនាំ (ឬគម្រោង) អំពីរបៀបធ្វើកិច្ចការនោះ ។ ដូចនេះគ្រូបង្រៀនគួររៀបចំសកម្មភាពសំខាន់ខ្លះៗដូចជា :

-កំណត់ប្រធានបទស្រាវជ្រាវ

-កំណត់ទីកន្លែង និងពេលវេលា

-ចាត់តាំងក្រុមការងារ

-កំណត់មុខសញ្ញាអ្នកដែលត្រូវសម្ភាស (អ្នកផ្តល់ព័ត៌មាន)

-រៀបចំកម្រងសំណួរដែលអាចជួយសិស្សឱ្យបានគិតល្អិតល្អន់អំពីព័ត៌មានដែលពួកគេ ត្រូវប្រមូល

-ប្រមូលផ្តុំទិន្នន័យព័ត៌មាន និងចងក្រងខ្លឹមសារមេរៀន/ប្រធានបទ

| ថ្នាក់ទី | កិច្ចការស្រាវជ្រាវ | សំណួរស្រាវជ្រាវ ដំណើរការ និងសំណួរពិចារណាហ្មត់ចត់ |
|---|---|---|
| ១ | អំពីអាហារពេលព្រឹក | **តើយើងមានអ្វីសម្រាប់អាហារពេលព្រឹក ព្រឹកនេះ?**<br>សិស្សបង្កើតជាក្រុមទៅតាមប្រភេទអាហារពេលព្រឹករបស់ពួកគេ (បាយ មីគ្មាន ។ល។) ។ អ្នកដឹកនាំក្រុមរាប់ក្រុមរបស់ពួកគេ ។ សិស្សសរសេរចំនួនក្រុមនីមួយៗនៅលើក្តារខៀន ។ គ្រូបង្រៀនសួរសំណួរបន្ថែម អាហារពេលព្រឹក ដែលពេញនិយមបំផុត ។ល។<br>**តើយើងបានរៀនអ្វីខ្លះពីការសិក្សាស្រាវជ្រាវរបស់ពួកយើង?**<br>• កុមារភាគច្រើននៅក្នុងថ្នាក់បរិភោគបាយកកនៅពេលព្រឹក<br>• កុមារមួយចំនួនបរិភោគមី<br>• កុមារមួយចំនួនទៀតមិនបរិភោគអ្វីទេនៅពេលព្រឹកមុនមកសាលារៀន |
| ៣ | អំពីកូនរុក្ខជាតិ | **តើប្រភេទដើមផ្កាអ្វីខ្លះដែលដាំនៅផ្ទះរបស់ពួកយើង?**<br>សម្រាប់កិច្ចការធ្វើនៅផ្ទះ កុមារទាំងអស់ត្រូវនាំយកឧទាហរណ៍មួយអំពីផ្កា និងស្លឹកពីកូនរុក្ខជាតិ ដែលដុះនៅក្បែរ ឬក្នុងផ្ទះ ។ នៅសាលាពួកគេជួបជុំជាក្រុមដើម្បីពិនិត្យមើល រាប់ និងប្រាប់ឈ្មោះផ្កា ដែលសមាជិកក្រុមនាំយកមក ។ ក្រុមនីមួយបង្ហាញលទ្ធផលរបស់ខ្លួន ។<br>**តើយើងបានរៀនអ្វីខ្លះពីការស្រាវជ្រាវរបស់ពួកយើង?**<br>• មនុស្សភាគច្រើនដាំផ្កាស្បៃរឿង<br>• មនុស្សភាគច្រើនចូលចិត្តផ្កាពណ៌លឿង និងក្រហម |

| | | |
|---|---|---|
| | | • យើងឃើញ មានផ្កាពីរប្រភេទដែលគេមិនស្គាល់ឈ្មោះ |
| ៥ | អំពីចរាចរ | **តើផ្លូវនៅក្រៅរបងសាលាយើង មានភាពមមាញឹកយ៉ាងណា ? តើរថយន្តធំ និងរថយន្តតូចបន្ថយល្បឿនឬទេ នៅពេលឆ្លងកាត់សាលារៀន ?**<br>បើសិនជាសាលារៀននៅជាប់នឹងផ្លូវដែលមានចរាចរមមាញឹក សិស្សអាចរាប់ និងធ្វើចំណាត់ថ្នាក់ប្រភេទរថយន្ត (រថយន្តក្រុង រថយន្តនីសាន់ រថយន្តតូច ម៉ូតូ រ៉ឺម៉ក រទេះគោ កង់ ។ល។ ដែលឆ្លងកាត់សាលារៀនរវាង ម៉ោង៧ និងម៉ោង ៧:៣០នាទី ។ សិស្សអាចធ្វើកំណត់សម្គាល់អំពីរថយន្តធំ និងរថយន្តតូច ដែលបើកក្នុងល្បឿនលឿនផងដែរ ។<br>**តើយើងបានរៀនអ្វីខ្លះពីការស្រាវជ្រាវរបស់ពួកយើង?**<br>• រថយន្តធំចំនួន... និងរថយន្តតូចចំនួន...បានឆ្លងកាត់ក្នុងរយៈពេល៣០នាទី<br>• យានយន្តមួយចំនួនបើកបរយ៉ាងលឿន ។ ចំនួនពាក់កណ្ដាលនៃរថយន្តធំ និងរថយន្តតូចមិនបានបន្ថយល្បឿនទេ នៅពេលបើកបរឆ្លងកាត់សាលារៀន ។<br>• យើងគួរបង្កើតផ្លាកសញ្ញាថ្មី និងមានទំហំធំ ជាសញ្ញាឱ្យយានយន្តបន្ថយល្បឿន ដើម្បីឱ្យមានសុវត្ថិភាពដល់កុមារនៅពេលចូល សាលារៀន ។ |

**កិច្ចការស្រាវជ្រាវជាច្រើនទាក់ទងនឹងជំហានចំនួន៣សំខាន់ៗខាងក្រោម :**

- **ធ្វើ** : សិស្សធ្វើអ្វីមួយរួមគ្នា
- **ពិភាក្សា** : សិស្សពិភាក្សាអំពីអ្វីដែលពួកគេបានរកឃើញ និងអត្ថន័យរបស់វា
- **កត់ត្រា/បង្ហាញ** : សិស្សកត់ត្រាពីលទ្ធផលរបស់ពួកគេ ទៅតាមរបៀបណាមួយ

★ កិច្ចការរបស់សិក្ខាកាម : ធ្វើការជាក្រុមតូចៗ ដើម្បីជ្រើសរើសសកម្មភាពស្រាវជ្រាវងាយៗ សម្រាប់សិស្សថ្នាក់ទី២ ទី៤ និងទី៦ ទៅតាមរបៀបដែលខ្ញុំបានបង្ហាញ សម្រាប់ថ្នាក់ទី១ ទី៣ និងទី៥ ។

**២.ការធ្វើចំណែកថ្នាក់តាមក្រុម**

**✦ សិក្សាសង្គម និងវិទ្យាសាស្ត្រអនុវត្ត**

**សម្ភារ** : ក្រដាសធំ ប៊ិកហ្វឺត បញ្ជីឈ្មោះប្រទេស និងឈ្មោះសត្វ (ឯកសារចែកជូន) ។ ដ្យាក្រាមនៃការធ្វើចំណែកថ្នាក់ដាក់តាមក្រុមប្រទេស និងសត្វ (ឯកសារចែកជូន) ។

អ្នកសម្របសម្រួល : ការធ្វើចំណែកថ្នាក់ដាក់តាមក្រុមគឺជាប្រព័ន្ធនៃការធ្វើចំណែកថ្នាក់ ជាវិធីនៃការរៀបចំអ្វីមួយទៅតាមជំពូក ។ វប្បធម៌ និងភាសាផ្សេងៗគ្នាក៏អាចធ្វើចំណែកថ្នាក់ ទៅតាមរបៀបផ្សេងៗគ្នា ។ មនុស្សធ្វើចំណែកថ្នាក់ផ្សេងៗគ្នាដាក់តាមក្រុមជាតិសាសន៍ ។ សត្វ និងរុក្ខជាតិធ្វើចំណែកថ្នាក់ទៅតាមប្រភេទរបស់វា ។

អ្នកសម្របសម្រួល : ដើម្បីយល់អំពីគំនិតនៃការធ្វើចំណែកថ្នាក់ដាក់តាមក្រុម វាជាការល្អប្រសើរដែលយើងត្រូវអនុវត្តដោយប្រើឧទាហរណ៍ជាក់ស្តែងខ្លះៗ ។ នៅខាងក្រោមនេះមានវត្ថុពីរក្រុម ។ ក្រុមទី១ ជាក្រុមប្រទេសនៅក្នុងពិភពលោក និងក្រុមទី២ ជាប្រភេទសត្វ ។ កិច្ចការរបស់សិក្ខាកាមគឺត្រូវធ្វើការងារតាមក្រុមតូចៗ ដើម្បីសម្រេចចិត្តលើការបែងចែកវត្ថុក្នុងក្រុមទៅតាមជំពូករបស់វា ដាក់ឈ្មោះជំពូកនីមួយៗ និងត្រូវយល់ព្រមលើក្បួនដែលជា មូលហេតុបញ្ជាក់ថាវត្ថុនេះគួរស្ថិតនៅតាមក្រុមផ្សេងៗគ្នា ។

| **ក្រុមទី១ : ប្រទេសនៅក្នុងពិភពលោក** |
|---|
| កម្ពុជា បារាំង វៀតណាម ចិន អាឡឺម៉ង់ អ៊ីតាលី ម៉ាឡេស៊ី ជប៉ុន ហ្វីលីពីន ស្រីលង្កា ឥណ្ឌា អេស្ប៉ាញ ឡាវ អៀរឡង់ សឹង្ហបុរី ទួកគី ស៊ុយអែត អង់គ្លេស |

↓

<table>
<tr><td colspan="4">ក្រុមទី១ : ចំណែកថ្នាក់ដាក់តាមក្រុមដែលអាចធ្វើបាន</td></tr>
<tr><td colspan="4">ជំពូក : ប្រទេសនៅក្នុងពិភពលោក<br>កម្ពុជា បារាំង វៀតណាម ចិន អាឡឺម៉ង់ អ៊ីតាលី ម៉ាឡេស៊ី ជប៉ុន ហ្វីលីពីន ស្រីលង្កា ឥណ្ឌា អេស្ប៉ាញ ឡាវ អៀរឡង់ សឹង្ហបុរី</td></tr>
<tr><td colspan="2">ជំពូក : អាស៊ី<br>កម្ពុជា វៀតណាម ចិន ម៉ាឡេស៊ី ជប៉ុន ហ្វីលីពីន ស្រីលង្កា ឥណ្ឌា ឡាវ សឹង្ហបុរី</td><td colspan="2">ជំពូក : អឺរ៉ុប<br>បារាំង អាឡឺម៉ង់ អ៊ីតាលី អេស្ប៉ាញ ចក្រភពអង់គ្លេស ស៊ុយអែត អៀរឡង់ ទួកគី</td></tr>
<tr><td>ជំពូក : អាស៊ាន<br>កម្ពុជា វៀតណាម ឡាវ ម៉ាឡេស៊ី ហ្វីលីពីន សឹង្ហបុរី</td><td>ជំពូក: មិនមែនអាស៊ាន<br>ចិន ជប៉ុន ស្រីលង្កា ឥណ្ឌា</td><td>ជំពូក : ទ្វីបអឺរ៉ុប<br>បារាំង អាឡឺម៉ង់ អ៊ីតាលី អេស្ប៉ាញ ទួកគី</td><td>ជំពូក : តំបន់កោះនៅ អឺរ៉ុប<br>ចក្រភពអង់គ្លេស ស៊ុយអែត អៀរឡង់</td></tr>
</table>

| **ក្រុមទី២ សត្វ** |
|---|
| ឆ្កែ ឆ្មា បង្កង បង្គា មាន់ ឆ្លាម ទា ខ្លា មឹក បាឡែន ខ្លាឃ្មុំ ឥន្ទ្រី ត្រីរស់ ត្រីបបែល ក្រៀល ក្ងាន ចាប ភេ ក្របី |

<table>
<tr><td colspan="4">ក្រុមទី២ ៖ ចំណែកថ្នាក់ដាក់តាមក្រុមដែលអាចធ្វើបាន</td></tr>
<tr><td colspan="4">ជំពូក ៖ សត្វ<br>ឆ្កែ ឆ្មា បង្កង បង្គា មាន់ ឆ្លាម ទា ខ្លា មឹក បាឡែន ខ្លាឃ្មុំ ឥន្ទ្រី ត្រីរ៉ស់ ត្រីបបែល ក្រៀល ក្ងាន ចាប ភេ ក្របី</td></tr>
<tr><td colspan="2">ជំពូក ៖ សត្វលើគោក<br>ឆ្កែ ឆ្មា មាន់ ខ្លា ខ្លាឃ្មុំ ឥន្ទ្រី ក្រៀល ក្ងាន ចាប ក្របី</td><td colspan="2">ជំពូក ៖ សត្វក្នុងទឹក<br>បង្កង បង្គារ ឆ្លាម មឹក បាឡែន ត្រីរ៉ស់ ត្រីបបែល ភេ</td></tr>
<tr><td>ជំពូក ៖ ថនិកសត្វ<br>ឆ្កែ ឆ្មា ខ្លា ខ្លាឃ្មុំ ក្របី</td><td>ជំពូក ៖ បក្សី<br>មាន់ ទា ឥន្ទ្រី ក្រៀល ក្ងាន</td><td>ជំពូក ៖ ទឹកសាប<br>បង្កង ត្រីរ៉ស់ ភេ</td><td>ជំពូក ៖ ទឹកប្រៃ<br>មឹក បង្គា ឆ្លាម បាឡែន ត្រីបបែល</td></tr>
</table>

ក្រុមតូចៗពាក់កណ្ដាលធ្វើកិច្ចការអំពីការធ្វើចំណែកថ្នាក់ដាក់តាមក្រុមទី១ និងពាក់កណ្ដាលទៀត ធ្វើចំណែកថ្នាក់ដាក់តាមក្រុមទី២ ។ នៅពេលដែលពួកគាត់បានបញ្ចប់ អ្នកចូលរួមត្រូវយកក្រដាសគាត់មកខាងមុខដាក់តាំង ។ អ្នកសម្របសម្រួលជ្រើសរើសតំណាងខ្លះឱ្យឡើងមកបង្ហាញ និងពន្យល់ការធ្វើចំណែកថ្នាក់ក្រុមរបស់ពួកគាត់ ។ ក្រុមដទៃទៀតដែលប្រហែលជាបានលទ្ធផលផ្សេងពីនេះ អាចផ្ដល់យោបល់នៅពេលចុងក្រោយ ។ អ្នកសម្របសម្រួលឱ្យអ្នកចូលរួមទាំងអស់ពិនិត្យមើលឈ្មោះជំពូកនានា និងប្រទេស/សត្វនៅក្នុងជំពូកនីមួយៗដោយហ្មត់ចត់ ដើម្បីឱ្យឃើញថា អ្វីៗទាំងអស់បានដាក់ត្រឹមត្រូវ ។

អ្នកសម្របសម្រួលសួរសិក្ខាកាមថា ៖ តើពួកគាត់អាចបែងចែកក្រុមថនិកសត្វឱ្យទៅជាពីរឬបីក្រុមផ្សេងទៀតបានឬទេ? ចម្លើយរំពឹងទុក ៖ សត្វព្រៃ/សត្វស្រុក ស៊ីស្មៅ/ស៊ីសាច់ ។



## ✦ គណិតវិទ្យា

**សម្ភារ ៖** ក្រដាសធំ ប៊ិកហ្វឺត រូបធរណីមាត្រ (ឯកសារចែកជូន) ។

កិច្ចការរបស់សិក្ខាកាម គឺត្រូវធ្វើការងារក្រុមតូចៗ ដើម្បីសម្រេចចិត្តធ្វើចំណាត់ថ្នាក់ចតុកោណ (មុខបួន) ទាំងនេះ ជា២ក្រុម និងដាក់ឈ្មោះឱ្យក្រុម ។ បន្ទាប់មកធ្វើចំណាត់ថ្នាក់ក្រុម នីមួយៗ ជា២អនុក្រុមទៀត និងដាក់ឈ្មោះឱ្យវា ។



ចម្លើយរំពឹងទុក :

**★ ការបែងចែកទី១**

- ក្រុមទី១ រូបដែលមានជ្រុងបួន មានមុំកែងនៅជ្រុងនីមួយៗ
- ក្រុមទី២ រូបដែលមានជ្រុង៤ មានមុំនៅតាមជ្រុងនានា ។

**★ ការបែងចែកទី២**

- ក្រុមទី១ អនុក្រុមទី១ : ការេ
- ក្រុមទី១ អនុក្រុមទី២ : ចតុកោណកែង ។
- ក្រុមទី២ អនុក្រុមទី១: ប្រលេឡូក្រាម/ចតុកោណព្នាយ
- ក្រុមទី២ អនុក្រុមទី២: ចតុកោណផ្សេងទៀត ។

## ប្រធានបទទី 3 ការបង្កើតល្បែងសិក្សា

## សកម្មភាព ៣.1 ល្បែងសិក្សា 60 នាទី

### ក.អត្ថន័យល្បែងសិក្សា

**សម្ភារ** : ផ្ទាំងក្រដាសធំ ប៊ិកហ្វឺត ។

អ្នកសម្របសម្រួល : ល្បែងសិក្សា គឺជាសកម្មភាពយ៉ាងមានប្រសិទ្ធភាព ដើម្បីឱ្យគ្រូអនុវត្តសម្រាប់សិស្សនៅគ្រប់កម្រិតថ្នាក់នៃសាលាបឋមសិក្សា ។ អ្នកសម្របសម្រួល ឱ្យក្រុមទាំងមូលផ្តល់មូលហេតុ ដែលពួកគាត់គិតថាល្បែងសិក្សាអាចមានប្រយោជន៍ ។ អ្នកសម្របសម្រួលម្នាក់ទៀត សរសេរគំនិតរបស់អ្នកចូលរួមនៅលើសន្លឹកក្រដាសធំមួយ ។

### ខ.ប្រភេទទូទៅនៃល្បែងសិក្សា

**សម្ភារ** : ល្បែងបង្ហាញ : ប័ណ្ណលេខពី ១ ដល់ ១០ ប័ណ្ណពាក្យពីមួយដល់ដប់ ។

អ្នកសម្របសម្រួល : មានល្បែងជាច្រើនត្រូវបានគេប្រើប្រាស់ ក្នុងការសិក្សានៅក្នុងសាលារៀនពាសពេញពិភពលោក ប៉ុន្តែល្បែងដែលប្រសើរបំផុត សម្រាប់យើងនៅកម្ពុជា គឺល្បែងដែល :

- កុមាររៀនបានច្រើន
- កុមារចូលចិត្តលេងល្បែងនោះ និងរៀនសូត្រ
- ល្បែងដែលមានតម្លៃថោក ហើយងាយប្រើប្រាស់
- សម្ភារងាយៗអាចប្រើប្រាស់បានដើម្បីបង្កើតល្បែងសិក្សាច្រើនប្រភេទ។

អ្នកសម្របសម្រួល : ចំណុចចុងក្រោយនេះគឺសំខាន់ណាស់ពីព្រោះសម្ភារ មួយចំនួនដែលយើងនឹងផលិត នៅថ្ងៃនេះអាចយកទៅប្រើប្រាស់បានច្រើនដង ដោយគ្រូ និងសិស្សគ្រាន់តែយកទៅបង្កើតជារបៀបថ្មីលើសម្ភារនោះតែប៉ុណ្ណោះ ។

អ្នកសម្របសម្រួលហៅគ្រូមួយក្រុមដែលមានគ្នាប្រាំមួយ ឬ ប្រាំពីរនាក់ឡើងមកខាងមុខលេងល្បែង ។ អ្នកចូលរួមដទៃទៀតគួរបង្កើតជារង្វង់មួយនៅជុំវិញអ្នកលេង ដើម្បីអាចមើលឃើញអ្វីដែលគេកំពុងតែលេង ។

អ្នកសម្របសម្រួលនិយាយទៅកាន់ក្រុមនោះថា : យើងនឹងឃើញនូវរបៀបផ្សេងៗជាច្រើននៃល្បែងសិក្សាដែលទាក់ទងគណិតវិទ្យា និងភាសាខ្មែរ ។

**ទី១** : អ្នកសម្របសម្រួលផ្តល់សម្ភារល្បែងសិក្សាឱ្យសិក្ខាកាមលេងតាមការយល់ឃើញរបស់ពួកគេ ។

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| មួយ | ពីរ | បី | បួន | ប្រាំ | ប្រាំមួយ | ប្រាំពីរ | ប្រាំបី | ប្រាំបួន | ដប់ |

**តើលោក/លោកស្រី អាចពិពណ៌នាការរៀបចំសកម្មភាពនេះយ៉ាងដូចម្តេច?**

ចម្លើយរំពឹងទុក : *ការដាក់ប័ណ្ណ ដែលដូចគ្នាជាមួយគ្នា ទៅតាមប្រភេទក្រុមខុសៗគ្នា ទៅតាមលក្ខណៈ ឬច្បាប់ និងដាក់ឈ្មោះក្រុមផ្សេងៗគ្នា (**ចំណែកថ្នាក់**)* ។

**ទី2 :** អ្នកសម្របសម្រួលឱ្យសិក្ខាកាមរកវិធីផ្សេងទៀត ដោយអាចរៀបប័ណ្ណចំនួនទាំងអស់ពីលំដាប់ទី១ដល់ទី១០ ហើយសួរសិក្ខាកាមក្នុងក្រុមតូចៗថា : **តើលោក/ លោកស្រី អាចពិពណ៌នាការរៀបចំសកម្មភាពនេះ យ៉ាងដូចម្តេច ?**

ចម្លើយរំពឹងទុក : *ការដាក់ប័ណ្ណទៅតាមលំដាប់ត្រឹមត្រូវ (**លំដាប់**)* ។

**ទី3 :** អ្នកសម្របសម្រួលឱ្យសិក្ខាកាមរកវិធីផ្សេងទៀត ដោយអាចរៀបផ្គូផ្គងប័ណ្ណលេខនីមួយៗ ជាមួយប័ណ្ណពាក្យ ហើយសួរសិក្ខាកាមក្នុង ក្រុមតូចៗថា: **តើលោក/លោកស្រី អាចពិពណ៌នាការរៀបចំ សកម្មភាពនេះយ៉ាងដូចម្តេច ?**

ចម្លើយរំពឹងទុក : *ការដាក់ប័ណ្ណដែលមានន័យដូចគ្នាជាមួយគ្នាជាគូៗ ឬសម្រេចចិត្តថា តើប័ណ្ណណាខ្លះនៅក្នុងក្រុមដែលមិនត្រូវជាមួយប័ណ្ណផ្សេងទៀត (**ផ្គូផ្គង**)* ។

អ្នកសម្របសម្រួលប្រាប់ឱ្យអ្នកចូលរួមទាំងអស់ត្រឡប់ទៅកាន់កន្លែងដើមវិញ ។

អ្នកសម្របសម្រួល : សរុបប្រភេទល្បែងដែលបានលេងមាន ៣ ប្រភេទ ដូចតារាងខាងក្រោម :

| **ការផ្គូផ្គង** | **ការរៀបតាមលំដាប់** (លំដាប់/ការរៀបលំនាំគំរូ) | **ការធ្វើចំណែកថ្នាក់** |
|---|---|---|

អ្នកសម្របសម្រួល : **តើល្បែងនេះផ្តល់ចំណេះដឹង និងបំណិនអ្វីខ្លះដល់សិស្ស? តើល្បែងនេះសមស្របនឹងថ្នាក់ណា?**

ចម្លើយរំពឹងទុក : *ចំណេះដឹងអំពីការរាប់ចំនួន១-១០ អានឈ្មោះចំនួន១-១០ ធ្វើការងាររួមគ្នា ពន្យល់គំនិតពួកគេ ស្តាប់យោបល់អ្នកផ្សេង និយាយ ។ល ។ ល្បែងនេះសមស្របនឹងកុមារថ្នាក់ទី១* ។

អ្នកសម្របសម្រួល : ការយល់ពី**បញ្ញត្តិ**នៅក្នុងល្បែងនោះគឺសំខាន់ណាស់ ។ ប្រសិនបើគ្រូបង្រៀនយល់ពី **បញ្ញត្តិ** នេះ មានន័យថាពួកគេអាចប្រើល្បែងប្រភេទតែមួយបានគ្រប់កម្រិតថ្នាក់ ដោយគ្រាន់តែផ្លាស់ប្តូរខ្លឹមសារឱ្យស្របទៅតាមកម្រិតថ្នាក់តែប៉ុណ្ណោះ ។



## សកម្មភាព 3.2 ការបង្ហាញល្បែងសិក្សាគណិតវិទ្យា 60 នាទី

**សម្ភារ** : ល្បែងសម្រាប់បង្ហាញ ។

អ្នកសម្របសម្រួលពន្យល់អំពីវិធីធ្វើបង្ហាញ និងវិធីដែលសិក្ខាកាមនឹងប្តូរពីទីតាំងមួយទៅទីតាំងមួយទៀត នៅពេលដែលកណ្តឹងរោទិ៍ឡើង (ទី១→ទី២ ទី២→ទី៣ ទី៣→ទី១ ។ល ។) រហូតដល់ពួកគាត់បានចូលរួមនៅក្នុងការធ្វើបង្ហាញទាំង៣ ។

# សកម្មភាពលេងល្បែង




អ្នកសម្របសម្រួលបែងចែកសិក្ខាកាមជា៣ក្រុម ។ អ្នកសម្របសម្រួល៣នាក់ធ្វើការបង្ហាញអំពីល្បែងសិក្សានៅតាមកន្លែងបីខុសៗគ្នា ។ ក្រុមទី១អ្នកសម្របសម្រួលម្នាក់បង្ហាញនូវល្បែងសិក្សាជាច្រើនអំពីគណិតវិទ្យា ដោយផ្អែកលើបញ្ញត្តិការរៀបតាម**លំដាប់** ។ ក្រុមទី២អ្នកសម្របសម្រួលម្នាក់ទៀតបង្ហាញល្បែងសិក្សា ដោយផ្អែកលើបញ្ញត្តិនៃ **ការផ្គូផ្គង** ។ ក្រុមទី៣ អ្នកសម្របសម្រួលម្នាក់ទៀតបង្ហាញនូវល្បែងសិក្សា ដោយផ្អែកលើបញ្ញត្តិនៃ ការធ្វើ**ចំណែកថ្នាក់** ។ ក្រុមនីមួយៗនៃសិក្ខាកាមចាប់ផ្តើមនៅកន្លែងមួយដោយធ្វើការសង្កេត និងចូលរួមលេងល្បែង ។បន្ទាប់ពីរយៈពេល១៥នាទីមក អ្នកសម្របសម្រួលម្នាក់ធ្វើសញ្ញាឱ្យឮៗ ហើយក្រុមនីមួយៗត្រូវទៅកាន់កន្លែងមួយទៀត ។ រយៈពេល ៤៥ នាទីមកក្រុមទាំងអស់នឹងបានបញ្ចប់កន្លែងធ្វើ ថ្នាក់បង្ហាញទាំង ៣ ។

★ បន្ទាប់ពីសិក្ខាកាមបង្ហាញល្បែងនីមួយៗរួចមក អ្នកសម្របសម្រួលសួរ :

- **តើល្បែងនេះពង្រឹងបន្ថែមចំណេះដឹង ឬ បំណិនអ្វីខ្លះ ?**
- **តាមការប៉ាន់ស្មាន តើថ្នាក់ទីប៉ុន្មានដែលសមស្របនឹងល្បែងនេះ ?**
- **តើមានប្រភេទល្បែងអ្វីផ្សេងទៀតដែលអាចលេងដោយប្រើសម្ភារទាំងនេះ ?**

***ការសង្ខេបអំពីល្បែងគណិតវិទ្យា***

| បញ្ញត្តិ | ឧទាហរណ៍ |
|---|---|
| **ការរៀបតាមលំដាប់** | ១. ដ្យាក្រាមចំនួន និងលេខ (ដ្យាក្រាម : ប័ណ្ណតាមចំនួន)<br>២. ការប្រៀបធៀបវត្ថុដែលមានប្រវែងខុសគ្នា (ចំរៀកក្រដាស)<br>៣. ឯកតារង្វាស់ប្រវែងចម្រុះ (ប័ណ្ណ) |
| **ការផ្គូផ្គង** | ១. ប្រភាគ ភាគរយ និងទសភាគ ដោយប្រើរូបភាព (ប័ណ្ណ)<br>២. ចំនួនពី ១ ដល់ ១០ ដោយប្រើដ្យាក្រាម និងលេខ<br>៣. សរសេរចំនួនសមមូល ដោយប្រើឯកត្តារង្វាស់ |
| **ការធ្វើចំណែកថ្នាក់** | ១. រាងធរណីមាត្រ<br>២.ចំនួនជាពហុគុណនៃ១០ និងចំនួនមិនមែនជាពហុគុណនៃ១០ ចំនួនការេ និងមិនមែនការេ ចំនួនសេស និងចំនួនគូ (ប័ណ្ណ)<br>៣. អក្សរកាត់នៃឯកតារង្វាស់ ប្រវែង ទម្ងន់ ចំណុះ និងផ្ទៃ (ប័ណ្ណ) |

## សកម្មភាព ៣.៣ ការបង្ហាញល្បែងសិក្សាភាសា 60 នាទី

**សម្ភារ** : ល្បែង សម្រាប់បង្ហាញ ។

ការបង្ហាញត្រូវអនុវត្តតាមដំណើរការដូចគ្នានឹងសកម្មភាពខាងដើម ។
អ្នកសម្របសម្រួលបែងចែកសិក្ខាកាមជា៣ក្រុម ។ អ្នកសម្របសម្រួល៣នាក់ធ្វើការបង្ហាញអំពីល្បែងសិក្សានៅ តាមកន្លែងបីខុសៗគ្នាក្នុងកន្លែងបំប៉ន ។ក្រុមទី១អ្នកសម្របសម្រួលម្នាក់បង្ហាញល្បែងសិក្សាមួយចំនួននៅក្នុងភាសាខ្មែរ ដោយផ្អែកលើបញ្ញត្តិនៃការរៀបដាក់**តាមលំដាប់**។ ក្រុមទី២ អ្នកសម្របសម្រួលម្នាក់ទៀតបង្ហាញល្បែងសិក្សាដោយផ្អែក លើបញ្ញត្តិនៃ**ការផ្គូផ្គង**។ ក្រុមទី៣អ្នកសម្របសម្រួលម្នាក់ទៀតបង្ហាញល្បែងសិក្សាដោយផ្អែកលើបញ្ញត្តិនៃការធ្វើ**ចំណែក ថ្នាក់**។ ក្រុមនីមួយៗចាប់ផ្តើមលេងល្បែង ។បន្ទាប់ពីរយៈពេល២០នាទីមកអ្នកសម្របសម្រួលម្នាក់ចុចកណ្តឹងហើយក្រុមនីមួយៗត្រូវចូលទៅកន្លែងបន្ទាប់ទៀត។ បន្ទាប់ពីរយៈពេល១ម៉ោងមកក្រុមទាំងអស់នឹងបានបញ្ចប់កន្លែងធ្វើថ្នាក់បង្ហាញទាំង៣។

★ បន្ទាប់ពីសិក្ខាកាមបង្ហាញល្បែងនីមួយៗរួចមកអ្នកសម្របសម្រួលសួរអ្នកចូលរួម :

- **តើល្បែងនេះពង្រឹងបន្ថែមចំណេះដឹង ឬ បំណិនអ្វីខ្លះ ?**
- **តាមការប៉ាន់ស្មាន តើថ្នាក់ទីប៉ុន្មានដែលសមស្របនឹងល្បែងនេះ ?**
- **តើមានប្រភេទល្បែងអ្វីផ្សេងទៀតដែលអាចលេងដោយប្រើសម្ភារទាំងនេះ ?**

***ការសង្ខេបអំពីល្បែងភាសា***

| **បញ្ញត្តិ** | **ឧទាហរណ៍** |
|---|---|
| **ការរៀបដាក់តាមលំដាប់** | ១. ថ្ងៃនៃសប្តាហ៍ និងថ្ងៃនេះ/ថ្ងៃស្អែក/ថ្ងៃម្សិលមិញ ។ល។ (ប័ណ្ណ)<br>២.រៀបចំពាក្យច្របល់ឱ្យក្លាយជាប្រយោគ (រួមទាំង វណ្ណយុត្តិ) (ប័ណ្ណ)<br>៣. លំដាប់អក្ខរក្រម (ប័ណ្ណ) |
| **ការផ្គូផ្គង** | ១. ពាក្យ និងរូបភាពអំពីសមាជិកគ្រួសារ (ប័ណ្ណ)<br>២. រូបភាព និងប្រយោគ (ប័ណ្ណ)<br>៣. សទិសសូរ (ប័ណ្ណ) |
| **ការធ្វើចំណែកថ្នាក់ប្រភេទ** | ១. នាម កិរិយាស័ព្ទ គុណនាម ឈ្នាប់ ពេល (ប័ណ្ណ)<br>២. ពាក្យចាប់ផ្តើមដោយកន្សោមព្យញ្ជនៈពីរខុសគ្នា (ប័ណ្ណ)<br>៣. ប្រភេទចំណីអាហារផ្សេងៗគ្នា (បន្លែ ផ្លែឈើ សាច់ អង្ករ) (ប័ណ្ណ) |

**សន្និដ្ឋាន** : អ្នកសម្របសម្រួលសួរសិក្ខាកាម **តើល្បែងលេងទាំង ២មុខវិជ្ជាដែលបានលេងមានការពាក់ព័ន្ធសៀវភៅសិក្សា គោលរបស់ក្រសួងអប់រំ យុវជនន និងកីឡាយ៉ាងដូចម្តេច ?**

***ចម្លើយរំពឹងទុក:*** *ប្រើអត្ថបទនៅក្នុងសៀវភៅភាសាខ្មែរ សម្រាប់កាត់ពាក្យ និងប្រយោគ ជ្រើសរើសពាក្យពិបាក និងសរសេរនិយមន័យនៅលើប័ណ្ណ និងច្របល់វាចូលគ្នា ។ លេងល្បែងគណិតវិទ្យាដើម្បីហាត់រៀន អំពីប្រព័ន្ធចំនួនតម្លៃលេខ រង្វាស់ ធរណីមាត្រ ដោយប្រើខ្លឹមសារនៅក្នុងសៀវភៅអាន ។*

**សកម្មភាព 3.4 លំហាត់បង្កើតល្បែងសិក្សាគណិតវិទ្យា 60 នាទី**

**សម្ភារ :** សៀវភៅគណិតវិទ្យា ថ្នាក់ទី១-៦ ប័ណ្ណសម្រាប់ធ្វើល្បែង ហ្វឺត ខ្មៅដៃពណ៌ ឯកសារនៃសន្លឹកទម្រង់របាយការណ៍អំពីល្បែងសិក្សា ។

អ្នកសម្របសម្រួល :" លោកគ្រូ អ្នកគ្រូម្នាក់ៗនឹងធ្វើការងារតាមក្រុមកម្រិតថ្នាក់ ដើម្បីបង្កើតល្បែងសិក្សា**គណិតវិទ្យា** " ។ នៅពេលដែលគ្រូម្នាក់ៗបានធ្វើល្បែងរួចហើយ ត្រូវបង្ហាញពីរបៀបលេងជាមួយក្រុមរបស់ខ្លួន ឬ ទៅតាមក្រុមផ្សេងៗបើអាច ។

អ្នកសម្របសម្រួលពន្យល់ពីដំណាក់កាលដែលត្រូវធ្វើនៅក្នុងសកម្មភាពដូចខាងក្រោម :

១. អង្គុយនៅលើកន្ទេល ឬនៅជុំវិញតុតាមក្រុម តាមកម្រិតថ្នាក់ ។ ចែកសម្ភារតាមក្រុមប្រហែលជា ២០ប័ណ្ណ សម្រាប់គ្រូមួយក្រុមៗ

២. គ្រូតាមក្រុមអានសៀវភៅគណិតវិទ្យា ហើយជ្រើសរើសមេរៀនមួយ ដើម្បីបង្កើតល្បែងសិក្សា

៣. គ្រូសម្រេចចិត្តអំពីប្រភេទល្បែងដែលពួកគាត់ធ្វើ និងអ្វីដែលត្រូវសរសេរនៅលើប័ណ្ណ

៤. តាមក្រុមសាកល្បងលេងល្បែងដែលបានបង្កើត

៥. គ្រូបង្កើតជាក្រុមដែលមានគ្នា ៤ ឬ ៥ នាក់ និងចែកវេនគ្នាលេងល្បែងផ្សេងៗគ្នា

៦. គ្រូម្នាក់ៗបំពេញសន្លឹករបាយការណ៍អំពីប្រភេទល្បែងដែលខ្លួនបានធ្វើ និងសរសេរសេចក្តីសង្ខេប រួចរក្សាទុកជាមួយល្បែងសិក្សានោះ សម្រាប់លេងពេលក្រោយទៀត ។

**ទម្រង់របាយការណ៍អំពីល្បែងសិក្សា**

| | |
|---|---|
| **ឈ្មោះគ្រូ** | : |
| **មុខវិជ្ជា** | : ភាសាខ្មែរ គណិតវិទ្យា សិក្សាសង្គម វិទ្យាសាស្ត្រងអនុវត្ត |
| **ប្រធានបទ** | : |
| **សមស្របកម្រិតថ្នាក់** | : ថ្នាក់ទី ១, ២, ៣, ៤, ៥, ៦ |
| **ប្រភេទល្បែងសិក្សា** | : ផ្គូផ្គង លំដាប់លំដោយ ចំណែកថ្នាក់ |

**ពណ៌នាយ៉ាងសង្ខេបពីការលេងល្បែង :**

**ពង្រឹងសមត្ថភាពសំខាន់ៗរបស់សិស្ស និង អនុវត្ត :**

## សកម្មភាព 3.5 លំហាត់បង្កើតល្បែងសិក្សាភាសា 60 នាទី

**សម្ភារៈ** : សៀវភៅភាសារបស់ក្រសួងអប់រំ យុវជន និងកីឡា ប័ណ្ណក្រដាស សម្រាប់ធ្វើល្បែង ប៊ិចហ្វឺត ខ្មៅដៃពណ៌ ។

អ្នកសម្របសម្រួល : លោកគ្រូ អ្នកគ្រូម្នាក់ៗធ្វើការងារតាមក្រុមកម្រិតថ្នាក់ដើម្បីបង្កើតល្បែងសិក្សា**ភាសាខ្មែរ** ។ នៅពេលដែលគ្រូម្នាក់ៗបានធ្វើល្បែងរួចហើយ ត្រូវបង្ហាញពីរបៀបលេងជាមួយគ្រូដទៃទៀតមកពីកម្រិតថ្នាក់ដូចគ្នា ។

អ្នកសម្របសម្រួលពន្យល់ពីដំណាក់កាលដែលពួកគាត់ត្រូវធ្វើនៅក្នុងសកម្មភាពដូចខាងក្រោម :

១. អង្គុយនៅលើកន្ទេល ឬ នៅជុំវិញតុតាមក្រុមកម្រិតថ្នាក់ ។ ចែកសម្ភារដល់គ្នាប្រហែលជា ២០ ប័ណ្ណក្រដាសសម្រាប់គ្រូចូលរួមម្នាក់ៗ

២. គ្រូតាមក្រុមអានសៀវភៅភាសា ហើយជ្រើសរើសរើសមេរៀនមួយ ដើម្បីបង្កើតល្បែងសិក្សា

៣. គ្រូសម្រេចចិត្តអំពីប្រភេទល្បែងដែលពួកគាត់នឹងធ្វើ និងអ្វីដែលត្រូវសរសេរនៅលើប័ណ្ណ

៤. គ្រូធ្វើល្បែង និងលេងវាដោយខ្លួនឯង ដើម្បីពិនិត្យមើលវា

៥. គ្រូបង្កើតជាក្រុមដែលមានគ្នា បួន ឬ ប្រាំនាក់ និងចែករវេនគ្នាលេងល្បែងផ្សេងៗគ្នា

៦. គ្រូម្នាក់បំពេញសន្លឹករបាយការណ៍អំពីប្រភេទល្បែងដែលខ្លួនបានធ្វើ និងសរសេរសេចក្តីសង្ខេបអំពីវា រួចរក្សាទុកជាមួយល្បែងសិក្សានោះ សម្រាប់លេងពេលក្រោយទៀត ។

**ទម្រង់របាយការណ៍អំពីល្បែងសិក្សា**

**ឈ្មោះគ្រូ** :

**មុខវិជ្ជា** : ភាសាខ្មែរ គណិតវិទ្យា សិក្សាសង្គម វិទ្យាសាស្ត្រអនុវត្ត

**ប្រធានបទ** :

**សមស្របកម្រិតថ្នាក់** : ថ្នាក់ទី ១, ២, ៣, ៤, ៥, ៦

**ប្រភេទល្បែងសិក្សា** : ផ្គូផ្គង លំដាប់លំដោយ ចំណែកថ្នាក់

**ពណ៌នាយ៉ាងសង្ខេបពីការលេងល្បែង :**

**ពង្រឹងសមត្ថភាពសំខាន់ៗរបស់សិស្ស និង អនុវត្ត :**

**សកម្មភា** ... **នាទី**

**សម្ភារៈ** : សៀវភៅកំណត់ត្រាគ្រូ ផ្ទាំងក្រដាសធំ ប៊ិចហ្វឺត ។

អ្នកសម្របសម្រួលនិយាយថា មានកិច្ចការគ្រូបួន និយាយអំពីល្បែងសិក្សានៅក្នុងឯកសារ ប្រសិទ្ធភាពនៃការបង្រៀន និងរៀន ។ អ្នកសម្របសម្រួលប្រាប់អ្នកចូលរួមឱ្យអានកិច្ចការនេះនៅក្នុងសៀវភៅកំណត់ត្រាគ្រូ ។ ប្រសិនបើអ្នកចូលរួមពុំមានសំណួរទេ នោះអ្នកសម្របសម្រួលត្រូវផ្ទៀងផ្ទាត់មើលការយល់របស់អ្នកចូលរួមតាមការសួរសំណួរដល់ពួកគាត់ :

| **អ្នកសម្របសម្រួលសួរគ្រូ** | **ចម្លើយរំពឹងទុក** |
|---|---|
| តើសម្ភារដែលអ្នកប្រើសម្រាប់ធ្វើល្បែងតាមរយៈអ្វីខ្លះ? | តាមរយៈប័ណ្ណក្រដាស ក្ដារបន្ទះ ឬ វត្ថុផ្សេងៗទៀត |
| តើអ្នកសរសេរអ្វីនៅក្នុងប្រអប់? | អ្វីដែលសរសេរដាក់នៅលើប័ណ្ណនីមួយៗក្នុងល្បែងរបស់គាត់ |
| តើអ្នកអាចសរសេរអ្វីខ្លះជា "ចម្លើយសិស្ស"? | សរសេរពីការយល់ដឹងរបស់សិស្សអំពីល្បែង ( សមត្ថភាព លេង ឬ បញ្ហាណាមួយ ) |
| តើអ្នកអាចសរសេរអ្វីខ្លះជា "ការតាមដាន" | គ្រូអាចសរសេរ ប្រសិនបើល្បែងត្រូវបានប្រើម្ដងទៀត នៅតាមមុខវិជ្ជា ឬ មេរៀនផ្សេងៗទៀត |

ដើម្បីសរុបសកម្មភាពអំពីល្បែងសិក្សា អ្នកសម្របសម្រួលបង្ហាញបញ្ជីគំនិតដែលអ្នកចូលរួមផ្ដល់នៅក្នុងសកម្មភាពទី៣.១ ។ អ្នកសម្របសម្រួលសួរក្រែងមានមូលហេតុផ្សេងណាទៀត ដែលធ្វើឱ្យល្បែងសិក្សាមានប្រយោជន៍ដែលអ្នកចូលរួមចង់បន្ថែម ។ អ្នកសម្របសម្រួលទីពីរ សរសេរបន្ថែមនូវរាល់គំនិតថ្មីដែលមាន ។

*ចម្លើយរំពឹងទុកអំពីមូលហេតុធ្វើឱ្យល្បែងមានសារប្រយោជន៍ :*

- ធ្វើឱ្យកុមាររីករាយ និងបង្កើតបរិយាកាសរៀនសូត្រសប្បាយរីករាយ
- ឱ្យកុមារធ្វើការជាមួយគ្នា ពន្យល់អ្វីៗដល់គ្នាទៅវិញទៅមក និងពិភាក្សាគ្នាអំពីការរៀនសូត្ររបស់ពួកគេ
- ជួយពង្រឹងបន្ថែមដល់ការរៀនសូត្ររបស់កុមារ
- ជួយកុមារឱ្យអនុវត្តជាក់ស្ដែង និងប្រើប្រាស់ការយល់ដឹង
- ជួយកុមារឱ្យចេះពិចារណាដោយហ្មត់ចត់
- ជួយកុមារឱ្យចេះធ្វើការជាក្រុមជាមួយកុមារផ្សេងទៀត
- ជួយកុមារឱ្យរៀនធ្វើការងារដោយឯករាជ្យពីគ្រូ
- ផ្ដល់កិច្ចការ (ល្បែង) ដល់កុមារខ្លះសម្រាប់ធ្វើ នៅពេលដែលគ្រូធ្វើការងារជាមួយកុមារម្នាក់ៗ ឬ ជាមួយក្រុមពិសេស
- ល្អក្នុងការផ្ដល់ដល់កុមារដែលបញ្ចប់ការងារផ្សេងទៀតបានរហ័ស ។

## ប្រធានបទទី 4 ការប្រើប្រាស់ធនធានក្នុងថ្នាក់រៀនសិប្បនិម្មិត

### សកម្មភាព 4.1 ការបង្កើតបរិស្ថានថ្នាក់រៀនសិប្បនិម្មិត 30 នាទី

**សម្ភារ** : ផ្ទាំងក្រដាសធំ ប៊ិកហ្វឺត ។

អ្នកសម្របសម្រួល : គ្រូបង្រៀន គឺជាអ្នកគ្រប់គ្រងថ្នាក់រៀន ។ ការទទួលខុសត្រូវរបស់គ្រូបង្រៀន គឺធ្វើការជាមួយសិស្សដើម្បីបង្កើតបរិស្ថាន "សំបូរបែប" សម្រាប់ការសិក្សា ។ នេះមានន័យថាថ្នាក់រៀនគួរមានផាសុកភាព (ស្អាត) ដើម្បីទាក់ទាញទឹកចិត្ត និងជាកន្លែងជំរុញឱ្យមានការរៀនសូត្រ ។ គោលបំណងគឺចង់ឱ្យកុមារមានការសប្បាយរីករាយមកសាលារៀនជារៀងរាល់ថ្ងៃ និងអាចស្វែងរកអ្វីៗដែលថ្មីដើម្បីមើល និងសម្រាប់គិត ។

អ្នកសម្របសម្រួល : បរិស្ថាន "សំបូរបែប" មិនមែនមានន័យថា គ្រូបង្រៀនត្រូវតែចំណាយប្រាក់ច្រើនទៅលើការតុបតែងនោះទេ ។ បន្ទប់រៀនគួរមានសម្ភារដែលជំរុញការសិក្សា "សំបូរបែប" ។ សម្ភារមួយចំនួនអាចទិញដោយប្រើថវិកា PAP (ឧ.តារាងអក្ខរក្រម តារាងចំនួន ផែនទី ។ល។) ។ សម្ភារមួយចំនួនទៀតអាចផ្តល់ដោយក្រសួងអប់រំ យុវជន និងកីឡា ឬ តាមរយៈកម្មវិធីផ្សេងៗរបស់រដ្ឋាភិបាល (ឧ.ការអប់រំអំពីមីន ហ៊ីវ/អេដស៍ អាហារូបត្ថម្ភ ការអប់រំ សម្រាប់ទាំងអស់គ្នា ។ល។) និងសម្ភារផ្សេងៗទៀត ដែលអាចរៀបចំដោយគ្រូបង្រៀន និងសិស្ស ។

អ្នកសម្របសម្រួល : **តើគ្រូ និងសិស្សត្រូវធ្វើអ្វីខ្លះដើម្បីបង្កើតបរិស្ថានថ្នាក់រៀនសំបូរបែប?**

អ្នកសម្របសម្រួល ម្នាក់ទៀតសរសេរគំនិតរបស់សិក្ខាកាមនៅលើផ្ទាំងក្រដាសធំ ។





***ចម្លើយរំពឹងទុក ...***

- តាំងបង្ហាញគំរូនៃសំណេរ ឬ គំនូរ ឬ ហត្ថកម្មរបស់សិស្ស
- ប្រើប្រាស់សម្ភារក្នុងការបង្កើតជ្រុងបន្ទប់រៀន ឬ ជ្រុងបណ្ណាល័យ
- ឧបករណ៍សិប្បកម្ម នេសាទ កសិកម្មដែលផលិតនៅក្នុងមូលដ្ឋាន និងសម្ភារផ្ទះបាយ (សំណាញ់ ឧបករណ៍ផ្សេងៗ កន្ត្រក...)
- សម្ភារពីបរិស្ថានដូចជា ការរៀបតាំងពីស្លឹកឈើ ផ្កា សត្វល្អិត...
- ការពិសោធងាយៗ សម្រាប់កុមារសង្កេត និងចងក្រងជាឯកសារ (ការបណ្តុះគ្រាប់ ឬ ការដាំកូនរុក្ខជាតិនៅ ក្នុងទឹក និងក្នុងដើង កូនក្អុក សួនសត្វល្អិត ផ្លែឈើដែលពុកផុយ...)

អ្នកសម្របសម្រួល ៖ គ្រូបង្រៀនអាចស្វែងរកធនធានគ្រប់ទីកន្លែង ដូចជាទស្សនាវដ្ដី និងកាសែតចាស់ៗ ផ្ទាំងរូបភាពប័ណ្ណផ្សព្វផ្សាយ សម្ភារទាំងនេះតែងតែជាការចាប់អារម្មណ៍របស់សិស្ស ។ ផ្ទាំងរូបភាពដែលផុតកាលបរិច្ឆេទ ឬ ឈប់ប្រើប្រាស់របស់ការប្រជុំ និងព្រឹត្តិការណ៍ ឬ យុទ្ធនាការបង្កើនការយល់ដឹងរបស់រដ្ឋាភិបាលដែលមានរូបភាព និងអត្ថបទពិតជាក់ស្ដែងគួរឱ្យចាប់អារម្មណ៍ សម្រាប់យកមកធ្វើការពិភាក្សា និងការវិភាគ ។ គ្រូបង្រៀនអាចធ្វើការជាមួយសិស្ស ដើម្បីឱ្យតម្លៃទៅលើតារាងផ្សេងៗ និងផ្ទាំងរូបភាពចាស់ៗ ដោយការដាក់ស្លាកឈ្មោះ ដាក់ចំណងជើង ។ល។ **គ្រូ និងសិស្សមិនគួររៀបចំតាំងបង្ហាញ រួចហើយបំភ្លេចចោលសម្ភារនោះទេ** ។ សម្ភារទាំងនោះអាចប្រើប្រាស់សម្រាប់ការបង្រៀន និងរៀនទៅក្នុងមេរៀនទាំងឡាយ ។សម្ភារទាំងនេះគួរតែមានការផ្លាស់ប្ដូរបន្ទាប់ពីដាក់តាំងបានរយៈពេលមួយ ឬពីរខែដើម្បីរក្សាចំណាប់អារម្មណ៍របស់សិស្ស ។

**សកម្មភាព 4.2 ការសាកល្បងកម្មវិធីសិក្សា** **15 នាទី**

**សម្ភារ** ៖ តារាងអំពីភាសា និងការរៀនសូត្រអំពីភាសា សៀវភៅសិក្សាគោលគណិតវិទ្យា ។

អ្នកសម្របសម្រួលសួរ ៖ **នៅសាលារៀន តើមានមុខវិជ្ជាអ្វីខ្លះដែលសិស្សរៀនដោយប្រើភាសា ?**

*ចម្លើយរំពឹងទុក* ៖ គ្រប់មុខវិជ្ជាទាំងអស់ ពីព្រោះនៅក្នុងមុខវិជ្ជាទាំងអស់កុមាររៀនស្តាប់ និយាយ អាន និងសរសេរ ។ អ្នកសម្របសម្រួលយល់ស្រប និងនិយាយថា គ្រប់មេរៀនទាំងអស់ទោះបីមុខវិជ្ជាណាក៏ដោយក៏ប្រើភាសាដែរ ។ អ្នកសម្របសម្រួលលើកសៀវភៅគណិតវិទ្យា ហើយចង្អុលបង្ហាញថា **តើសិស្សអាចអានលើការណែនាំដើម្បីធ្វើលំហាត់ និងមានការយល់ដឹងលើចំណោទនៅក្នុងសៀវភៅដោយសារអ្វី ?**

បន្ទាប់មកអ្នកសម្របសម្រួល ៖ អ្នកអប់រំហៅការប្រើភាសាបែបនេះថា **"*ភាសានៅក្នុងកម្មវិធីសិក្សា*"** ។

អ្នកសម្របសម្រួលបិទតារាងនៅលើក្តារខៀន (ដូចតារាងខាងក្រោម តែបិទកូឡោនទីពីរ )។ ដោយបញ្ជាក់ថា ៖ យើងគប្បីយល់ច្បាស់ខ្លឹមសារឃ្លាទាំង ៣ នេះ ៖

- រៀនភាសា
- រៀនអំពីភាសា
- រៀនតាមរយៈភាសា

អ្នកសម្របសម្រួលសួរ ៖ **តើអ្នកគិតថាឃ្លានីមួយៗនេះមានន័យដូចម្តេច?** អ្នកសម្របសម្រួលប្រាប់អ្នកចូលរួមឱ្យពិភាក្សាពីអត្ថន័យរបស់ឃ្លាទាំងបីជាមួយអ្នកដែលអង្គុយជិត និងបន្ទាប់មកត្រូវផ្តល់យោបល់ ។ អ្នកសម្របសម្រួលជួយអ្នកចូលរួមឱ្យសរសេរអត្ថន័យ និងបើកក្រដាសគ្របចេញនៅពេលដែលពួកគាត់បញ្ចប់គំនិតហើយ ។

**តារាងអំពីភាសា និងការរៀនសូត្រអំពីភាសា**

| **ខ្លឹមសារ** | **អត្ថន័យ** |
|---|---|
| រៀនភាសា | ការរៀនពាក្យថ្មីៗ (តាមរយៈ ស្តាប់ និយាយ អាន សរសេរ) |
| រៀនអំពីភាសា | ការរៀនពីរចនាសម្ព័ន្ធភាសា ក្បួន វេយ្យាករណ៍ របៀបប្រើប្រាស់ភាសាដើម្បីបង្ហាញពីអត្ថន័យ |
| រៀនតាមរយៈភាសា | ការប្រើភាសាជាមធ្យោបាយក្នុងការពន្យល់ និងការស្វែងយល់គំនិត និងព័ត៌មាន ពីមុខវិជ្ជាផ្សេងៗជាច្រើនទៀត ។ |

អ្នកសម្របសម្រួលសង្ខេបដោយសួរថា ៖ ***តើមានន័យដូចម្តេច ពេលដែលខ្ញុំនិយាយថា " រាល់មុខវិជ្ជា គឺជាមេរៀនទាក់ទងនឹងភាសា ?***

ចម្លើយរំពឹងទុក ៖ *នៅក្នុងមេរៀននីមួយៗ គ្រូ និងសិស្សប្រើប្រាស់ភាសាក្នុងការរៀនសូត្រ ។ ជានិច្ចកាលភាសាដើរទន្ទឹមគ្នាជាមួយនឹងការបង្រៀន និងរៀន ។*

**សកម្មភាព 4.3 ការប្រើផ្ទាំងរូបភាព ( បំណិនស្តាប់ និងបំណិននិយាយ )** 45 នាទី

**សម្ភារ** ៖ ផ្ទាំងរូបភាព ៣ ឬ ៤ផ្ទាំង ដែលជាទូទៅមាននៅក្នុងថ្នាក់រៀន ដូចជា ៖ ការចុះឈ្មោះចូលរៀន ការអប់រំសម្រាប់ទាំងអស់គ្នា ចំណីអាហារ និងអាហារូបត្ថម្ភ អនាម័យ និងសុខភាព គ្រោះថ្នាក់ គ្រាប់មីន សត្វ និងរុក្ខជាតិ ... ។

**ការប្រើប្រាស់ផ្ទាំងរូបភាពសម្រាប់ការបង្រៀន**

អ្នកសម្របសម្រួល ៖ ផ្ទាំងរូបភាព ឬ អត្ថបទ គឺជាសម្ភារបង្រៀនដ៏មានប្រយោជន៍ ។ វាមានការងាយស្រួលដល់គ្រូបង្រៀនក្នុងការសួរសំណួរអំពីសម្ភារនេះដែល ជាឱកាសមួយសម្រាប់កុមារអនុវត្ត បំណិន ស្តាប់ និងនិយាយ ។

អ្នកសម្របសម្រួលមានផ្ទាំងរូបភាពពិតខ្លះបិទលើក្តារខៀន ដែលនឹងត្រូវប្រើក្នុងកិច្ចការរបស់អ្នកចូលរួម ខាងក្រោម ។ អ្នកសម្របសម្រួលចង្អុលទៅកាន់ផ្ទាំងរូបភាពពិតមួយ រួចសួរអ្នកចូលរួមនូវកម្រិតសំណួរខុសៗគ្នាជាច្រើនអំពី ផ្ទាំងរូបភាពដូចជា ៖

| **ឧទាហរណ៍សំណួរ** | **ឧទាហរណ៍ចម្លើយ** | **កម្រិតសំណួរ** |
|---|---|---|
| តើអ្នកឃើញអ្វីខ្លះនៅក្នុងរូបភាព? | ខ្ញុំអាចមើលឃើញ... | ចងចាំ |
| តើប៉ូស្ទ័រនេះបង្ហាញពីអ្វី ? ( ផ្ទាំងរូបភាព ) | បង្ហាញពី... | យល់ដឹង |
| តើអ្នកគិតថាហេតុអ្វី...? | ខ្ញុំគិតថា...ពីព្រោះ... | ពិចារណាហ្មត់ចត់ |
| តើអ្វីដែលអ្នកចូលចិត្តបំផុតអំពី...? | ខ្ញុំចូលចិត្ត...ពីព្រោះ... | ពិចារណាហ្មត់ចត់ |

បន្ទាប់មកអ្នកសម្របសម្រួលបែងចែកសិក្ខាកាមជាក្រុមតូចៗដោយក្រុមនីមួយៗទទួលបានផ្ទាំងរូបភាពមួយ ។ មនុស្សម្នាក់ៗនៅក្នុងក្រុមទទួលបានក្រដាសពាសន្លឹក សម្រាប់សរសេរសំណួរចំនួន៣ទាក់ទងនឹងផ្ទាំងរូបភាព ។ ប្រធានក្រុមត្រូវប្រមូលសំណួរទាំងអស់ដោយជ្រើសរើសសំណួរដែលដូចគ្នា និងខុសគ្នារួចបង្ហាញទៅកាន់ថ្នាក់រៀនទាំងមូល ។

អ្នកសម្របសម្រួល ៖ គ្រូបង្រៀនក៏អាចប្រើផ្ទាំងរូបភាព សម្រាប់ល្បែងសិក្សាដូចជា ៖

- តើអ្នកអាចមើលឃើញអ្វីមួយនៅក្នុងផ្ទាំងរូបភាពដែលចាប់ផ្តើមដោយអក្សរ...?
- តើអ្នកអាចបិទស្លាកនេះនៅលើកន្លែងដែលត្រឹមត្រូវនៅលើផ្ទាំងរូបភាពបានឬទេ?
- តើអ្នកអាចមើលឃើញវត្ថុអ្វីខ្លះដែលធំបំផុតចំនួន៥នៅក្នុងផ្ទាំងរូបភាពឬទេ? ចូរដាក់ចំនួន ១ ២ ៣ ៤ និង៥ នៅលើវត្ថុដែលអ្នករកឃើញ ។
- តើអ្នកអាចរកឃើញវត្ថុចំនួនប៉ុន្មាននៅក្នុងផ្ទាំងរូបភាពដែលមានពណ៌បៃតង/ក្រហម/ស...?
- តើអ្នកអាចទស្សន៍ទាយមនុស្សនៅលើផ្ទាំងរូបភាពដែលគាត់កំពុងនិយាយបានឬទេ? ( ប្រើនិមិត្តសញ្ញាតាងសំដីនិយាយ 🗨 )

អ្នកសម្របសម្រួលសន្និដ្ឋានដោយនិយាយថា ៖ ផ្ទាំងរូបភាព អាចជាសម្ភារបង្រៀន និងរៀនផងអាចជាសម្ភារល្បែងសិក្សាផងដែរ ព្រោះល្បែងទាំងអស់នេះសុទ្ធតែមានប្រយោជន៍សម្រាប់ផ្តល់អ្វីមួយឱ្យសិស្សធ្វើ ប្រសិនបើពួកគេបញ្ចប់មេរៀនមុនម៉ោង ឬប្រសិនបើសិស្សមួយចំនួនបញ្ចប់កិច្ចការមុនសិស្សដទៃ ។

**សកម្មភាព 4.4 ការប្រើប្រាស់ផែនទី... ( ការអភិវឌ្ឍភាសានិយាយ ) 45 នាទី**

**សម្ភារ** ៖ ផែនទីសមស្របសម្រាប់កម្រិតថ្នាក់នីមួយៗ (ភូមិ ឃុំ ស្រុក ខេត្តក្នុងប្រទេសកម្ពុជា តំបន់ ពិភពលោក) ។ តារាងទី១ និយាយអំពីប្រភេទផែនទីខុសៗគ្នាសមស្របសម្រាប់កុមារប្រើតាមកម្រិតថ្នាក់ ។ តារាងទី២ រាយសកម្មភាពរៀនសូត្រដែល កុមារអាចធ្វើដោយពឹងផ្អែកទៅលើផែនទី ។

**ការប្រើប្រាស់ផែនទីសម្រាប់ការបង្រៀន**

*អ្នកសម្របសម្រួល ៖* ផែនទី គឺជាសម្ភារបង្រៀនដែលមានប្រយោជន៍ណាស់ ។ គ្រូបង្រៀនអាចប្រើប្រាស់ផែនទីជាប្រភពធនធានសម្រាប់ការសិក្សារបស់សិស្សក្នុងមុខវិជ្ជាភាសាខ្មែរ គណិតវិទ្យា និងសិក្សាសង្គម ។ ក្នុងខណៈពេលដែលរាងកាយសិស្សលូតលាស់ធំឡើងៗ ការយល់ដឹងរបស់ពួកគេក៏រីកលូតលាស់ផងដែរ ។ នៅក្នុងថ្នាក់ទី១ សិស្សផ្តោតទៅលើខ្លួនឯង គ្រួសារ និងលំនៅដ្ឋានរបស់ពួកគេ ។ នៅថ្នាក់ទី២ និងទី៣ សិស្សចាប់ផ្តើមគិត និងរៀនពីភូមិ ឃុំ/សង្កាត់ ស្រុក/ខណ្ឌ និងអាចរហូតដល់ខេត្តរបស់ពួកគេ ។ នៅក្នុងថ្នាក់កម្រិតខ្ពស់ជាងនេះ សិស្សរៀនអំពីខេត្ត/ក្រុង ប្រទេស តំបន់ របស់ពួកគេ និងពិភពលោក ។

អ្នកសម្របសម្រួល ៖ បិទតារាងដូចខាងក្រោមនៅលើក្តារខៀន និងឱ្យអ្នកចូលរួមបំពេញកូឡោនទី៣...។ **តើផែនទីប្រភេទអ្វីដែលកុមារគួររៀននៅកំរិតថ្នាក់?** អ្នកសម្របសម្រួលទី២ សរសេរគំនិតអ្នកចូលរួមនៅលើតារាង ។

| ថ្នាក់ទី | សិស្សផ្តោតទៅលើ | ផែនទី |
|---|---|---|
| ១ | ផ្ទះរបស់ខ្ញុំ សាលារៀនរបស់ខ្ញុំ ការធ្វើដំណើរទៅសាលារៀន | បន្ទប់រៀន សាលារៀន ផ្ទះ |
| ២ | ភូមិរបស់ខ្ញុំ ឃុំ/សង្កាត់របស់ខ្ញុំ | ឃុំ/សង្កាត់ ស្រុក/ខណ្ឌ |
| ៣ | ឃុំ/សង្កាត់របស់ខ្ញុំ ស្រុក/ខណ្ឌ | ឃុំ/សង្កាត់ ស្រុក/ខណ្ឌ ខេត្ត/ក្រុង |
| ៤ | ខេត្ត/ក្រុងខ្ញុំ | ខេត្ត/ក្រុង/ប្រទេសកម្ពុជា |
| ៥ | ប្រទេសរបស់ខ្ញុំ | ប្រទេសកម្ពុជា |
| ៦ | ប្រទេសខ្ញុំ ប្រទេសក្នុងតំបន់ | ប្រទេសកម្ពុជា ពិភពលោក អាស៊ីអាគ្នេយ៍ |

អ្នកសម្របសម្រួលនិយាយ ៖ មានប្រភេទសកម្មភាពរៀនសូត្រខុសៗគ្នាដែលគ្រូអាចផ្តល់ឱ្យកុមារធ្វើដោយពឹងផ្អែកលើផែនទី ។ កុមារត្រូវតែស្តាប់ដោយយកចិត្តទុកដាក់ចំពោះសំណួរគ្រូ និងបន្ទាប់មកពន្យល់ចម្លើយនោះឱ្យច្បាស់ដោយប្រើភាសារបស់ខ្លួនឯង។

អ្នកសម្របសម្រួលបិទ និងចង្អុលទៅផែនទី១ ឬ ២នៅលើក្តារខៀន និងសួរអ្នកចូលរួមក្នុងថ្នាក់ទាំងមូល ៖ សូមផ្តល់ជាសំណួរដែលកុមារអាចឆ្លើយដោយប្រើផែនទី? អ្នកសម្របសម្រួលទី២ កត់ត្រាចម្លើយអ្នកចូលរួមនៅលើក្រដាសផ្ទាំងធំមួយនៅពីក្រោមចំណងជើង **"សកម្មភាពរៀនសូត្រដោយប្រើផែនទី "** ។

***ចម្លើយរំពឹងទុក :***

-រកទីកន្លែងនៅលើផែនទី

-អធិប្បាយពីទីតាំង (ប្រើពាក្យខាងជើង ខាងត្បូង ខាងកើត ខាងលិច)

-អធិប្បាយទីតាំងនៃកន្លែងមួយទាក់ទងនឹងកន្លែងផ្សេងទៀត

-និយាយអំពីព្រំប្រទល់

-កំណត់ និងដាក់ឈ្មោះស្រុក/ខណ្ឌ ខេត្ត/ក្រុងប្រទេសនៅជាប់ព្រំប្រទល់

-និយាយអំពីដែនសមុទ្រ និងកោះ

-និយាយអំពីផ្លូវថ្នល់ និងទន្លេ ស្ទឹង ភ្នំ

-និយាយអំពីទីតាំង និងប្រៀបធៀបចម្ងាយ

-និយាយអំពីការធ្វើដំណើរពី ចំណុច១ ទៅចំណុច១ ទៀត ។

បន្ទាប់មកអ្នកសម្របសម្រួល បែងចែកអ្នកចូលរួមក្រុមតាមកម្រិតថ្នាក់ និងចែកផែនទីមួយដល់ក្រុមនីមួយៗ ។ សមាជិកក្រុមនីមួយៗ ទទួលបានក្រដាសពាសន្ទឹក និងសរសេរសំណួរបីអំពីផែនទី ។ ប្រធានក្រុមត្រូវប្រមូលសំណួរទាំងអស់ ដោយជ្រើសរើសសំណួរដែលដូចគ្នា និងខុសគ្នារួចបង្ហាញទៅកាន់ថ្នាក់រៀនទាំងមូល ។

អ្នកសម្របសម្រួលនិយាយ : ដូចគ្នាទៅនឹងផ្ទាំងរូបភាព និងរូបភាពដែរ ផែនទីក៏មានប្រយោជន៍សម្រាប់ផ្តល់អ្វីមួយឱ្យសិស្សធ្វើ ប្រសិនបើពួកគេបញ្ចប់មេរៀនមុនម៉ោង ឬ ប្រសិនបើសិស្សមួយចំនួនបញ្ចប់កិច្ចការមុនសិស្សដទៃទៀត ។

## សកម្មភាព 4.5 កិច្ចការគ្រូដោយប្រើផ្ទាំងរូបភាព និងផែនទី 15 នាទី

**សម្ភារ** : សៀវភៅកំណត់ត្រាគ្រូ

អ្នកសម្របសម្រួលនិយាយថា មានកិច្ចការពីរដែលនិយាយអំពីការប្រើផ្ទាំងរូបភាព និងផែនទី ។ អ្នកសម្របសម្រួលឱ្យអ្នកចូលរួមអានសៀវភៅកំណត់ត្រាគ្រូ និង អានឱ្យរហ័ស ។ អ្នកសម្របសម្រួលឆ្លើយសំណួររបស់អ្នកចូលរួម ។ ប្រសិនបើអ្នកចូលរួមពុំមានសំណួរទេ នោះអ្នកសម្របសម្រួលពិនិត្យមើលការយល់ដឹងរបស់អ្នកចូលរួម តាមការសួរសំណួរ :

តើអ្វីទៅដែលអ្នកគិតថា គ្រូនឹងសរសេរនៅក្នុងប្រអប់ដែលមានចំណងជើង "ការអធិប្បាយពីសកម្មភាពសិក្សា"?

***ចម្លើយរំពឹងទុក*** : សេចក្តីសង្ខេបនៃសកម្មភាពសិក្សាដែលកុមារធ្វើដោយប្រើផែនទី ឬផ្ទាំងរូបភាព គឺពុំមាននិយាយអំពីវត្ថុបំណង ឬ ចំណេះដឹង បំណិន ឥរិយាបថ ឬអ្វីផ្សេងទៀតនោះឡើយ ។

តើគ្រូអាចយកផែនទីពីកន្លែងណាមកប្រើ ប្រសិនបើគាត់ពុំមានទេ?

***ចម្លើយរំពឹងទុក*** : ខ្ចីពីគ្រូម្នាក់ទៀត ខ្ចីពីបណ្ណាល័យ ខ្ចីពីមណ្ឌលធនធានសាលាបង្គោល ទៅមើលផែនទីនៅសាលាឃុំ/សង្កាត់ សុំនាយកសាលាទិញផែនទី ដោយប្រើប្រាស់ថវិកា PAP របស់សាលារៀន ។

# ប្រធានបទទី 5 ការអភិវឌ្ឍអំណាន

## សកម្មភាព 5.1 អំណានឮៗដោយគ្រូ និងសិស្ស 60 នាទី

**សម្ភារ** : ផ្ទាំងរូបដែលសរសេរពីរបៀបអានអក្សរ សៀវភៅរឿងនិទាន (មានរូបភាព) សម្រាប់កុមារថ្នាក់ទី១ និងទី២ ។

អ្នកសម្របសម្រួល : គ្រូបង្រៀននៅបឋមសិក្សាជាច្រើនមានក្ដីបារម្ភថា កុមារមានការអភិវឌ្ឍបំណិនសរសេរ និងអានយឺតណាស់ ។ គ្រូដែលបង្រៀននៅថ្នាក់ខ្ពស់តួញត្អែរថាសិស្សដែលឡើងមកថ្នាក់របស់គាត់មានចំណេះដឹងអន់ ឯហេតុផលមួយក្នុងចំណោមហេតុផលផ្សេងៗគឺដោយសារកុមារភាគច្រើនធំដឹងក្ដីឡើងនៅក្នុងផ្ទះ ដែលមិនមានសៀវភៅច្រើន ទស្សនាវដ្ដី និងសារព័ត៌មាន ។ ជាញឹកញាប់កុមារមិនបានឃើញបងប្អូនបង្កើត ឬ មនុស្សចាស់អានសៀវភៅឡើយ ។ នេះមានន័យថា កុមារជាច្រើនមកសាលារៀនដោយពុំមានការយល់ដឹងផ្នែកមូលដ្ឋាន អំពីអក្សរ ឬ ចំណេះដឹងដែលមានសភាពខុសៗគ្នា និងគោលបំណងផ្សេងៗនៃប្រភេទអត្ថបទ ។

អ្នកសម្របសម្រួល : មុននឹងកុមារអាចអានដោយខ្លួនឯង គ្រូអាចជួយពួកគេរៀនតាមក្បួនខ្នាតជាមូលដ្ឋានមួយចំនួនអំពីការអានតាមរយៈការបង្ហាញ និងនិយាយ ។ ក្បួនខ្នាតទាំងអស់នេះ អ្នកអប់រំហៅថា របៀបអានអក្សរ (conventions of print) ។ របៀបអានអក្សរមួយចំនួនគឺមានលក្ខណៈជាក់ស្ដែងពេក រហូតដល់គ្រូបង្រៀនអាចនឹងភ្លេចថាកុមារអាចនឹងមិនដឹងអំពីវា ។

អ្នកសម្របសម្រួល : **តើរបៀបអានអក្សរខ្មែរដូចម្ដេច ?**

**ចម្លើយរំពឹងទុក :**

- ត្រូវអានអត្ថបទតាមលំដាប់ទំព័រនៃសៀវភៅ
- ត្រូវចាប់ផ្ដើមអានពីផ្នែកខាងលើនៃទំព័រ
- ត្រូវអានអត្ថបទពីឆ្វេងទៅស្ដាំតាមបន្ទាត់នីមួយៗ
- ត្រូវអានដោយពុំមានការដកឃ្លារវាងពាក្យជាច្រើន
- ត្រូវអានដោយមានការដកឃ្លា រវាងឃ្លា អនុប្រយោគ និងប្រយោគមួយចំនួន

របៀបអានអក្សរមិនមានលក្ខណៈដូចគ្នាទេ សម្រាប់ភាសាទាំងអស់ ។

អ្នកសម្របសម្រួល : គ្រូបង្រៀនគួរជួយសិស្សឱ្យយល់ពីបែបបទនៃអក្សរ និងអភិវឌ្ឍបំណិនអានដោយប្រើវិធីងាយៗមួយចំនួន ។ គ្រូបង្រៀនគួរប្រើវិធីទាំងនេះនៅពេលកំពុងអានអត្ថបទឱ្យសិស្សស្ដាប់ ឬ ជាមួយសិស្ស ។ ភាគច្រើននៃវិធីទាំងនេះមានលក្ខណៈសមស្របសម្រាប់សិស្សថ្នាក់ទី១-៣ ។ គ្រូបង្រៀនអាច ប្រើប្រាស់វិធីខ្លះក្នុងចំណោម វិធីផ្សេងទៀតដូចជាការទស្សនៈទាយសម្រាប់គ្រប់កម្រិតថ្នាក់ ។ អ្នកសម្របសម្រួលនិយាយថា : សង្កេតមើលការបង្ហាញ ថ្នាក់និទស្សន៍នឹងឃើញបំណិនជាច្រើនដែលអ្នកអាចស្វែងយល់ ឬ កំណត់បាន ។

អ្នកសម្របសម្រួលម្នាក់នៅក្នុងក្រុមអានរឿងដោយកាន់ផ្ទាំងរូបភាពធំ ព្រមទាំងអត្ថបទងាយៗសមស្របនឹងកម្រិតថ្នាក់ទី១, ២ ។ ដើម្បីធ្វើឱ្យសិក្ខាកាមមានឱកាស រកឃើញ និងកំណត់គំនិតទាំងនោះ ។ បន្ទាប់ពីបញ្ចប់ថ្នាក់និទស្សន៍ អ្នកសម្របសម្រួលសួរសិក្ខាកាមក្នុងថ្នាក់ទាំងមូលដើម្បីប្រមូលផ្ដុំគំនិត : ***តើវិធីងាយៗអ្វីខ្លះដែលគ្រូគួរប្រើនៅពេលអានអត្ថបទ/រឿងនិទានទៅកាន់សិស្សថ្នាក់ទី១ ទី២ ?*** អ្នកសម្របសម្រួលម្នាក់សរសេរចម្លើយរបស់សិក្ខាកាមដាក់លើក្ដារខៀន ។

***ចម្លើយរំពឹងទុក៖***

- *មុននឹងអាន គ្រូបង្ហាញរូបភាព និងសួរសិស្សថាតើពួកគេអាចទស្សន៍ទាយថាអត្ថបទនេះនិយាយអំពីអ្វី*
- *គ្រូអានអត្ថបទមួយលើកឱ្យសិស្សស្តាប់*
- *បន្ទាប់មកគ្រូអានដោយកាន់សៀវភៅ ដែលសិស្សទាំងអស់អាចមើលឃើញ*
- *ពេលគ្រូអាន គាត់អានតាមអត្ថបទដោយយកម្រាមដៃដាក់លើកន្លែងអានពីឆ្វេងទៅស្តាំ*
- *នៅពេលដល់ចុងបន្ទាត់មួយ ភ្នែក/ម្រាមដៃរបស់គាត់ត្រឡប់ទៅរកដួរ បន្ទាប់ ទៀត និងចាប់ពីឆ្វេងទៅ ស្តាំ*
- *គ្រូប្រាប់សិស្សឱ្យធ្វើតាមដោយមើលអត្ថបទនៅក្នុងសៀវភៅរបស់ពួកគេ ដោយប្រើម្រាមដៃក្នុងពេលគ្រូអាន*
- *គ្រូចល័តគ្រប់កន្លែងក្នុងបន្ទប់ដើម្បីត្រួតពិនិត្យមើល ថាតើកុមារកំពុងធ្វើតាមឬទេ*
- *គ្រូបញ្ឈប់ការអានក្នុងខណៈពេលណាមួយៗ ហើយសួរសិស្សថាតើពួកគេអាចទស្សន៍ទាយពាក្យ ឬ ឃ្លាបន្ទាប់បាន ឬទេ តាមរយៈការយល់ដឹងអត្ថន័យនៃរឿង ។*

ប្រសិនបើអ្នកចូលរួមពុំផ្តល់វិធីទាំងនេះទេ អ្នកសម្របសម្រួលគួរតែបន្ថែមវាចូលទៅក្នុងបញ្ជី ។

អ្នកសម្របសម្រួលហៅសិក្ខាកាមស្ម័គ្រចិត្ត ១ ឬ ២នាក់ឱ្យឡើងបង្ហាញពីបច្ចេកទេសទាំងនេះ ។ ក្នុងខណៈពេលអានអត្ថបទរឿង ។ អ្នកសម្របសម្រួលចូលរួមក្នុងក្រុមតូចដើម្បីសង្កេត និងផ្តល់យោបល់ ។



**សកម្មភាព 5.2 ការអភិវឌ្ឍចំណេះដឹងអំពី រចនាសម្ព័ន្ធអត្ថបទ "ពេញលេញ" របស់កុមារ** 60 នាទី

**សម្ភារៈ** តារាងបង្ហាញសំណួរគ្រូ លក្ខណៈនៃអត្ថបទពេញលេញ និងអត្ថបទរឿងទន្សាយចង់ស៊ីចេក ។

អ្នកសម្របសម្រួល ៖ នៅក្នុងការបង្រៀនអំណាន និងសរសេរ គ្រូភាគច្រើនផ្តោតអារម្មណ៍យ៉ាងខ្លាំងទៅលើអក្សរ និងពាក្យច្រើនជាងទៅលើអត្ថបទទាំងមូល ។ ជាលទ្ធផល គឺថាសិស្សមិនមានឱកាសច្រើនដើម្បីគិតអំពីអត្ថន័យ និងអ្វីដែលបង្កើតជាអត្ថបទមួយ "ពេញលេញ"ឡើយ ។ វាធ្វើឱ្យសិស្សជួបការលំបាកដើម្បីក្លាយជាអ្នកដែលមានជំនាញក្នុងការអាន និងការសរសេរ ។ ទោះបីជាកុមារតូច ក៏ពួកគេចេះវិភាគអត្ថបទទៅតាមរបៀបងាយណាមួយ ប្រសិនបើគ្រូសួរសំណួរបានត្រឹមត្រូវ ។ កុមារនឹងទទួលបានអត្ថប្រយោជន៍យ៉ាងច្រើននៅក្នុងឆ្នាំបន្ទាប់លើការយល់ដឹងទាំងអស់នេះ នៅពេលពួកគេចាប់ផ្តើមសរសេរអត្ថបទផ្ទាល់ខ្លួន ។

អ្នកសម្របសម្រួលឱ្យអ្នកសម្របសម្រួលម្នាក់ទៀតអានអត្ថបទទៅកាន់អ្នកចូលរួម ។ អ្នកសម្របសម្រួលប្រាប់អ្នកនោះថានឹងមានកិច្ចការខ្លះសម្រាប់អ្នកចូលរួមធ្វើបន្ទាប់ពីអានរួច ដូច្នេះមិនត្រូវសួរសំណួរអំពីអត្ថបទឡើយ គ្រាន់តែអានវាឱ្យចប់បានហើយ ។

អ្នកសម្របសម្រួលម្នាក់ទៀតអានអត្ថបទ រឿងទន្សាយចង់ស៊ីចេក (ឯកសារចែកជូន)

អ្នកសម្របសម្រួលនិយាយថា ៖ នៅពេលគ្រូ និងសិស្សអានចប់ គ្រូគួរសួរសំណួរដល់សិស្សអំពីអត្ថបទទាំងមូល ។ សំណួរទាំងនេះអាចប្រើសម្រាប់ពិភាក្សាអំពីអត្ថបទ ភាគច្រើនទាក់ទងទៅនឹងកន្សោមពាក្យដូចខាងក្រោម ៖

**នរណា នៅឯណា នៅពេលណា មានអ្វីកើតឡើង ចាប់ផ្តើម បញ្ចប់**

អ្នកសម្របសម្រួលសួរសិក្ខាកាម ៖ ***តើអ្នកអាចផ្តល់ឧទាហរណ៍ពីសំណួរមួយចំនួនដែលគ្រូអាចសួរដើម្បីជួយសិស្សអភិវឌ្ឍការយល់ដឹងថាអ្វីជាអត្ថបទពេញលេញបានឬទេ?*** អ្នកសម្របសម្រួលទី២ ឡើងសរសេរលើក្តារខៀនក្នុងខណៈពេលសិក្ខាកាមផ្តល់ចម្លើយ ។

***ចម្លើយរំពឹងទុក ៖***

- *តើនរណាជាតួអង្គសំខាន់នៅក្នុងអត្ថបទ?*
- *តើអ្វីបានកើតឡើងនៅក្នុងអត្ថបទ (ព្រឹត្តិការណ៍សំខាន់)?*
- *តើព្រឹត្តិការណ៍ក្នុងរឿងកើតឡើងនៅឯណា?*
- *តើព្រឹត្តិការណ៍ក្នុងរឿងកើតឡើងនៅពេលណា?*
- *តើរឿងនេះចាប់ផ្តើមដោយរបៀបណា?*
- *តើអ្វីបានកើតឡើងនៅពេលបន្ទាប់... (ឱ្យកុមារនិយាយរឿងឡើងវិញដោយប្រើពាក្យផ្ទាល់របស់ពួកគេ)?*
- *តើអ្វីកើតឡើងនៅពេលបញ្ចប់រឿង?*

***បញ្ជាក់*** ៖ អ្នកសម្របសម្រួលឱ្យពិនិត្យច្បាស់ពីការអានអត្ថបទ " **ទន្សាយចង់ស៊ីចេក** "

អ្នកសម្របសម្រួល ៖ សួរសំណួរតាមតារាងខាងក្រោម និងស្រង់ចម្លើយដាក់ក្នុងតារាង (កូឡោនទី ២)

| **សំណួររបស់គ្រូបង្រៀន** | **ចម្លើយអំពីអត្ថបទ** | **លក្ខណៈនៃអត្ថបទពេញលេញ** |
|---|---|---|

| | | |
|---|---|---|
| តើនរណាជាតួអង្គសំខាន់នៅក្នុងអត្ថបទ? | ទន្សាយ | *តួអង្គ* |
| តើអ្វីបានកើតឡើងនៅក្នុងអត្ថបទ ( ព្រឹត្តិការណ៍សំខាន់ ) ? | ទន្សាយចង់ស៊ីចេក ដោយធ្វើពុតជាងាប់ | *ព្រឹត្តិការណ៍* |
| តើព្រឹត្តិការណ៍ក្នុងរឿងកើតឡើងនៅឯណា? | ............................. | *ទីកន្លែង* |
| តើព្រឹត្តិការណ៍ក្នុងរឿងកើតឡើងនៅពេលណា? | ............................. | *ពេលវេលា* |
| តើរឿងនេះចាប់ផ្តើមដោយរបៀបណា? | ............................. | *សេចក្តីផ្តើម* |
| តើអ្វីបានកើតឡើងនៅពេលបន្ទាប់...( ឱ្យកុមារនិយាយរឿងឡើងវិញដោយប្រើពាក្យផ្ទាល់របស់ពួកគេ ) ? | ............................. ............................. | *តួសេចក្តី សាច់រឿងទាំងមូល* |
| តើអ្វីកើតឡើងនៅពេលបញ្ចប់រឿង? | ............................. | *សេចក្តីបញ្ចប់* |

បន្ទាប់មកអ្នកសម្របសម្រួលសរសេរព័ត៌មានចូលទៅក្នុងកូឡោនទី៣ នៅលើតារាង "លក្ខណៈនៃអត្ថបទពេញលេញ" ។

អ្នកសម្របសម្រួលបិទតារាងសំណួររួចនិយាយថា ខ្ញុំមានសំណួរពីរបន្ថែមទៀតអំពីអត្ថបទដែលត្រូវឆ្លើយ... អ្នកសម្របសម្រួលទីពីរសរសេរចម្លើយពួកគេ ។

| **សំណួររបស់គ្រូបង្រៀន** | **ចម្លើយអំពីអត្ថបទ** | **លក្ខណៈនៃអត្ថបទពេញលេញ** |
|---|---|---|
| នៅក្នុងអត្ថបទរឿងនេះ តើអ្នកចូលចិត្តផ្នែកណា? ហេតុអ្វី? | ................................... | *ជំរុញការពិចារណាហ្មត់ចត់* |
| តើនរណាជាតួអង្គដែលអ្នកចូលចិត្តនៅក្នុងអត្ថបទ? ហេតុអ្វី ? | ................................... | *ជំរុញការពិចារណាហ្មត់ចត់* |

ចំពោះសំណួរចុងក្រោយទាំងពីរនេះ អ្នកសម្របសម្រួលសួរអ្នកស្ម័គ្រចិត្តទាំង២ រូប : ***តើអ្នកមានរកឃើញចម្លើយ*** សម្រាប់***សំណួរទាំងពីរនេះនៅក្នុងអត្ថបទឬទេ?***

ចម្លើយរំពឹងទុក : *ទេ យើងត្រូវតែប្រើគំនិតរបស់ខ្លួនឯងដើម្បីឆ្លើយសំណួរទាំងពីរនេះ* ។ អ្នកសម្របសម្រួលយល់ស្រប និងបន្ទាប់មកសរសេរចូលទៅក្នុងតារាង " សំណួរពិចារណាហ្មត់ចត់ "។ អ្នកសម្របសម្រួលនិយាយថាជំរុញការពិចារណាហ្មត់ចត់ ត្រូវសួរសំណួរអំពីអត្ថបទ ប៉ុន្តែគេពុំអាចឆ្លើយនូវគំនិត និងព័ត៌មាននៅក្នុងអត្ថបទឡើយ ។ លោកគ្រូ អ្នកគ្រូគួរយកចិត្តទុកដាក់លើសំណួរ ២ ខាងក្រោយបន្ថែមទៀត ដើម្បីធ្វើឱ្យអត្ថបទកាន់តែមានលក្ខណៈពេញលេញ ។

## សកម្មភាព 5.3 ការប្រើអត្ថបទជាក់ស្តែង 60 នាទី

**សម្ភារ :** អត្ថបទជាក់ស្តែង ( សិស្សរក ) អត្ថបទផ្សព្វផ្សាយពាណិជ្ជកម្ម សុខភាព មីន រូបមន្តធ្វើម្ហូប ។

**អត្ថបទជាក់ស្តែង ( សម្រាប់កុមារធំៗ)**

អ្នកសម្របសម្រួលនិយាយថា : សិស្សជាច្រើនគ្រាន់តែធ្លាប់បានអានអត្ថបទដែលមាននៅក្នុងសៀវភៅសិក្សា ឬនៅក្នុងសៀវភៅរឿងដែលបានពីបណ្ណាល័យប៉ុណ្ណោះ ។ គ្រូបង្រៀនអាចជួយពង្រីកបទពិសោធន៍របស់សិស្សក្នុងភាពជាអ្នកអានដោយបង្ហាញពួកគេនូវប្រភេទអត្ថបទផ្សេងទៀត ។ អត្ថបទភាគច្រើនគឺជួបប្រទះនៅក្នុងជីវិតប្រចាំថ្ងៃ ប៉ុន្តែកម្រយកមកប្រើនៅក្នុងការសិក្សាណាស់ ។ អត្ថបទទូទៅត្រូវបានគេប្រើនៅក្នុងការផ្សព្វផ្សាយព័ត៌មានផ្សេងៗ ដែលទាក់ទងនឹងការអប់រំសុខភាព ការសិក្សា បរិស្ថាន ការផ្សាយពាណិជ្ជកម្ម និងលើផលិតផល ។ អត្ថបទទាំងនេះ អាចមានលក្ខណៈងាយ ( ប្រទេសខ្ញុំ ស្រាបៀរខ្ញុំ) ឬ មានលក្ខណៈស្មុគស្មាញ ( ធាតុផ្សំគីមីនៅក្នុងកំប៉ុង ភេសជ្ជៈ) ។ ដូចគ្នានោះផងដែរ គេអាចអាន និងស្វែងយល់អត្ថន័យអត្ថបទទាំងអស់នេះនៅលើផ្ទៃកំប៉ុង និងគ្រូអាចសួរសំណួរលើកទឹកចិត្តឱ្យកុមារគិតអំពីមូលហេតុដែលគេសរសេរអត្ថបទទាំងនេះ (**គោលបំណង**) និងថាតើគេសរសេរសម្រាប់នរណា (**ទស្សនិកជន**) ។

បន្ទាប់មកអ្នកសម្របសម្រួលជ្រើសរើសឧទាហរណ៍ពីអត្ថបទជាក់ស្តែងដែលគ្រូយកមក ហើយអានផ្នែកខ្លះ អ្នកសម្របសម្រួលគប្បីជ្រើសរើសអត្ថបទដោយប្រុងប្រយ័ត្ន ពីព្រោះអត្ថបទខ្លះមានកម្រិតលំបាក ។ អ្នកសម្របសម្រួលសួរអ្នកចូលរួមឱ្យប្រាប់អំពីអត្ថបទជាក់ស្តែង *ឧទាហរណ៍* : គោលបំណង និងទស្សនិកជន ។

អ្នកសម្របសម្រួលបែងចែកសិក្ខាកាមជាក្រុមតូចដើម្បីពិភាក្សា និងធ្វើបញ្ជីឧទាហរណ៍អត្ថបទជាក់ស្តែងនៅក្នុងសហគមន៍ និងសាលារៀនរបស់ពួកគាត់ ។ នៅពេលពួកគាត់ធ្វើចប់ តំណាងក្រុមតាមក្រុមនីមួយៗឡើងរាយការណ៍អ្វីដែលបានរកឃើញ ។ តំណាងក្រុមផ្សេងៗទៀតអាចបន្ថែមគំនិតដែលខុសប្លែកគ្នា ។ អ្នកចូលរួមអាចបង្ហាញគំនិតរបស់ខ្លួនជាទម្រង់តារាងដូចបង្ហាញខាងក្រោមនេះ ។

***ចម្លើយរំពឹងទុក :***

| ***ប្រភេទអត្ថបទជាក់ស្តែង*** | ***គោលបំណង*** | ***អ្នកអាន/ទស្សនិកជន*** |
|---|---|---|
| *ការផ្សាយពាណិជ្ជកម្ម* | *ដើម្បីលក់ផលិតផល* | *គ្រប់គ្នាដែលចង់ទិញផលិតផល* |
| *សេចក្តីណែនាំពី របៀបប្រើ* | *ជូនដំណឹង បង្ការការខូចខាត* | *គ្រប់គ្នាដែលទិញ និងប្រើប្រាស់ផលិតផល* |
| *រូបមន្តធ្វើម្ហូប* | *បង្ហាញពីសេចក្តីណែនាំសម្រាប់ចម្អិន* | *គ្រប់គ្នាដែលចង់ចម្អិនអាហារនោះ* |
| *ព័ត៌មានពី...* | *បញ្ចុះបញ្ចូលប្រជាជន ឱ្យបោះឆ្នោតជូនគណបក្សណាមួយ* | *គ្រប់គ្នាដែលមានសិទ្ធិបោះឆ្នោត* |
| *ព័ត៌មានពី...* | *បង្ហាញពីរបៀបដែលធ្វើឱ្យមានសុខភាពល្អ ឬគ្រោះថ្នាក់ដល់សុខភាព* | *គ្រប់គ្នាដែលចាប់អារម្មណ៍ពីសុខភាពអនាម័យ* |
| *ព័ត៌មានពី...* | *បង្កើនការពិចារណា ប្រាប់ដំណឹង បញ្ចុះបញ្ចូល* | *គ្រប់គ្នាដែលចាប់អារម្មណ៍* |

**<u>សន្និដ្ឋាន</u> :**

អ្នកសម្របសម្រួលនិយាយថា នៅជនបទការដែលមាននរណាម្នាក់ចេះអាន គឺជាធនធានយ៉ាងសំខាន់ ។ សមត្ថភាពអានផ្តល់ការយល់ដឹងពីប្រភេទព័ត៌មានខុសៗគ្នាជាច្រើន ។ ព័ត៌មានខ្លះ ដូចជាវិធីប្រើ ឬបំរាមអំពីថ្នាំពេទ្យ ថ្នាំគីមីកសិកម្ម និង

ផលិតផលផ្សេងទៀត អាចជាការសង្គ្រោះជីវិតមួយ ។ ការចេះអក្សរក៏ជាបំណិនសំខាន់មួយ នៅក្នុងការចូលទៅដល់ព័ត៌មានអំពីសិទ្ធិស្របច្បាប់ និងសិទ្ធិនានារបស់ពលរដ្ឋ ។ ហេតុនេះហើយបានជាមនុស្សជាច្រើនអធិប្បាយ ការចេះអក្សរជា "បំណិនជីវិត " សំខាន់ជាងគេបំផុត ។

## សកម្មភាព ៥.4 កិច្ចការគ្រូអំពីអំណាន 30 នាទី

**សម្ភារ** : សៀវភៅកំណត់ត្រាគ្រូ ទំព័រ... ។

អ្នកសម្របសម្រួលនិយាយថា មានកិច្ចការចំនួនពីរស្តីអំពីអំណាននៅក្នុងសៀវភៅកំណត់ត្រាគ្រូ ។ អ្នកសម្របសម្រួលឱ្យសិក្ខាកាមអានវា ។ អ្នកសម្របសម្រួលសួរសិក្ខាកាមក្រែងពួកគាត់មិនយល់អំពីការណែនាំនៅលើទំព័រទាំងនោះ ។ អ្នកសម្របសម្រួល ត្រូវត្រួតពិនិត្យការយល់របស់សិក្ខាកាមតាមការសួរពួកគាត់ :

កិច្ចការទី១ : ការវិភាគអត្ថបទ

**តើឯកសារអ្វីដែលគ្រូប្រើ សម្រាប់ធ្វើការវិភាគ ?**

*ចម្លើយរំពឹងទុក: គ្រូអាចជ្រើសរើសសៀវភៅរឿងសមស្រប ឬអត្ថបទ ពីទស្សនាវដ្តី ឬពីសៀវភៅរបស់ក្រសួងអប់រំ យុវជន និងកីឡា ។*

**តើអ្នកសរសេរចម្លើយការវិភាគអត្ថបទជាមួយកុមារនៅឯណា ?**

*ចម្លើយរំពឹងទុក : នៅលើសន្លឹកកិច្ចការក្នុងសៀវភៅកំណត់ត្រាគ្រូ ។*

**នៅក្នុងកិច្ចការអំណានទី២ តើមានកុមារប៉ុន្មាននាក់ដែលអ្នកបានធ្វើសម្ភាសន៍អំពីចំណាប់អារម្មណ៍របស់ពួកគេ?**

*ចម្លើយរំពឹងទុក: ៦នាក់ គឺកុមារាពនាក់ និងកុមារីពនាក់ ។*

**តើអ្នកសរសេរអ្វីខ្លះនៅក្នុងប្រអប់ទី២** សម្រាប់**កិច្ចការទី២?**

*ចម្លើយរំពឹងទុក : នៅផ្នែកខាងឆ្វេងដៃ អ្នកសរសេរប្រភេទរឿងដែលកុមារបានលើកឡើង ។ នៅខាងស្តាំដៃអ្នករាប់តើមានកុមារប៉ុន្មាននាក់ដែលនិយាយប្រភេទរឿងនោះ និងសរសេរចំនួនកុមារ ។*

# ប្រធានបទទី ៦ ការអភិវឌ្ឍសំណេរ

## សកម្មភាព 6.1 សំណេរដើម និងអត្ថបទចរចា 75 នាទី

**សម្ភារ** : ផ្ទាំងក្រដាសធំ ប៊ិកហ្វឺត ឯកសារសង្ខេបតារាងទី១ ស្ដីពីឧទាហរណ៍អំពីសកម្មភាពប្រើវិធីសាស្ត្រអត្ថបទចរចានៅកម្រិតថ្នាក់ផ្សេងគ្នា ឯកសារសង្ខេបតារាងទី២ ស្ដីពីផលសម្រេចនៃការស្រាវជ្រាវអំពីសំណេរល្អ ។

អ្នកសម្របសម្រួល : កន្លងមកយើងបានផ្ដោតទៅលើការជួយកុមារឱ្យអភិវឌ្ឍបំណិនអាន ។ ពេលនេះយើងនឹងផ្ដោតលើការជួយកុមារឱ្យអភិវឌ្ឍបំណិនសរសេរ ។

អ្នកសម្របសម្រួល : មនុស្សមួយចំនួនដែលមិនយល់ពីការអប់រំគិតថា "**បំណិនសរសេរ**" គឺ មានលក្ខណៈដូចគ្នានឹង "**បំណិនសរសេរដៃ** " ។ ពួកគេគិតថាប្រសិនបើមនុស្សចេះតួអក្សរ ហើយអាចគូសអក្សរដោយប្រើ ខ្មៅដៃបាននោះពួកគេថា : ចេះសរសេរហើយ ។

អ្នកសម្របសម្រួល : ជាការពិតណាស់ការរៀនសរសេរអក្សរ និងពាក្យគឺជាផ្នែកមួយសំខាន់ណាស់នៅក្នុងការងាររបស់សិស្សនៅក្នុងថ្នាក់ទី១ ទី២ និងទី៣ ។ ទោះបីជាយ៉ាងណាក៏ដោយនៅថ្នាក់ទី៤ សិស្សគួរតែចាប់ផ្ដើមអភិវឌ្ឍបំណិនផ្សេងទៀត ព្រមទាំងសមត្ថភាពសរសេរបានស្អាត និងប្រកបបានត្រឹមត្រូវ ។

អ្នកសម្របសម្រួលសួរ : ***ប្រសិនបើការសរសេរល្អ មានន័យលើសពីការសរសេរដៃបានស្អាត និងប្រកបបានត្រឹមត្រូវនោះ តើការសរសេរបានល្អមានន័យដូចម្ដេច?*** អ្នកសម្របសម្រួលផ្ដល់សន្លឹកក្រដាសទៅឱ្យសិក្ខាកាមដើម្បីធ្វើការជាក្រុមដែលមានសមាជិក៥នាក់ ហើយព្យាយាមសរសេរនិយមន័យខ្លីមួយអំពីការសរសេរល្អ ។ ក្រុមទាំងឡាយឡើងបិទប័ណ្ណ និងតំណាងក្រុមឡើងអាន ។

អ្នកសម្របសម្រួល : អ្នកអប់រំជាច្រើនយល់ស្របថា **ការសរសេរល្អ គឺអ្នកដែលអាចសរសេរដោយចេះប្រើពាក្យ ឃ្លា ល្បះ ខ្លីមានន័យគ្រប់គ្រាន់ ។**

អ្នកសម្របសម្រួលបិទតារាងនៅលើក្ដារខៀនហើយនិយាយថា : មានការសិក្សាពីសំណេរជាច្រើននៅក្នុងភាសាផ្សេងៗគ្នាលើពិភពលោកយើងនេះ ។ ការសិក្សាទាំងអស់យល់ស្របថា :

- មធ្យោបាយល្អដើម្បីក្លាយជាអ្នកសរសេរ គឺត្រូវសរសេរអត្ថបទផ្ទាល់ខ្លួនឯង (ពោលគឺ ដោយការអនុវត្ត)
- ការចម្លងសំណេរពីអ្នកដទៃមិនមែនជាមធ្យោបាយល្អបំផុតដើម្បីបង្កើនបំណិនសរសេរនោះទេ (លើកលែងតែកុមារដែលនៅក្មេងពេក និងមិនទាន់បានហ្វឹកហាត់សរសេរដៃនៅឡើយ)
- ការសរសេរ គឺជាលំនាំមួយ អ្នកសរសេរត្រូវតែសរសេរអ្វីមួយជាច្រើនដង (សរសេរព្រាងច្រើនដង) មុននឹងបានជាអត្ថបទពេញលេញមួយ
- វាជាជំនួយមួយ ប្រសិនបើពិភាក្សាអត្ថបទសរសេរជាមួយអ្នកដទៃមុននឹងបញ្ចប់វា
- អត្ថបទទាំងឡាយត្រូវបែងចែកជាច្រើនប្រភេទ ហើយប្រភេទនីមួយៗមានលក្ខណៈផ្ទាល់របស់វា
- សិស្សដែលបានយល់ពីមូលដ្ឋានគ្រឹះនៃវចនាសម្ព័ន្ធ និងលក្ខណៈប្រភេទផ្សេងៗនៃសំណេរ គឺជាអ្នកសរសេរដ៏ពូកែ ។

អ្នកសម្របសម្រួល : វាជាការសំខាន់ចំពោះគ្រូបង្រៀនដែលត្រូវផ្ដល់ឱកាសឱ្យសិស្ស ទោះបីជាសិស្សតូចៗក៏ដោយឱ្យបង្កើតការសរសេរផ្ទាល់ខ្លួន ។ នេះមានន័យថាការសរសេរមានផ្ទុកនូវគំនិតផ្ទាល់របស់សិស្ស វាមិនមែនជាការចម្លងពីក្ដារខៀន ឬសៀវភៅទេ ។ សិស្សដែលសរសេរផ្ទាល់ខ្លួននឹងមានការលូតលាស់ ហើយមានទំនុកចិត្តក្នុងខណៈដែល ពួកគេអនុវត្តប្រយោគមួយនឹងក្លាយទៅជាប្រយោគពីរ បន្ទាប់មកក្លាយទៅជាប្រយោគបី និងបន្ទាប់មកទៀតក្លាយទៅជាកថាខណ្ឌ

នឹងក្លាយជាអត្ថបទពេញលេញ ។ វាជាការសំខាន់ផងដែរថា គ្រូបង្រៀនត្រូវអនុញ្ញាតឱ្យសិស្សមើល ឧទាហរណ៍នៃការសរសេរផ្ទាល់ខ្លួនរបស់គេដែលតាំងបង្ហាញនៅលើជញ្ជាំងថ្នាក់រៀន គាបភ្ជាប់នឹងខ្សែនៅខាងលើ តុសិស្ស ឬ សរសេរបង្ហាញនៅលើក្ដារខៀន ។

អ្នកសម្របសម្រួល : ប៉ុន្តែចំពោះសិស្សដែលមិនទាន់ចេះសរសេរនៅឡើយ តើពួកគេអាចបង្កើតសំណេរផ្ទាល់ខ្លួនដោយរបៀបណា? ពួកគេអាចធ្វើបានតាមដំណើរការមួយដែលហៅថា "អត្ថបទចរចា " ។ នេះមានន័យថាគ្រូបង្រៀន និងសិស្សត្រូវពិភាក្សាគ្នាអំពីអ្វីដែលសិស្សចង់និយាយ ហើយនៅពេលសិស្សយល់ព្រមគ្រូសរសេរឱ្យពួកគេ ។ គ្រូ និងសិស្សអានអត្ថបទនោះជាមួយគ្នា ។ ទោះបីជាពួកគេមិនបានសរសេរដោយខ្លួនឯងក៏ដោយ ក៏ពួកគេមានអារម្មណ៍ជាម្ចាស់អត្ថបទ ពីព្រោះវាជាគំនិតរបស់ពួកគេ ។ ដំណើរការដូចគ្នានេះអាចប្រើប្រាស់នៅពេល**សិស្សគូរគំនូរ** ។ គ្រូបង្រៀនអាចសួរពីអ្វីដែលសិស្សចង់សរសេរនៅខាងក្រោមគំនូរ បន្ទាប់មកគ្រូសរសេរអ្វីដែលពួកគេនិយាយនោះ ។

គ្រូអាចប្រើប្រាស់អត្ថបទចរចាប្រកបដោយជោគជ័យបាន ជាមួយសិស្សថ្នាក់ខ្ពស់ដែលអាចពិភាក្សាក្នុងក្រុមនូវអ្វីដែលពួកគេនិយាយ (ការចរចា) បន្ទាប់មកសមាជិកម្នាក់អាចសរសេរគំនិតរបស់ក្រុមនោះ ។

ការប្រើអត្ថបទចរចានៅកម្រិតថ្នាក់ខុសៗគ្នា :

<table>
<tr><th>ថ្នាក់ទី</th><th>ឧទាហរណ៍នៃសកម្មភាពរៀនសូត្រដោយប្រើការចរចា</th></tr>
<tr><td>១</td><td>គ្រូសួរសិស្សឱ្យនិយាយតើគំនូររបស់គេនិយាយអំពីអ្វី ? គ្រូសរសេរចំណងជើងឱ្យសិស្សនៅពីក្រោមគំនូរពួកគេ ។ គ្រូសួរសិស្សឱ្យនិយាយតើគំនូររបស់គេនិយាយអំពីអ្វី ? គ្រូសរសេរចំណងជើងឱ្យសិស្សចម្លងទៅដាក់លើគំនូរពួកគេ ។ គ្រូសរសេរប្រយោគទោលមួយនៅលើក្ដារខៀនដោយប្រើចម្លើយសិស្សឆ្លើយចំពោះសំណួរ ។ សិស្សអានវារួមគ្នា ។</td></tr>
<tr><td>២</td><td>គ្រូហៅសិស្សឱ្យអធិប្បាយអ្វីមួយដែលបានកើតឡើងនៅក្នុងសហគមន៍ ។ គ្រូសរសេរប្រយោគងាយៗពីរ ឬ បីដោយប្រើពាក្យរបស់សិស្ស ។ គ្រូ និងសិស្សអានរួមគ្នា ។ កុមារចំលងវាចូលក្នុងសៀវភៅពួកគេ ។</td></tr>
<tr><td>៣</td><td>គ្រូហៅសិស្សឱ្យធ្វើការងារជាក្រុមតូចៗ ដើម្បីសរសេរអត្ថបទងាយៗរួមគ្នា ។ គ្រូជួយសិស្សប្រសិនបើគេជាប់គាំងដោយសួរសំណួរ ឬ ប្រកបពាក្យថ្មី ឬ ពាក្យពិបាកឱ្យសិស្ស ។ ក្រុមទាំងឡាយចែករំលែកអត្ថបទគ្នានៅក្នុងថ្នាក់ ។</td></tr>
<tr><td>៤</td><td rowspan="3">សិស្សចាប់ផ្តើមសរសេរអត្ថបទងាយៗដោយខ្លួនឯង ។ ពេលសិស្សចាប់ផ្តើមសរសេរអត្ថបទវែង ឬ ស្មុគស្មាញជាងមុន ពួកគេនឹងដឹងថាវាអាចជួយដល់ការពិភាក្សាអំពីគំនិតនៅក្នុងក្រុម និងផលិតអត្ថបទចរចាមួយ ។ សមាជិកម្នាក់របស់ក្រុមអាចធ្វើជាអ្នកសរសេរ ។ សិស្សដែលមានការលំបាកក្នុងការសរសេរ ក៏អាចបង្កើតភាពជឿជាក់តាមការធ្វើការចរចា និងធ្វើការងារជាក្រុមបន្ថែមទៀត មុននឹងគេសាកល្បងធ្វើការងារដោយខ្លួនឯង ។</td></tr>
<tr><td>៥</td></tr>
<tr><td>៦</td></tr>
</table>

បន្ទាប់មកអ្នកសម្របសម្រួលបង្ហាញដំណើរការ អត្ថបទចរចាជាមួយអ្នកចូលរួមមួយក្រុមដែលមានគ្នា ៦ ឬ ៧នាក់ ។ អ្នកសម្របសម្រួលជាអ្នកសរសេរអត្ថបទនៅលើផ្ទាំងក្រដាសធំមួយ ហើយសមាជិកក្រុមជាអ្នកផ្ដល់គំនិត ។ អ្នកចូលរួមដទៃទៀតឈរនៅជុំវិញក្រុមដើម្បីសង្កេតមើលលំនាំនេះ ។



នៅចុងបញ្ចប់នៃសកម្មភាពធ្វើបង្ហាញ អ្នកសម្របសម្រួលសួរក្រុមទាំងមូលឱ្យផ្តល់គំនិត អំពីតួនាទីរបស់**អ្នកសរសេរ** ***(អ្នកចរចា)*** និងតួនាទីរបស់ក្រុម ។ អ្នកសម្របសម្រួលទី២ អាចកត់ត្រាចម្លើយពួកគាត់ ។

*ចម្លើយរំពឹងទុកគឺ :*

| **អ្នកសរសេរ** | **សមាជិកក្រុម/អ្នកចរចា** |
|---|---|
| សរសេរគំនិតសមាជិកក្រុម | ផ្តល់គំនិតផ្ទាល់ខ្លួន |
| សួរបញ្ជាក់ឱ្យច្បាស់ | ស្តាប់អ្នកដទៃ |
| សូមកុំបដិសេធគំនិតរបស់សមាជិកក្រុម | ផ្តល់ការកែលំអ |
| សូមកុំធ្វើការកែតម្រូវ លុះត្រាតែប្រាប់ឱ្យធ្វើ | ចង្អុលកំហុស និងផ្តល់ការកែតម្រូវ |
| សួរសំណួរ ប្រសិនបើក្រុមជាប់គាំង | អានឡើងវិញនូវអ្វីដែលគេបានធ្វើដើម្បីមើលថាតើអត្ថន័យ ច្បាស់លាស់ និងសមស្របឬទេ ? |

**សកម្មភាព 6.2 លំនាំសំណេរ (ការសរសេរព្រាង និងការផ្តល់យោបល់) 90 នាទី**

**សម្ភារ :** ក្រដាសធំ ប៊ិកហ្វឺត តារាងបញ្ជីផ្ទៀងផ្ទាត់សម្រាប់អត្ថបទក្រុម ។

អ្នកសម្របសម្រួល : កុមាររៀនថ្នាក់ទី៣ ពួកគេចេះចាប់ផ្តើមធ្វើសំណេរដើមរបស់ខ្លួនហើយ ។ ចាប់ពីថ្នាក់ទី៣ ឡើងទៅ គ្រូគួរតែជួយកុមារឱ្យយល់ថា ជាធម្មតាសំណេរល្អទទួលបានមកពី**លំនាំ**មួយ ។

អ្នកសម្របសម្រួល : មានអ្នកសរសេរមួយចំនួនតូច ដែលអាចសរសេរអត្ថបទល្អឥតខ្ចោះក្នុងរយៈពេលតែមួយលើក ។ ការសរសេរភាគច្រើនត្រូវឆ្លងកាត់ដំណើរការ**ព្រាង** ពីរ បី ឬ ច្រើនលើកសិន មុននឹងអ្នកសរសេរពេញចិត្តអត្ថបទនោះ ។ បច្ចុប្បន្ននេះមានការងាយស្រួលណាស់ដោយប្រើកុំព្យូទ័រជាអ្នកកែតម្រូវ ដែលគេអាចធ្វើបានគ្រប់ពេលវេលា ។ បើសរសេរដៃវាមានការលំបាកច្រើន ហើយមានភាពរញ៉េរញ៉ៃទៀតផង ដូចជាការគូសខ្វែងចោល ការបញ្ចូលព័ត៌មានថ្មី និងការកែតម្រូវផ្សេងទៀត គឺត្រូវធ្វើនៅលើក្រដាស ក្ដារឆ្នួន ឬ លើក្ដារខៀន ។ គេមិនគួររិះគន់អ្នកសរសេរ ចំពោះការព្រាងដែលគ្មានសណ្ដាប់ធ្នាប់នេះឡើយ : ការផ្លាស់ប្ដូរច្រើនដងបង្ហាញថាអ្នកសរសេរយកចិត្តទុកដាក់ខ្លាំងអំពីការបង្កើត**សំណេរចុងក្រោយ** ដែលមានលក្ខណៈត្រឹមត្រូវ ។ **គោលបំណងចំបងនៅក្នុងការព្រាងលើកដំបូង គឺដើម្បីសរសេរនូវរាល់គំនិតទាំងអស់នៅលើក្រដាស ។**

អ្នកសម្របសម្រួល : អ្នកសរសេរជាច្រើនទទួលបានផលប្រយោជន៍ពីការដែលឱ្យអ្នកផ្សេងអាន និងផ្ដល់នូវគំនិតយោបល់លើការព្រាងសំណេររបស់ខ្លួនគេ ។ ការធ្វើបែបនេះគេហៅថា " **ការផ្ដល់យោបល់** " ។ នៅក្នុងការផ្ដល់យោបល់ អ្នកអានសេចក្ដីព្រាង គួរផ្ដោតជាសំខាន់ទៅលើអត្ថន័យ ថាតើវាច្បាស់លាស់ឬទេ? តើវាគួរឱ្យច្រឡំបល់ឬទេ? តើផ្នែកដែលល្អអាចធ្វើឱ្យកាន់តែល្អថែមទៀតបានឬទេ? កំហុសអក្ខរាវិរុទ្ធមិនសំខាន់ទេ ពីព្រោះវាមិនមែនជាសំណេរចុងក្រោយឡើយនៅក្នុងការផ្ដល់យោបល់នេះ អត្ថន័យ**សំណេរចុងក្រោយ** គួរតែមានលក្ខណៈច្បាស់លាស់ ហើយរាល់កំហុសទាំងឡាយរួមមានអក្ខរាវិរុទ្ធ និងសញ្ញាវណ្ណយុត្តិត្រូវបានកែតម្រូវ ។

អ្នកសម្របសម្រួល : សំណេរព្រាងទាំងឡាយអាចសរសេរនៅលើក្រដាសចាស់ៗ លើក្ដារឆ្នួន ឬ លើក្ដារខៀនតូច ។ ការធ្វើដូចនេះងាយស្រួលក្នុងការកែតម្រូវ ។ វាក៏មានលក្ខណៈប្រសើរផងដែរ ប្រសិនបើក្រុមតូចកំពុងធ្វើការរួមគ្នានៅលើអត្ថបទមួយ ពីព្រោះពួកគេទាំងអស់អាចនៅជុំគ្នា និងពិនិត្យ មើលអត្ថបទរួមគ្នា។

អ្នកសម្របសម្រួល : ឥឡូវនេះលោក អ្នកសាកល្បងកិច្ចការសំណេរតាមជំហានខាងក្រោម :

**ជំហានទី១** បង្កើតជាក្រុមតូចៗដែលមានគ្នា ៥-៦ នាក់ ។ ត្រៀមផ្ទាំងក្រដាសធំ និងប៊ិកហ្វឺត ។ ជ្រើសរើសមនុស្សម្នាក់នៅក្នុងក្រុមធ្វើជាអ្នកសរសេរ ។ **អ្នកសម្របសម្រួលសរសេរ ឬ ប្រាប់ឃ្លាផ្ដើម** ។

**ជំហានទី២** គិត និងពិភាក្សាអំពីសម្រាប់សរសេរ និងប្រាប់អ្នកសរសេរនូវអ្វីដែលត្រូវសរសេរ ( មានពេល ១០ នាទីសម្រាប់ការចរចា និងការសរសេរនេះ): នេះ គឺជាសំណេរព្រាងដំបូងរបស់អ្នក ។

**ជំហានទី៣** អានសំណេរព្រាងដំបូងរួមគ្នាឱ្យចប់ ។ ពិភាក្សាកែលំអ ( សរសេរកំណែតម្រូវ លុបចោល ឬ បន្ថែម ) ។

**ជំហានទី៤** ត្រួតពិនិត្យមើលអត្ថបទក្រុមម្ដងទៀត ដោយផ្សៀងនឹងលក្ខណៈវិនិច្ឆ័យលើតារាងបញ្ជីផ្ទៀងផ្ទាត់ខាងក្រោម ។

**ជំហានទី៥** សរសេរអត្ថបទឡើងវិញដោយធ្វើការកែតម្រូវ និងពិនិត្យឡើងវិញ អានមួយចប់ម្ដងទៀត និងធ្វើការកែប្រែចុងក្រោយ ( ឧទាហរណ៍ : អក្ខរាវិរុទ្ធ) ។

**ជំហានទី៦** ឆ្លងក្រុម : ក្រុមនីមួយៗនិយាយអំពីសំណេរព្រាងទី២ អំពីការកែប្រែសំខាន់ៗដែលបានធ្វើរវាងសំណេរព្រាងដំបូង និងសំណេរចុងក្រោយ ។

*អ្នកសម្របសម្រួលសួរ :* ***តើអត្ថបទទាំងនេះបានមកពីណា?***

*ចម្លើយរំពឹងទុក: បានមកពីពួកយើង ។*

*អ្នកសម្របសម្រួលសួរ:* **តើគំនិតប្រើនៅក្នុងអត្ថបទបានមកពីណា?**

*ចម្លើយរំពឹងទុក: បានមកពីការស្រមៃ និងបទពិសោធរបស់ពួកយើង ។*

## តារាងបញ្ជីផ្ទៀងផ្ទាត់ សម្រាប់កិច្ចការសំណេរក្រុម

| លក្ខណៈវិនិច្ឆ័យ | ផ្ទៀងផ្ទាត់ |
|---|---|
| ចំណងជើង | |
| បញ្ចប់ប្រយោគ | |
| វណ្ណយុត្តិ | |
| ជម្រើសពាក្យល្អៗ | |
| លំដាប់ប្រយោគល្អៗ | |
| កថាខណ្ឌ | |
| អត្ថន័យច្បាស់លាស់ ស្តាប់បាន | |
| អក្ខរាវិរុទ្ធ | |
| សេចក្តីសន្និដ្ឋាន | |

## សកម្មភាព 6.3 កិច្ចការគ្រូអំពីសំណេរ 15 នាទី

**សម្ភារ** : សៀវភៅកំណត់ត្រាគ្រូ ។

អ្នកសម្របសម្រួល មានកិច្ចការចំនួនពីរអំពី**សំណេរ**នៅក្នុងសៀវភៅកំណត់ត្រាគ្រូ ។ ឱ្យអ្នកចូលរួមអានសៀវភៅកំណត់ត្រាគ្រូទំព័រ... ។ អ្នកសម្របសម្រួលសួរអ្នកចូលរួមក្រែងពួកគាត់មិនយល់អំពីការណែនាំនៅលើទំព័រទាំងនោះ ។

អ្នកសម្របសម្រួលឆ្លើយសំណួររបស់អ្នកចូលរួម ប្រសិនបើអ្នកចូលរួមគ្មានសំណួរអ្វីទេ អ្នកសម្របសម្រួលត្រូវត្រួតពិនិត្យការយល់របស់អ្នកចូលរួមតាមការសួរពួកគាត់ ៖

*អ្នកសម្របសម្រួលសួរ:* **នៅក្នុងកិច្ចការសំណេរទី១ តើគ្រូគ្រប់ថ្នាក់ទាំងអស់បានធ្វើសកម្មភាពដូចគ្នា និងអនុវត្តតាមដំណើរការដូចគ្នាជាមួយកុមារឬទេ?**

*ចម្លើយរំពឹងទុក : បានធ្វើ ប៉ុន្តែចំនួនសំណេរដែលកុមារធ្វើប្រែប្រួលទៅតាមកំរិតថ្នាក់* ។

*អ្នកសម្របសម្រួលសួរ :* **តើនេះមានន័យថា កិច្ចការទី១នឹងត្រូវការរយះពេលវែង** សម្រាប់**គ្រូថ្នាក់ទី៦ ជាងគ្រូថ្នាក់ ទី១ឬ?**

*ចម្លើយរំពឹងទុក : បាទ/ចាស* ។

*អ្នកសម្របសម្រួលសួរ :* **តើអ្វីខ្លះដែលគ្រូធ្វើនៅក្នុងកិច្ចការទី២?**

*ចម្លើយរំពឹងទុក :* ពួកគាត់អនុវត្តដំណើរការសរសេរ រួមទាំងការប្រជុំពិភាក្សា អំពីកិច្ចការដែលពួកគាត់កំពុងតែធ្វើជាផ្នែកនៃប្រធានបទវាយតម្លៃរបស់ប្រសិទ្ធភាពនៃការបង្រៀន និងរៀន (កិច្ចការទី៦ **ការវិភាគដំណើររឿងរបស់កុមារ**) ។

អ្នកសម្របសម្រួលសន្និដ្ឋានដោយនិយាយថា ៖ សិស្សប្រើបទពិសោធន៍ គំនិត និងការស្រមើលស្រមៃរបស់ខ្លួននៅក្នុងការសរសេរ គឺជាឧទាហរណ៍ល្អមួយនៃអ្វីដែលយើងហៅថា ***ការពិចារណាហ្មត់ចត់*** ។ ប្រធានបទបន្ទាប់នៅក្នុងសិក្ខាសាលានេះ ក៏និយាយផងដែរអំពីការលើកទឹកចិត្តកុមារឱ្យពិចារណាដោយខ្លួនឯងតាមការប្រើកម្រិតសំណួរផ្សេងៗគ្នា ។

## ប្រធានបទទី ៧ វាយតម្លៃ និងកម្រងស្នាដៃសិស្ស

### សកម្មភាព 7.1 ការវាយតម្លៃ 45 នាទី

**សម្ភារៈ** ៖ ផ្ទាំងក្រដាសធំ ប៊ិកហ្វឺត ។

អ្នកសម្របសម្រួល ៖ គ្រូទាំងអស់នៅតាមសាលារៀនលើពិភពលោក ធ្វើការវាយតម្លៃការរៀនសូត្ររបស់សិស្ស ។ មានមូលហេតុជាច្រើនដែលការវាយតម្លៃនេះ តម្រូវឱ្យអ្នកទាំងអស់គ្នាពិចារណាឲ្យច្បាស់លាស់ ។

អ្នកសម្របសម្រួល ៖ អ្នកចូលរួមបង្កើតក្រុមតូចៗ និងពិភាក្សាសំណួរផ្តោតខាងក្រោមរយៈពេល១៥នាទី ៖ **តើចំណុចអ្វីខ្លះដែលសាលារៀន និងគ្រូត្រូវធ្វើការវាយតម្លៃការសិក្សារបស់សិស្ស ?** អ្នកសម្របសម្រួលជ្រើសរើស២ ឬ ៣ក្រុមឱ្យរាយការណ៍ និងឱ្យក្រុមដទៃទៀតបន្ថែមគំនិតផ្សេងទៀត ដែលពួកគេបានសរសេរ ។

បន្ទាប់មកអ្នកសម្របសម្រួល បន្ថែមគំនិតនានា (ពីបញ្ជីខាងក្រោម) បើគំនិតអ្នកចូលរួមនៅខ្វះ ។

***ចម្លើយរំពឹង ៖***

-តើកុមារបានត្រៀមរួចរាល់ដើម្បីឡើងថ្នាក់ឬនៅ (ចំណេះដឹង បំណិន និងឥរិយាបថ) ?

-តើកុមាររៀនបានពូកែឬទេ (អាចអាន/សរសេរ រាប់ ។ល។) ?

-តើកុមារអាចប្រើចំណេះដឹង និងបំណិនរបស់ខ្លួន សម្រាប់ដោះស្រាយបញ្ហាបានឬទេ ?

-តើគ្រូបង្រៀនប្រកបដោយប្រសិទ្ធភាពឬទេ?

-តើកម្មវិធីសិក្សា និងសម្ភារនានាដំណើរការប្រកបដោយប្រសិទ្ធភាព ឬទេ?

-តើសាលារៀនធ្វើការងារបានល្អ ឬទេ?

-ព័ត៌មានអំពីគុណភាពប្រព័ន្ធអប់រំ

-ព័ត៌មានអំពីភាពរីកចម្រើនរបស់សិស្សដែលពួកគេអាចផ្តល់ឱ្យគ្រួសារសិស្ស ។




## សកម្មភាព 7.2 ការវាយតម្លៃការសិក្សារបស់សិស្ស ៣០ នាទី

**សម្ភារ ៖** គ្មាន ។

អ្នកសម្របសម្រួលប្រាប់សិក្ខាកាមឱ្យរំលឹកពីចំនួនសិស្សដែលពុំបានឡើងថ្នាក់/រៀនត្រួតថ្នាក់ (ឬអត្រាឡើងថ្នាក់/រៀនត្រួតថ្នាក់) ក្នុងថ្នាក់របស់ពួកគាត់ក្នុងឆ្នាំសិក្សាកន្លងមក ។ អ្នកសម្របសម្រួលហៅសិក្ខាកាមខ្លះឱ្យនិយាយអំពីអត្រាទាំងនោះ ។

អ្នកសម្របសម្រួល ៖ **តើមូលហេតុអ្វីខ្លះដែលអ្នកសម្រេចចិត្តថា សិស្សគួរតែរៀនត្រួតថ្នាក់ ?** អ្នកសម្របសម្រួលម្នាក់ទៀតសរសេរចម្លើយចូលក្នុងបញ្ជីនៅលើក្ដារខៀន ឬ លើផ្ទាំងក្រដាសធំ ។

**ចម្លើយរំពឹងទុក :**

| | |
|---|---|
| -ធ្វើតែស្តធ្លាក់ | ចំណេះដឹង |
| -អវត្តមានច្រើន | ឥរិយាបថ |
| -ពុំអាចធ្វើកិច្ចការនេះ ឬ កិច្ចការនោះ (រាប់ អាន សរសេរ...) | ចំណេះដឹង និងបំណិន |
| -មិនចូលរួមក្នុងសកម្មភាពសិក្សា | ឥរិយាបថ |
| -ពុំចេះពីរបៀបរៀបចំអត្តចរិត | ចំណេះដឹង ? ឥរិយាបថ ? |
| -ពុំយកចិត្តទុកដាក់លើការងារ | ឥរិយាបថ |

អ្នកសម្របសម្រួលឱ្យអ្នកចូលរួមគិតថាតើមូលហេតុដែលពួកគាត់បានផ្ដល់ឱ្យនេះ ទាក់ទងទៅនឹងចំណេះដឹង បំណិន ឬ តម្លៃឬទេ (ចំណេះដឹង បំណិន ឥរិយាបថ) ។ បន្ទាប់មកអ្នកសម្របសម្រួលអានបញ្ជីមូលហេតុនេះម្ដងមួយៗ និងហៅអ្នកចូលរួមឱ្យដាក់អក្សរ “K” “S” ឬ “A” ដល់វានីមួយៗ ។ អ្នកចូលរួមអាចសរសេរអក្សរច្រើនជាងមួយបាន ប្រសិនបើពួកគាត់ចូលចិត្ត ។

បន្ទាប់មកអ្នកសម្របសម្រួលសួរសំណួរបន្ត : **តើអ្នកបានធ្វើអ្វីខ្លះដើម្បីរកមូលហេតុទាំងនេះអំពីសិស្ស ?** អ្នកសម្របសម្រួលទី២សរសេរចម្លើយនៅលើក្ដារខៀន ។ នៅពេលអ្នកចូលរួមបានផ្ដល់ចម្លើយអ្នកសម្របសម្រួលសរសេរ ចំណងជើងនៅលើបញ្ជី : “ **វិធីវាយតម្លៃ** ” ។ អ្នកសម្របសម្រួលគួរតែពិនិត្យមើលថា អ្នកចូលរួមបានផ្ដល់គំនិតគ្រប់ចម្លើយ រំពឹងទុកទាំងអស់ (ខាងក្រោម) ។

**ចម្លើយរំពឹងទុក :**

-ធ្វើតែស្ត និងកែដាក់ពិន្ទុ

-សួរសំណួរ

-សង្កេតអត្តចរិត

-ស្ដាប់ពួកគេនិយាយ/ពន្យល់

-មើលកិច្ចការសរសេររបស់ពួកគេ

-មើលពួកគេសហការជាមួយសិស្សដទៃ

អ្នកសម្របសម្រួល ៖ ទាំងនេះ គឺជាចម្លើយដ៏ល្អ និងជាមូលដ្ឋានដើម្បីឈានទៅយល់ប្រធានបទបន្ទាប់ គឺប្រភេទនៃការវាយតម្លៃ ។

## សកម្មភាព 7.3 ប្រភេទនៃការវាយតម្លៃ 60 នាទី

**សម្ភារ :** សៀវភៅកំណត់ត្រាគ្រូ ក្រដាសធំ ប៊ិកហ្វឺត ។

អ្នកសម្របសម្រួល ៖ អ្នកអប់រំប្រើពាក្យបច្ចេកទេសដើម្បីពណ៌នាអំពីប្រភេទនៃការវាយតម្លៃខុសៗគ្នា ដែលអ្នកបានសិក្សានៅក្នុងសកម្មភាព ៧.២ ចុងក្រោយ ។ កម្រងពាក្យសំខាន់បួន គឺការវាយតម្លៃផ្លូវការ និងការវាយតម្លៃ

ក្រៅផ្លូវការ ការវាយតម្លៃជាដំណាក់ និងការវាយតម្លៃសរុប ។ ប្រភេទនៃការវាយតម្លៃទាំងនេះមានអធិប្បាយនៅក្នុងសៀវភៅកំណត់ត្រាគ្រូ ។

អ្នកសម្របសម្រួលឱ្យសិក្ខាកាមបង្កើតជាក្រុមតូចៗដើម្បីអានសៀវភៅកំណត់ត្រាគ្រូ និងពិភាក្សារួមគ្នា ។ កិច្ចការសរសេររបស់អ្នកចូលរួម គឺត្រូវយល់ស្របលើការពណ៌នានៃពាក្យវាយតម្លៃទាំងបួនប្រភេទ និងសរសេរដោយសង្ខេបនៅលើក្រដាសធំ ។ នៅខណៈដែលក្រុមទាំងឡាយបញ្ចប់ការអាន និងការពិភាក្សាហើយ អ្នកសម្របសម្រួលហៅក្រុមខ្លះឱ្យអានការពណ៌នារបស់ពួកគាត់ ។ បន្ទាប់មកអ្នកសម្របសម្រួលប្រាប់ក្រុមនោះឱ្យប្រៀបធៀបការពណ៌នារបស់ខ្លួនជាមួយការពណ៌នានៅផ្នែកខាងក្រោយ**សៀវភៅកំណត់ត្រាគ្រូ** ទំព័រ៤៧-៤៨ ។ បន្ទាប់មកទៀតអ្នកសម្របសម្រួលសួរក្រែងសិក្ខាកាមមានសំណួរ ។

អ្នកសម្របសម្រួលសន្និដ្ឋានសកម្មភាពនេះតាមការសួររបស់អ្នកចូលរួមថា តើប្រភេទនៃការវាយតម្លៃមួយណាដែលពួកគាត់គិតថាគួរតែប្រើនៅក្នុងថ្នាក់របស់ខ្លួន ។ ចម្លើយរំពឹងទុក គឺថាគ្រូគួរតែប្រើប្រភេទនៃការវាយតម្លៃខុសៗគ្នាទាំងអស់នោះព្រោះការលាយចម្រុះយុទ្ធវិធីមានភាពប្រសើរជាងគេបំផុត ។

## សកម្មភាព 7.4 កិច្ចការគ្រូអំពីការវាយតម្លៃ 45 នាទី

**សម្ភារ** : សៀវភៅកំណត់ត្រាគ្រូ ។

អ្នកសម្របសម្រួលប្រាប់គ្រូឱ្យមើលកិច្ចការគ្រូអំពីការវាយតម្លៃនៅ***ក្នុងសៀវភៅកំណត់ត្រាគ្រូ*** ។ អ្នកសម្របសម្រួលនិយាយថា មានកិច្ចការសំខាន់ពីរ ប៉ុន្តែការងារត្រូវធ្វើភាគច្រើនអំពីកិច្ចការគ្រូក្នុងការវាយតម្លៃពុំត្រូវបានគេធ្វើរហូតដល់ចុងឆ្នាំ ។

**កិច្ចការទី១** ទាក់ទងនឹងការប្រមូលគំរូការងារពីសិស្ស ៥នាក់ក្នុងថ្នាក់ នៅក្នុងអំឡុងឆ្នាំសិក្សា នៃវគ្គ ។ គំរូការងារត្រូវចងក្រង នៅក្នុងសឺមីទ៥ ។ សឺមីទាំងនេះហៅថា ***កម្រងស្នាដៃសិស្ស*** និងការវាយតម្លៃប្រភេទនេះ *ហៅថា**ការវាយតម្លៃកម្រងស្នាដៃសិស្ស*** ។ គ្រូក៏ត្រូវប្រមូលព័ត៌មានផ្ទាល់ខ្លួនអំពីសិស្សម្នាក់ៗក្នុងចំណោមសិស្សទាំង ៥នាក់ផងដែរ ។ នៅក្នុងអំឡុងឆ្នាំនេះ គ្រូពិនិត្យមើលឡើងវិញ នូវគំរូកិច្ចការ ដើម្បីវាយតម្លៃភាពរីកចម្រើនរបស់សិស្ស តម្រូវការសិក្សារបស់ពួកគេ និងវិធីដែលគ្រូអាចជួយពួកគេ ។ នៅដំណាច់ឆ្នាំ គំរូកិច្ចការទាំងនេះ ជួយគ្រូឱ្យធ្វើការសម្រេចចិត្តអំពីលទ្ធផលនៃរៀនសូត្ររបស់សិស្ស និងថាតើពួកគេអាចឡើងថ្នាក់ បាន ឬមិនបាន ។

**កិច្ចការទី២ :** សិក្សាករណីរបស់សិស្ស **អំពីសិស្សម្នាក់ក្នុងចំណោមសិស្សទាំង៥** ។ គ្រូនឹងសរសេរផ្នែកភាគច្រើននៃការវិភាគសិក្សាករណីនេះ នៅក្នុងសិក្ខាសាលាទាំង២ នៅខែ មេសា និងកក្កដា (ប្រជុំគ្រូម្នាក់ទល់ម្នាក់លើកិច្ចការនេះក្នុងសិក្ខាសាលា) ។

អ្នកសម្របសម្រួលសន្និដ្ឋាន : ក្រសួងអប់រំ យុវជន និងកីឡា កំពុងស្ថិតក្នុងដំណើរការនៃការប្រើប្រាស់ទម្រង់វាយតម្លៃថ្មីមួយ សម្រាប់ការសិក្សារបស់សិស្សផ្អែកលើ " ស្តង់ដា " ។ ឯកសារស្តង់ដាកម្មវិធីសិក្សារបស់ក្រសួងបានពណ៌នាអំពីលទ្ធផលនៃការរៀនសូត្រ : អ្វីៗដែលសិស្សអាចធ្វើ ។ គ្រូនឹងសម្រេចចិត្តថា តើលទ្ធផលរៀនសូត្ររបស់សិស្សនៅដំណាច់ឆ្នាំអាចផ្គូផ្គងជាមួយស្តង់ដា ឬ លើសពីស្តង់ដា ។ ការប្រើប្រាស់ប្រភេទវាយតម្លៃទាំងអស់នឹងជួយគ្រូឱ្យធ្វើការវាយតម្លៃបានច្បាស់លាស់ថា តើសិស្សបានបំពេញស្តង់ដាសិក្សា ឬ មិនបាន ។

# ប្រធានបទទី ៨ ការឆ្លុះបញ្ចាំងគ្រូ ( ស្វ័យវាយតម្លៃ )

## សកម្មភាព 8.1 ការឆ្លុះបញ្ចាំងគ្រូ ជាទំរង់នៃការវាយតម្លៃខ្លួនឯង 45 នាទី

**សម្ភារ : សៀវភៅកំណត់ត្រាគ្រូ ។**

អ្នកសម្របសម្រួល : នៅក្នុងសិក្ខាសាលានេះ យើងបានរៀនរួចហើយអំពីវិធីដែលត្រូវវាយតម្លៃការសិក្សារបស់សិស្ស និងគោលបំណងនៃការវាយតម្លៃនោះ ។ ក្នុងចំណោមគោលបំណងទាំងនោះត្រូវរកឱ្យឃើញថា តើសិស្សកំពុងតែរៀនបានពូកែ និងអភិវឌ្ឍន៍ចំណេះដឹង បំណិន និងឥរិយាបថឬទេ ។ ជួនកាលយើងរកឃើញថា កុមារខ្លះរៀនពុំបានពូកែឡើយ ឬ ថា សិស្សទាំងអស់ជួបបញ្ហាលើផ្នែកខ្លះនៃកម្មវិធីសិក្សា ។

អ្នកសម្របសម្រួលនិយាយថា នៅពេលសិស្សរៀនពុំបានពូកែ គ្រូជាច្រើនអាចនិយាយថា :

*-សិស្សខ្ជិលច្រអូស*

*-សិស្សមានការទើយណាយ*

*-កុមារមិនចាប់អារម្មណ៍ក្នុងការរៀនសូត្រ*

*-កុមារតែងតែមកយឺត/អវត្តមាន/ពុំបានយកចិត្តទុកដាក់*

*-មានសិស្សច្រើនពេកនៅក្នុងថ្នាក់រៀន*

*-កុមារមិនរៀនអ្វីឡើយនៅសាលាកាលពីឆ្នាំទៅ ។ល ។*

មូលហេតុទាំងនេះអាចជាការពិត ប៉ុន្តែវាក៏អាចជាការដោះសារយ៉ាងងាយ សម្រាប់គ្រូដែលពុំបានធ្វើអ្វីសោះ ក្នុងការដោះស្រាយបញ្ហានេះ ។

អ្នកសម្របសម្រួលសួរ : **ប្រសិនបើសិស្សខ្លះ ឬ កុមារទាំងអស់រៀនមិនល្អ តើគ្រូត្រូវធ្វើអ្វីខ្លះ?** អ្នកសម្របសម្រួលទីពីរសរសេរចម្លើយរបស់អ្នកចូលរួម :

**ចម្លើយរំពឹងទុក :**

*-បង្រៀនមេរៀនឡើងវិញ និងបង្រៀនបន្ថែមទៀតនៅផ្នែកខ្លះនៃមេរៀនដែលសិស្សមិនទាន់យល់ច្បាស់*

*-ពន្យល់បន្ថែម*

*-ដាក់សិស្សរៀនយឺត ( រៀនពុំទាន់គេ ) ឱ្យអង្គុយខាងមុខ*

*-ធ្វើការងារដោយផ្ទាល់ជាមួយសិស្សដែលពុំរៀនបានពូកែនៅក្នុងក្រុមតូចៗ*

*-ទុកឱ្យសិស្សរៀនយឺតធ្វើការងារនៅតាមក្រុមចម្រុះគ្នាជាមួយសិស្សដែលយល់មេរៀន*

*-រៀបចំថ្នាក់បំប៉នសិស្សរៀនយឺត*

*-និយាយជាមួយមាតាបិតាអំពីសិស្សឱ្យមករៀនទៀងទាត់ ។*

អ្នកសម្របសម្រួល : លោកអ្នកបានចាប់ផ្តើមអនុវត្តយុទ្ធវិធីមួយទៀត ដែលគ្រូអាចប្រើនៅក្នុងថ្នាក់ទាំងនេះ ។ យុទ្ធវិធីនេះគឺផ្អែកទៅលើការវិភាគ/វាយតម្លៃវិធីដែលខ្លួនធ្វើការងារ និងព្យាយាមគិតអំពីវិធីដទៃទៀតដែលអាច ផ្លាស់ប្តូរការអនុវត្តបាន ។ នេះមានន័យថា ប្រើប្រាស់សម្ភារខុសៗគ្នាបង្កើតសកម្មភាពសិក្សាខុសៗគ្នា ឬ ធ្វើការផ្លាស់ប្តូរការគ្រប់គ្រងថ្នាក់រៀន ដូចជាការផ្លាស់ប្តូរក្រុមសិក្សា ដូចដែលបានលើកឡើងក្នុងប្រធានបទទី១ ) ។

អ្នកសម្របសម្រួល ៖ គ្រូធ្វើការវាយតម្លៃខ្លួនឯង ប្រភេទវាយតម្លៃនេះគេតែងហៅថា "ការឆ្លុះបញ្ចាំងការបង្រៀន" ។ ជាការសំខាន់ណាស់ការគិតឡើងវិញ ហើយឆ្លុះបញ្ចាំងលើការបង្រៀន គឺការផ្លាស់ប្តូរការអនុវត្តផ្ទាល់ខ្លួន របស់គ្រូ ដើម្បីធ្វើឱ្យបានលទ្ធផលល្អប្រសើរ ។

អ្នកសម្របសម្រួល ៖ នៅពេលគ្រូឆ្លុះបញ្ចាំងអំពីការបង្រៀនរបស់ខ្លួនពួកគាត់ត្រូវសួរសំណួរដល់ខ្លួនឯងជារឿយៗ ។ សូមមើលសៀវភៅកំណត់ត្រាគ្រូ អ្នកនឹងរកឃើញវា (អ្នកសម្របសម្រួលសរសេរសំណួរនៅលើក្តារខៀន ខណៈពេលដែលសិក្ខាកាមកំពុងបើកសៀវភៅ) ។

**តើខ្ញុំអាចផ្លាស់ប្តូរការបង្រៀនជាក់ស្តែងរបស់ខ្ញុំតាមវិធីណា ដើម្បីកែលំអការសិក្សា របស់សិស្សក្នុងថ្នាក់ខ្ញុំ ?**



## សកម្មភាព ៤.2 ការឆ្លុះបញ្ចាំងគ្រូ និងការផ្លាស់ប្តូរការអនុវត្តជាក់ស្តែង 60 នាទី

**សម្ភារ** ៖ សៀវភៅកំណត់ត្រាគ្រូ

អ្នកសម្របសម្រួល : ឥឡូវនេះអ្នកចូលរួមបែងចែកក្រុមតូចៗ និងអានព័ត៌មានសម្រាប់គ្រូនៃប្រធានបទទី៨ (ការឆ្លុះបញ្ចាំងគ្រូ) នៅក្នុង**សៀវភៅកំណត់ត្រាគ្រូ** ។ បន្ទាប់ពីបានអានអត្ថបទរួចហើយ អ្នកចូលរួមគួរតែពិភាក្សាអំពីគំនិតសំខាន់ៗរួមគ្នា ។

អ្នកសម្របសម្រួលអង្គុយតាមក្រុមនីមួយៗ ដើម្បីចូលរួមការពិភាក្សា និងសួរសំណួរខ្លះ ដើម្បីជួយដល់ការពិភាក្សា ។

នៅចុងបញ្ចប់នៃការពិភាក្សា អ្នកសម្របសម្រួលនឹងសួរសំណួរសង្ខេបខ្លះៗ (តារាងខាងក្រោម) ដើម្បីឱ្យប្រាកដថា តើគ្រប់គ្នាយល់ពីគំនិតសំខាន់ៗបានច្បាស់ហើយ ឬ នៅ ? ប្រសិនបើមានអ្នកខ្លះនៅមិនទាន់យល់ច្បាស់ ត្រូវសរសេរសំណួរនោះ ដើម្បីឱ្យក្រុមដទៃទៀតជួយផ្តល់គំនិតជាមុន ទើបអ្នកសម្របសម្រួលឆ្លើយ ឬ បំពេញជាក្រោយ ។

| **សំណួរគំរូ សម្រាប់អ្នកសម្របសម្រួល** | **ចម្លើយរំពឹងទុក** |
|---|---|
| តើដំណាក់កាលនៅក្នុងវដ្តនៃការបង្រៀនឆ្លុះបញ្ចាំងមានអ្វីខ្លះ ? | ធ្វើផែនការ - បង្រៀន - ឆ្លុះបញ្ចាំង |
| តើអ្វីទៅជាវដ្ត ? | វដ្ត គឺជាដំណើរការដែលមានដំណាក់កាលដូចៗគ្នានៅក្នុងវា និងសាឡើងវិញដដែលៗ ។ |
| តើ "ឆ្លុះបញ្ចាំង" មានន័យដូចម្តេច ? | ឆ្លុះបញ្ចាំងមានន័យថាយើង(គ្រូ)គិតអំពីអ្វីដែលបានកើតឡើងក្នុងពេលកំពុងបង្រៀន អ្វីដែលដំណើរការទៅល្អ/អ្វីដែលដំណើរមិនល្អ អ្វីដែលសិស្សមានចំណាប់អារម្មណ៍/អ្វីដែលសិស្សមិនចាប់អារម្មណ៍ អ្វីដែលសិស្សយល់បានល្អ អ្វីដែលសិស្សយល់មិនបានល្អ |
| តើគ្រូធ្វើអ្វីខ្លះនៅក្នុងដំណាក់កាលធ្វើផែនការ ? | ប្រើបទពិសោធន៍ទទួលបានពីដំណាក់កាលឆ្លុះបញ្ចាំងមកធ្វើផែនការ ដែលទាក់ទងនឹងការផ្លាស់ប្តូរការបង្រៀនជាក់ស្តែងរបស់យើង តាមវិធីខ្លះដែល យើងគិតថានឹងទទួលបានលទ្ធផលប្រសើរក្នុងការសិក្សារបស់សិស្ស ។ |
| តើគ្រូធ្វើអ្វីខ្លះនៅក្នុងដំណាក់កាលបង្រៀន ? | បង្រៀន!! សាកល្បងការផ្លាស់ប្តូរដែលយើងបានធ្វើផែនការ និងសង្កេតពីផលប៉ះពាល់លើសិស្ស ។ |
| តើគ្រូគួរតែធ្វើផែនការ និងប្រើគំនិតថ្មីៗ (ការផ្លាស់ប្តូរ) គ្រប់មេរៀនឬទេ ? | ទេ នោះគឺច្រើនជ្រុលពេក យើងគួរតែជ្រើសរើសប្រធានបទ និងមេរៀនដែលមានភាពមិនសូវប្រាកដ គិតឱ្យច្រើនអំពីអ្វីដែលអាចផ្លាស់ប្តូរ ព្យាយាមធ្វើដូចនេះ២ ឬ៣ដងក្នុង១សប្តាហ៍ ។ ប្រសិនបើជោគជ័យ នោះយើងអាចប្រើបច្ចេកទេសដូចគ្នានៅក្នុងមេរៀនដទៃ ទៀតដែលទាក់ទងគ្នា ។ |
| ។ល។ និង ។ល។ | |

**សកម្មភាព ៨.3 កិច្ចការឆ្លុះបញ្ចាំងគ្រូ** 20 នាទី

**សម្ភារ** : សៀវភៅកំណត់ត្រាគ្រូ ។

អ្នកសម្របសម្រួល ៖ សូមមើលកិច្ចការ សម្រាប់ការឆ្លុះបញ្ចាំងគ្រូនៅក្នុងសៀវភៅកំណត់ត្រាគ្រូ ។ អាន និងពិភាក្សាជាមួយអ្នកអង្គុយជិត ។ ប្រសិនបើមានចម្ងល់ណាមួយដែលអ្នកមិនអាចឆ្លើយរួចដោយខ្លួនឯង អ្នកអាចសួរនៅចុងម៉ោងបាន ។

ចម្ងល់ត្រូវទុកឱ្យអ្នកចូលរួមឆ្លើយជាមុន ទើបអ្នកសម្របសម្រួលជួយបំពេញបន្ថែមជាក្រោយប្រសិនបើចាំបាច់ ។

ប្រសិនបើអ្នកចូលរួមពុំមានសំណួរទេ នោះអ្នកសម្របសម្រួលត្រូវពិនិត្យការយល់របស់អ្នកចូលរួមដោយសួរ ៖

| **សំណួរអ្នកសម្របសម្រួល** | **ចម្លើយរំពឹងទុក** |
|---|---|
| តើគ្រូម្នាក់ៗគួរតែនាំយកអ្វីខ្លះមកកាន់ អង្គប្រជុំប្រចាំខែ? | *ការអនុវត្តថ្មីៗល្អជាងគេ មួយ ពីរ ឬ បីដែលបានប្រើ និងបញ្ហាធំជាងគេដែលជួប មួយ ពីរ ឬ បី ។* |
| តើគ្រូគួរតែធ្វើអ្វីខ្លះមុនអង្គប្រជុំប្រចាំខែសិក្ខាសាលាចុងក្រោយនៅខែកក្កដា? | *មើលឡើងវិញនូវការអនុវត្តគំនិតថ្មី និងបញ្ហាក្នុងឆ្នាំសិក្សា និងជ្រើសរើសការអនុវត្តគំនិតថ្មីដែលមានប្រសិទ្ធភាពជាងគេបីដែលបានប្រើនៅក្នុងឆ្នាំសិក្សា និងបញ្ហាធំជាងគេបីដែលជួបប្រទះ ។* |
| តើគេអាចសរសេរបញ្ហាទាំងបីដូចៗគ្នាពីខែ១ ទៅខែ១ទៀតបានឬទេ? | *បាន ប្រសិនបើវាជាបញ្ហាធំជាងគេបំផុត ។* |
| តើគេអាចសរសេរការអនុវត្តគំនិតថ្មីល្អជាងគេទាំង ៣ ដូចៗគ្នា ពីខែមួយ ទៅខែមួយទៀតបានឬទេ? | *មិនបានទេ ប្រសិនបើវាដូចគ្នា វាមិនអាចថ្មីបានឡើយ* |
| តើត្រូវចំណាយពេលវេលាយូរប៉ុន្មានដើម្បីសរសេរចម្លើយចំពោះកិច្ចការទាំងនេះ? | *ពីរ ឬ បីនាទី* |

## សកម្មភាព ៥.4 កិច្ចការគ្រូ

45 នាទី

**សម្ភារ** ៖ សៀវភៅកំណត់ត្រាគ្រូ ក្រដាសធំ ប៊ិកហ្វឺត ។

អ្នកសម្របសម្រួល : កិច្ចការគ្រូគឺជាផ្នែកសំខាន់មួយនៃវគ្គប្រសិទ្ធភាពនៃការបង្រៀន និងរៀន ។

អ្នកសម្របសម្រួលសួរ: **ហេតុអ្វីបានជាអ្នកគិតថា ក្រសួងអយក ចង់ឱ្យគ្រូធ្វើកិច្ចការទាំងនេះ ?**

អ្នកសម្របសម្រួលម្នាក់ទៀតសរសេរគំនិតរបស់អ្នកចូលរួមលើក្តារខៀន ។

**ចម្លើយរំពឹងទុកគឺ:**

*-ដើម្បីកែលំអបំណិនបង្រៀន*

*-ដើម្បីកែលំអផលសម្រេចរៀនសូត្រ* សម្រាប់ សិស្ស

*-ដើម្បីបង្កើនភាពមេត្រីក្នុងសាលារៀន*

*-ដើម្បីអនុវត្តន៏គំនិតថ្មីៗនៅក្នុងថ្នាក់រៀន*

*-ដើម្បីអភិវឌ្ឍន៏ការបង្រៀនរបស់ពួកគាត់*

*-ដើម្បីពង្រីកគំនិតល្អៗអំពីការបង្រៀនជាក់ស្តែងពីសាលារៀនមួយទៅសាលារៀនមួយទៀត*

*-ដើម្បីជំរុញការរៀនបង្រៀនជួយគ្រូ និងពង្រឹង "ខ្សែបណ្តាញគ្រូ "*

*-ដើម្បីអភិវឌ្ឍបំណិនរបស់ពួកគាត់ ជាអ្នកស្រាវជ្រាវតាមការធ្វើពិសោធ និងប្រមូលភស្តុតាងអំពីផលប៉ះពាល់ របស់គំនិតថ្មីៗ*

*-ដើម្បីផ្តល់ខ្លឹមសារមួយ និងគោលបំណងច្បាស់លាស់* សម្រាប់ *ការប្រជុំអភិវឌ្ឍវិជ្ជាជីវៈប្រចាំខែ*

អ្នកសម្របសម្រួលសួរ : **តើនរណានឹងទទួលខុសត្រូវឱ្យគ្រូធ្វើកិច្ចការទាំងនេះ ?**

**ចម្លើយរំពឹងទុក** : *យើង ... វាស្រេចតែ លើយើង ( គ្រូ) ក្នុងការសម្រេចចិត្តធ្វើកិច្ចការទាំងនេះ ឬមិនធ្វើ ។*

អ្នកសម្របសម្រួលសួរ: **ហេតុអ្វីក៏អ្នកគិតថាគ្រូអាចជ្រើសរើសធ្វើកិច្ចការទាំងនេះ?** អ្នកសម្របសម្រួលម្នាក់ទៀតសរសេរគំនិតរបស់អ្នកចូលរួម ។

**ចម្លើយរំពឹងទុកគឺ:** *ចម្លើយទាំងអស់ដែលផ្តល់នៅក្នុងសំណួរទី១ បូកបន្ថែម*

*-ដើម្បីយកប្រយោជន៏ពីឱកាស* សម្រាប់ *ការអភិវឌ្ឍផ្ទាល់ខ្លួន/វិជ្ជាជីវៈ*

*-ដើម្បីធ្វើការងារឱ្យបានល្អ* សម្រាប់ *សិស្ស គ្រួសារគេ និងសហគមន៏របស់គេ*

*-ដើម្បីឱ្យគេទទួលស្គាល់ថាជាអ្នកអនុវត្តពូកែមួយរូប ( តាមរយៈការផ្តល់ប័ណ្ណសរសើរ និងប្រាក់រង្វាន់) ។*

# ចប់

# ឧបសម្ព័ន្ធ

ខ្លឹមសារសំខាន់ និងគោលបំណងរបស់សិក្ខាសាលាស្ដីពីប្រសិទ្ធភាពនៃការបង្រៀន និងរៀនមានដូចខាងក្រោមនេះ :

| **សិក្ខាសាលា** | **ខ្លឹមសារសំខាន់ៗ** | **គោលបំណង** |
|---|---|---|
| សិក្ខាសាលា ៦ថ្ងៃ នៅខែកញ្ញា | • ណែនាំអំពីកម្មវិធីការបង្រៀន និងរៀនប្រកបដោយប្រសិទ្ធភាព<br>• សកម្មភាពរៀនសូត្រអំពីប្រធានបទ៨ នៃការបង្រៀន និងរៀនប្រកបដោយប្រសិទ្ធភាព | • ត្រៀមគ្រូសម្រាប់ចូលរួមនៅក្នុងប្រសិទ្ធភាពនៃការបង្រៀន និងរៀន<br>• ផ្ដល់គំនិតថ្មីៗអំពីការបង្រៀន និងរៀន<br>• ចែករំលែកគំនិតជាក់ស្ដែងរវាងគ្រូ |
| សិក្ខាសាលា ១ថ្ងៃ នៅខែមេសា ប្រជុំ១ថ្ងៃ | • ពិនិត្យឡើងវិញនូវភាពរីកចម្រើនលើប្រសិទ្ធភាពការបង្រៀន និងរៀន ក្នុងរយៈ ពេល៧ខែ<br>• សកម្មភាពរៀនសូត្រអំពីប្រធានបទទី៤ និងទី៨ (ការវាយតម្លៃ និងការឆ្លុះបញ្ចាំងគ្រូ) | • ការវាយតម្លៃជាដំណាក់អំពីវគ្គប្រសិទ្ធភាពនៃការបង្រៀន និងរៀន<br>• បង្កើតកិច្ចការចុងក្រោយ សម្រាប់ប្រធានបទទី៤ និងទី៨ |
| សិក្ខាសាលា ១ថ្ងៃ នៅខែកក្កដា និងប្រជុំ១ថ្ងៃ | • ពិនិត្យឡើងវិញនូវការងារអំពីប្រសិទ្ធភាពការបង្រៀន និងរៀនក្នុងឆ្នាំ<br>• ធ្វើផែនការ និងអនុសាសន៍ សម្រាប់ឆ្នាំបន្ទាប់ | • ជួយគ្រូឱ្យធ្វើកិច្ចការបានចប់ពេញលេញ<br>• វាយតម្លៃវគ្គប្រសិទ្ធភាពនៃការបង្រៀន និងរៀន<br>• ផ្ដល់អនុសាសន៍សម្រាប់ ប្រសិទ្ធភាពនៃការបង្រៀន និងរៀន ទៅថ្ងៃអនាគត |

# កម្មវិធីបំប៉នឯកសារប្រសិទ្ធភាពនៃការបង្រៀន និងរៀន ក្នុងឆ្នាំសិក្សា

| ខែ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ការបំប៉ន ជាប់ៗគ្នា | ៦ ថ្ងៃ<br>បំប៉នគ្រូឧទ្ទេស<br>និង<br>៦ ថ្ងៃ<br>បំប៉នគ្រូបង្រៀន | | | | | | | សិក្ខាសាលា<br>វាយតម្លៃ<br>១ថ្ងៃសម្រាប់<br>គ្រូ | | | សិក្ខាសាលា<br>វាយតម្លៃ<br>១ថ្ងៃសម្រាប់<br>គ្រូ | |
| ប្រជុំប្រចាំខែ | | ប្រជុំ១<br>១ថ្ងៃ | ប្រជុំ២<br>១ថ្ងៃ | ប្រជុំ៣<br>១ថ្ងៃ | ប្រជុំ៤<br>១ថ្ងៃ | ប្រជុំ៥<br>១ថ្ងៃ | ប្រជុំ៦<br>១ថ្ងៃ | ប្រជុំ៧<br>១ថ្ងៃ | ប្រជុំ៨<br>១ថ្ងៃ | ប្រជុំ៩<br>១ថ្ងៃ | ប្រជុំ១០<br>១ថ្ងៃ | |
| អនុវត្តក្នុងថ្នាក់រៀន | | ការអនុវត្តក្នុងថ្នាក់រៀន ពេញមួយឆ្នាំសិក្សា ទាក់ទងនឹងការសង្កេត និងកិច្ចការសរសេរងាយៗ រៀងរាល់អង្គប្រជុំប្រចាំខែដែលត្រូវពិនិត្យឡើងវិញនៅពេលប្រជុំខែបន្ទាប់ ។ គ្រូជួបគ្នាក្រៅផ្លូវការចន្លោះការប្រជុំប្រចាំខែ សម្រាប់ជាផ្នែកនៃបណ្ដាញសាលារៀន ដែលពួកគាត់បង្កើតដោយខ្លួនឯង ទៅតាមស្ថានភាពមូលដ្ឋានរបស់គាត់ ។ | | | | | | | | | | |

ការបំប៉នជាប់ៗគ្នា : ៦ថ្ងៃ + ១ថ្ងៃ + ១ថ្ងៃ (* វាយតម្លៃ/ធ្វើផែនការ " ឆ្លុះបញ្ចាំងការងារកន្លងមក និងធ្វើផែនការបន្ត ")

ការប្រជុំប្រចាំខែ : ១០ថ្ងៃ (ទាក់ទងនឹងការពិនិត្យកិច្ចការឡើងវិញ ខ្លឹមសារថ្មី សកម្មភាព និងការរៀបចំកិច្ចការ)

ការអនុវត្តក្នុងបន្ទប់រៀន : សាកល្បងគំនិតថ្មីៗ ធ្វើកិច្ចការងាយៗ ការសន្ទនាជាមួយគ្រូគ្នាឯង...

# បញ្ជីកិច្ចការតាមប្រធានបទត្រូវធ្វើប្រចាំឆ្នាំ

| ល.រ | ប្រធានបទ | កិច្ចការ | ចំណងជើង | ពេលកំណត់ | បានពិភាក្សា | ផ្សេងៗ |
|---|---|---|---|---|---|---|
| ១ | ការគ្រប់គ្រងបន្ទប់រៀន | ១ | ប្លង់បន្ទប់រៀន ១ | ដើមខែតុលា | ប្រជុំខែតុលា | |
| | | ២ | ប្លង់បន្ទប់រៀន ២ និងការប្រែប្រួល | ដើមខែមីនា | ប្រជុំខែមីនា | |
| | | ៣ | ប្លង់បន្ទប់រៀន ៣ និងការប្រែប្រួល | ដើមខែមិថុនា | ប្រជុំខែមិថុនា | |
| ២ | សំណួរពិចារណាហ្មត់ចត់ | ១ | ការពិចារណាហ្មត់ចត់ ១ | ដើមខែមករា | ប្រជុំខែមករា | |
| | | ២ | ការពិចារណាហ្មត់ចត់ ២ | ដើមខែកុម្ភៈ | ប្រជុំខែកុម្ភៈ | |
| ៣ | ល្បែងសិក្សា | ១ | ល្បែងសិក្សា ១ គណិតវិទ្យា | ដើមខែវិច្ឆិកា | ប្រជុំខែវិច្ឆិកា | |
| | | ២ | ល្បែងសិក្សា ២ ភាសា | ដើមខែធ្នូ | ប្រជុំខែធ្នូ | |
| | | ៣ | ល្បែងសិក្សា ៣ សិក្សាសង្គម | ដើមខែកុម្ភៈ | ប្រជុំខែកុម្ភៈ | |
| | | ៤ | ល្បែងសិក្សា ៤ វិទ្យាសាស្ត្រអនុវត្ត | ដើមខែមេសា | ប្រជុំខែមេសា | |
| ៤ | ការវាយតម្លៃ | ១ | ជ្រើសរើសសិស្សដើម្បីរៀបចំកម្រងស្នាដៃ | ដើមខែតុលា | ប្រជុំខែតុលា | |
| | | ២ | ប្រមូលកម្រងស្នាដៃសិស្ស | ដើមខែវិច្ឆិកា | ប្រជុំខែវិច្ឆិកា | |
| | | ៣ | ប្រមូលកម្រងស្នាដៃសិស្ស | ដើមខែកុម្ភៈ | ប្រជុំខែកុម្ភៈ | |
| | | ៤ | ប្រមូលកម្រងស្នាដៃសិស្ស | ដើមខែមេសា | ប្រជុំខែមេសា | |
| | | ៥ | ប្រមូលកម្រងស្នាដៃសិស្ស | ដើមខែមិថុនា | ប្រជុំខែមិថុនា | |
| | | ៦ | -សិក្សាករណីដំណើររឿងសិស្ស-ប្រជុំ<br>-សិក្សាករណីដំណើររឿងសិស្ស-ព្រាង | សិក្ខាសាលា១ថ្ងៃ ខែមេសា | សិក្ខាសាលា១ថ្ងៃ ខែកក្កដា | |
| | | ៧ | ពិនិត្យឡើងវិញនូវកម្រងស្នាដៃសិស្ស | សិក្ខាសាលា១ថ្ងៃ ខែកក្កដា | សិក្ខាសាលា១ថ្ងៃ ខែកក្កដា | |
| ៥ | ការប្រើធនធានសំបូរបែបក្នុងថ្នាក់រៀន | ១ | ប្រើផ្ទាំងរូបភាព | ដើមខែវិច្ឆិកា | ប្រជុំខែវិច្ឆិកា | |
| | | ២ | ប្រើផែនទី | ដើមខែមករា | ប្រជុំខែមករា | |
| ៦ | អំណាន | ១ | អំណាន ១ | ដើមខែធ្នូ | ប្រជុំខែធ្នូ | |
| | | ២ | អំណាន ២ | ដើមខែមករា | ប្រជុំខែមករា | |
| ៧ | សំណេរ | ១ | សំណេរ ១ ព្រាង និងប្រជុំ | ដើមខែមីនា | ប្រជុំខែមីនា | |
| | | ២ | សំណេរ ២ អត្ថបទចរចារ | ដើមខែមេសា | ប្រជុំខែមេសា | |
| ៨ | ការឆ្លុះបញ្ចាំង គ្រូ | ១ | ការឆ្លុះបញ្ចាំងគ្រូប្រចាំឆ្នាំ | សិក្ខាសាលា១ថ្ងៃ | សិក្ខាសាលា១ថ្ងៃ ខែកក្កដា | |
| | | ២ | ឆ្លុះបញ្ចាំងការងារកន្លងមក និងធ្វើផែនការបន្ត | សិក្ខាសាលា១ថ្ងៃ | សិក្ខាសាលា១ថ្ងៃ ខែកក្កដា | |

**<u>កំណត់សំគាល់</u>** : ក្នុងកូឡោនផ្សេងៗ គ្រូត្រូវគូសជាសញ្ញា ✓ នូវកិច្ចការដែលបានធ្វើហើយ ។

# ការប្រជុំប្រចាំខែ

**សម្ភារ** : សៀវភៅកំណត់ត្រាគ្រូ តារាងទី១: របៀបវារៈគំរូ សម្រាប់ការប្រជុំប្រចាំខែ

អ្នកសម្របសម្រួលនិយាយថា : ការប្រជុំប្រចាំខែមានសារសំខាន់ពីព្រោះវាជាឱកាស

- នៅពេលគ្រូមកពីសាលារៀនផ្សេងៗគ្នា អាចផ្លាស់ប្តូរបទពិសោធន៍គ្នា
- សម្រាប់គ្រូរៀនពីគ្នាទៅវិញទៅមក (ខ្សែបណ្តាញគ្រូគ្នាឯង)
- សម្រាប់គ្រូមានបទពិសោធន៍ជួយគ្រូថ្មីៗ
- សម្រាប់ពង្រីកគំនិតល្អៗពីសាលារៀនមួយទៅសាលារៀនមួយទៀតអំពីការបង្រៀន និងការរៀន

គោលបំណងសំខាន់នៃការប្រជុំប្រចាំខែគឺផ្តល់ជាវេទិកា ។ អ្នកសម្របសម្រួលមូលដ្ឋាន ( នាយក និងនាយករងកម្រង នាយក នាយករងសាលា និងប្រធានក្រុមបច្ចេកទេស ) មានតួនាទីសំខាន់នៅក្នុងការលើកទឹកចិត្តគ្រូឱ្យនិយាយអំពីការអនុវត្ត របស់ពួកគាត់ និងបញ្ហាដែលពួកគាត់កំពុងតែជួបប្រទះ ។

អ្នកសម្របសម្រួលនិយាយថា: កិច្ចការគ្រូនឹងជួយផ្តល់រចនាសម្ព័ន្ធមួយ សម្រាប់ការប្រជុំប្រចាំខែ ។ គ្រូអាចចាប់ផ្តើម ការប្រជុំប្រចាំខែពួកគាត់ទាំងអស់គ្នា ប៉ុន្តែបន្ទាប់មកត្រូវបែងចែកតាមក្រុមកម្រិតថ្នាក់សម្រាប់ធ្វើសកម្មភាពឱ្យកាន់តែពិស្តារ ។ សកម្មភាពសំខាន់ពីរនៅតាមក្រុមកម្រិតថ្នាក់ គឺ :

១. និយាយអំពីកិច្ចការដែលគ្រូបានបំពេញនៅក្នុងខែមុន និងអំពីបទពិសោធន៍ពួកគាត់ទាំងល្អ និងទាំងមិនល្អ ។ គ្រូខ្លះ ដែលទទួលបានលទ្ធផលល្អ អាចប្រើសៀវភៅកំណត់ត្រារបស់គាត់ ប្រាប់គ្រូដទៃទៀតនូវអ្វីដែលគាត់បានធ្វើ ។ គ្រូផ្សេងទៀតអាចសួរគាត់ឱ្យធ្វើបង្ហាញសកម្មភាពសិក្សាខ្លះៗ ។ អ្នកសម្របសម្រួលមូលដ្ឋាន អាចជួយដោយ ធ្វើការសង្ខេបគំនិតល្អៗផ្សេងៗគ្នា ដែលគ្រូបាន និងកំពុងតែប្រើ ។

២. និយាយអំពីកិច្ចការដែលគ្រូនឹងធ្វើនៅចន្លោះការប្រជុំប្រចាំខែនេះ និងខែបន្ទាប់ ។ នេះមានន័យថា អានការ ណែនាំទាំងអស់គ្នាមួយចប់ ពិភាក្សាវា និងព្រមព្រៀងលើអ្វីដែលគួរធ្វើ ។

អ្នកសម្របសម្រួលចែកគំរូរបៀបវារៈ នឹងនិយាយថា របៀបវារៈសម្រាប់ការប្រជុំប្រចាំខែអាចមានរាងដូចនេះ :

# គំរូរបៀបវារៈ សម្រាប់ការប្រជុំប្រចាំខែ

| | ចំណងជើងសកម្មភាព | ខ្លឹមសារសំខាន់ៗ | អ្នកសម្របសម្រួល/ប្រធាន | ពេល |
|---|---|---|---|---|
| ១ | ប្រជុំគ្រូ<br>(ថ្នាក់ទី១-៦ ទាំងអស់) | ***ព័ត៌មានពីក្រសួងអយក***<br>ការណែនាំថ្នាក់ជាតិ<br>ការណែនាំថ្នាក់ខេត្ត<br>ការណែនាំថ្នាក់ស្រុក/កម្រង<br>ព័ត៌មានមូលដ្ឋានដទៃទៀត | នាយកកម្រង | ៦០ នាទី |
| | | **កម្មវិធីប្រសិទ្ធភាពនៃការបង្រៀន និងរៀន**<br>ការពិភាក្សាទូទៅ ព័ត៌មានទូទៅ<br>ការរីកចម្រើន យោបល់កែលំអ | នាយកកម្រង និង<br>អ្នកសម្របសម្រួលមូលដ្ឋាន | |
| ២ | ក្រុមកម្រិតថ្នាក់ | ***ចែករំលែកលទ្ធផលកិច្ចការ***<br>ការពិភាក្សាតាមក្រុមតូចៗ<br>ការជ្រើសរើសគំនិតល្អៗ | នាយករង/ប្រធានក្រុម<br>បច្ចេកទេស | ៦០ នាទី |
| ៤ | ក្រុមកម្រិតថ្នាក់ | **បទបង្ហាញ**<br>ការពន្យល់/ការធ្វើបង្ហាញអំពី<br>គំនិតបង្រៀនល្អៗ | គ្រូ | ៤៥ នាទី |
| ៥ | ក្រុមកម្រិតថ្នាក់ | **ការរៀបចំ** សម្រាប់ **កិច្ចការ ទៅអនាគត :**<br>-ការអានកិច្ចការ<br>-ការពិភាក្សាកិច្ចការ<br>-សំណួរ និងចម្លើយ | នាយករង/ប្រធានក្រុម<br>បច្ចេកទេស | ៤៥ នាទី |
| ៦ | ប្រជុំក្រុមទាំងមូល | **សកម្មភាពពិនិត្យឡើងវិញនៅ អង្គប្រជុំ**<br>បញ្ហាដែលលេចឡើង<br>បញ្ហាសម្ភារ/ការផ្គត់ផ្គង់<br>បញ្ហាធ្វើផែនការ | នាយកកម្រង និង<br>អ្នកសម្របសម្រួលមូលដ្ឋាន | ៣០ នាទី |
| | | | | **៤ ម៉ោង** |

របៀបវារៈនេះ គ្រាន់តែជាគំរូប៉ុណ្ណោះ អាចធ្វើការផ្លាស់ប្តូរទៅតាមការជាក់ស្តែង ។ សកម្មភាពដែលបានដាក់ពណ៌ បញ្ជាក់ទាំងពីរ ជាសកម្មភាពដែលមានសារសំខាន់ជាងគេបំផុត សម្រាប់រក្សានូវកម្មវិធីប្រសិទ្ធភាពនៃ ការបង្រៀន និងរៀន និងមិនគួរជំនួសបានឡើយ ។

# សាលាកុមារមេត្រី និងប្រសិទ្ធភាពការបង្រៀន និងរៀន

## ( គោលបំណង វត្ថុបំណង និងវិធីសាស្ត្រ )

**សម្ភារ** : សៀវភៅកំណត់ត្រាគ្រូ

អ្នកសម្របសម្រួលហៅអ្នកចូលរួមឱ្យរាប់ឈ្មោះសមាសភាគទាំង៦នៃកម្មវិធីសាលាកុមារមេត្រី ( ប្រសិនបើពួកគាត់ពុំដឹង ពួកគាត់គួរតែព្យាយាម និងរកចម្លើយនៅក្នុងសៀវភៅកំណត់ត្រាគ្រូ) ។ អ្នកសម្របសម្រួលម្នាក់ទៀតសរសេរគំនិតរបស់អ្នកចូលរួមនៅលើក្តារខៀន/ផ្ទាំងក្រដាសធំ ។

អ្នកសម្របសម្រួលនិយាយថា ការបំប៉នអំពីប្រសិទ្ធភាពនៃការបង្រៀន និងរៀន គឺជាសមាសភាគទី២ ដែលទាក់ទងទៅនឹងកម្មវិធីសាលាកុមារមេត្រី ។

អ្នកសម្របសម្រួលពន្យល់ថា សៀវភៅកំណត់ត្រាគ្រូ មានព័ត៌មានអំពីកម្មវិធីសាលាកុមារមេត្រីទាំងមូល ដែលប្រាប់ពីប្រសិទ្ធភាពនៃការបង្រៀន និងរៀន ។ អ្នកសម្របសម្រួលឱ្យអ្នកចូលរួមមើលទំព័រខ្លឹមសារ នៃសៀវភៅកំណត់ត្រាគ្រូ ដើម្បីរកទំព័រឱ្យត្រូវទៅតាមសមាសភាគនីមួយៗ ។ អ្នកសម្របសម្រួលឱ្យសិក្ខាកាមម្នាក់ៗស្វែងយល់ គោលបំណង និងវត្ថុបំណងក្នុងសៀវភៅកំណត់ត្រាគ្រូ និងអានឱ្យឮ ។

បន្ទាប់មកអ្នកសម្របសម្រួលនិយាយថា សិក្ខាសាលានេះនឹងប្រើវិធីសាស្ត្ររៀនសូត្រដោយមានការចូលរួម ។ នេះមានន័យថា អ្នកចូលរួមនឹងត្រូវចំណាយពេលវេលាយ៉ាងច្រើននៅក្នុងសិក្ខាសាលាដើម្បីធ្វើកិច្ចការរៀនសូត្រ ហើយអ្នកសម្របសម្រួលពុំមែនជាអ្នកចំណាយពេលច្រើនក្នុងការនិយាយ និងពន្យល់ឡើយ ។ ដើម្បីបំពេញកិច្ចការរៀនសូត្រ អ្នកចូលរួមត្រូវប្រើបទពិសោធន៍របស់ខ្លួនឯងក្នុងការបង្រៀន និងគំនិតរបស់ខ្លួនឯង អំពីប្រសិទ្ធភាពនៃការបង្រៀន និងរៀនប្រកប ។

# គ្រូឧទ្ទេស និងតួនាទី

គ្រូឧទ្ទេសនៃកម្មវិធីប្រសិទ្ធភាពនៃការបង្រៀន និងរៀនអាចជ្រើសរើសចេញពីបុគ្គលិកនៃការិយាល័យថ្នាក់ខេត្ត ឬ ថ្នាក់ស្រុក សាលាគរុកោសល្យ និងវិក្រឹតការខេត្ត ឬអាចជានាយកសាលាឆ្នើម ឬ គ្រូឆ្នើមមកពីសាលានានានៅក្នុងខេត្ត ។ គ្រូឧទ្ទេសនៃកម្មវិធីប្រសិទ្ធភាពនៃការបង្រៀន និងរៀននឹងធ្វើសិក្ខាសាលាបំប៉នជាមួយគ្រូ និងអ្នកសម្របសម្រួលមូលដ្ឋាន ។ បន្ទាប់ពីធ្វើ សិក្ខាសាលារួច អ្នកសម្របសម្រួលមូលដ្ឋាននឹងធ្វើសកម្មភាពពិនិត្យតាមដានជាមួយគ្រូនៅពេលប្រជុំប្រចាំខែ និង នៅតាមសាលារៀន ។

គ្រូឧទ្ទេសត្រូវមានចំណេះដឹងល្អគ្រប់ផ្នែកទាំងអស់របស់វគ្គ ព្រមជាមួយនឹងឯកសារប្រសិទ្ធភាពការបង្រៀន និងរៀន ហើយក៏ត្រូវមានចំណេះដឹងល្អ អំពីកម្មវិធីសាលាកុមារមេត្រី ពីព្រោះប្រសិទ្ធភាពនៃការបង្រៀន និងរៀន (សមាសភាគទី២) ជាផ្នែកតែមួយគត់នៃក្របខ័ណ្ឌទូលំទូលាយរបស់កម្មវិធីសាលាកុមារមេត្រី ។ វាក៏មានសារសំខាន់ដែរថា គ្រូឧទ្ទេសត្រូវមាន បទពិសោធន៍ខ្លះអំពីការងារនៅសាលាបឋមសិក្សានៅក្នុងពេលថ្មីៗនេះ ជាពិសេសបទពិសោធន៍ជោគជ័យក្នុងនាមជាគ្រូប្រចាំ ថ្នាក់ ។

គ្រូឧទ្ទេសនៃកម្មវិធីប្រសិទ្ធភាពនៃការបង្រៀន និងរៀនទទួលខុសត្រូវក្នុងការរៀបចំ និងអនុវត្តសកម្មភាពរៀនសូត្រ នៅក្នុងសិក្ខាសាលាស្តីពីប្រសិទ្ធភាពនៃការបង្រៀន និងរៀនដែលបានអធិប្បាយនៅក្នុងសៀវភៅនេះ ។ គាត់នឹងត្រូវធ្វើសកម្មភាព បង្ហាញ និងផ្តល់ការពន្យល់ខ្លះៗ ។ ប៉ុន្តែតួនាទីចំបងរបស់គ្រូឧទ្ទេស គឺត្រូវជួយគ្រូឱ្យឆ្លើយសំណួរ និងធ្វើកិច្ចការដែលមាននៅ ក្នុងសិក្ខាសាលា ។ គ្រូបង្រៀននឹងរៀនបានពូកែ តាមការធ្វើសកម្មភាពរៀនសូត្រទាំងនេះដោយខ្លួនឯង ។ ដូច្នេះតួនាទីចម្បង របស់គ្រូឧទ្ទេស គឺជាអ្នកសម្របសម្រួល ។ ការអនុវត្តតាមវិធីនេះមានន័យថា គ្រូឧទ្ទេសប្រើវិធីដូចគ្នានឹងវិធីដែលគាត់លើក ទឹកចិត្តគ្រូឱ្យប្រើនៅក្នុងថ្នាក់រៀនរបស់គាត់ ។ វិធីនេះហៅថា គោលវិធីសិស្សមជ្ឈមណ្ឌល ឬអ្នករៀនមជ្ឈមណ្ឌល និងពេលខ្លះ រៀនសូត្រដោយមានការចូលរួម ។

គ្រូឧទ្ទេសនៃកម្មវិធីប្រសិទ្ធភាពនៃការបង្រៀន និងរៀនភាគច្រើនមិនមានពាក់ព័ន្ធនៅក្នុងការពិនិត្យតាមដានជាទៀងទាត់ ទៅលើគ្រូនៅតាមសាលា និងតាមកម្រង ។ អ្នកសម្របសម្រួលមូលដ្ឋាននឹងទទួលខុសត្រូវលើការជួយគ្រូនៅពេលប្រជុំក្នុង កម្រងនៅតាមសាលា ឬ ការិយាល័យអប់រំ យុវជន និងកីឡាស្រុក/ខណ្ឌ តំបន់ដាច់ស្រយាល ។ អ្នកសម្របសម្រួលតាម មូលដ្ឋានអាចជាបុគ្គលិកបច្ចេកទេសកម្រង (ប្រធាន/អនុប្រធានកម្រង នាយក/រងសាលារៀន ប្រធានក្រុមបច្ចេកទេស) ឬ ក្នុងករណីនៅតំបន់ដាច់ស្រយាល ជាបុគ្គលិកមកពីការិយាល័យអប់រំ យុវជន និងកីឡាស្រុក/ខណ្ឌ ឬ គ្រូចល័ត (គ្រូមាន បទពិសោធន៍ ឬ មានបច្ចេកទេសខ្ពស់) ។ គ្រូខ្លួនឯងជាអ្នកទទួលខុសត្រូវ អនុវត្តសកម្មភាពបង្រៀន និងរៀនប្រកបដោយ ប្រសិទ្ធភាពភាគច្រើននៅក្នុងថ្នាក់រៀន និងសាលារៀនរបស់គាត់នៅក្នុងឆ្នាំសិក្សា ។

# បំណិនរបស់គ្រូឧទ្ទេស

មនុស្សគ្រប់រូបពុំមែនសុទ្ធតែជាគ្រូឧទ្ទេសល្អដោយស្វ័យប្រវត្តិឡើយ ទោះបីជាអ្នកនោះមានបទពិសោធន៍ច្រើន និងមានសញ្ញាប័ត្រខ្ពស់ក៏ដោយ ជួនកាលអាចរចាគ្រូឧទ្ទេសមិនទាន់ល្អដែរ ។ បញ្ហាដែលគេជួបប្រទះច្រើនបំផុតអំពីគ្រូឧទ្ទេសគឺ :

- ពុំបានត្រៀមឱ្យបានត្រឹមត្រូវ និងពុំដឹងអំពីអ្វីដែលគាត់ត្រូវនិយាយ
- ពុំធ្លាប់អនុវត្តជាក់ស្តែងសោះអំពីគំនិតដែលគាត់ធ្វើបទបង្ហាញ
- ភ្លេចថា គោលបំណងសំខាន់នៃការអប់រំគឺជួយជំរុញអ្នករៀនសូត្រឱ្យរៀន
- ចង់បង្ហាញអំណួតអំពីចំណេះដឹងរបស់ខ្លួន ដែលជាហេតុធ្វើឱ្យគាត់និយាយច្រើនជ្រុល
- មិនដែលនិយាយថា "ខ្ញុំមិនចេះទេ" ទោះបីជាគាត់ពុំមានយុទ្ធសាស្ត្រ បទពិសោធន៍ ឬគំនិតតិចតួចក្នុងការឆ្លើយ ឬដោះស្រាយបញ្ហាក៏ដោយ
- ភ្លេចថាពួកគាត់កំពុងតែបង្រៀនមនុស្សធំដែលមានបទពិសោធន៍ និងគំនិតផ្ទាល់ខ្លួន

គ្រូឧទ្ទេសដែលមានប្រសិទ្ធភាព គួរតែចេះ :

- ធ្វើបង្ហាញដោយមានការជឿជាក់ និងនិយាយយ៉ាងច្បាស់អំពីប្រធានបទទាំងអស់ នៅក្នុងវគ្គបំប៉នអំពីប្រសិទ្ធភាពនៃការបង្រៀន និងរៀន (នេះគឺជាតម្រូវការមូលដ្ឋាននៅក្នុងការត្រៀមធ្វើការបំប៉ន)
- ធ្វើជាគំរូនូវប្រភេទគរុកោសល្យ ដែលគាត់រំពឹងឱ្យគ្រូប្រើជាមួយសិស្ស ។ ដូច្នេះ ប្រសិនបើគាត់ជំរុញគ្រូឱ្យប្រើវិធីសាស្ត្រដោយមានការចូលរួមជាមួយសិស្ស គាត់គួរតែប្រើជាមួយគ្រូនៅក្នុងការបំប៉ននេះ ។
- ណែនាំកិច្ចការឱ្យច្បាស់ដាក់ឱ្យគ្រូធ្វើដោយខ្លួនឯង ដោយពុំចាំបាច់ផ្តល់នូវធនធានដាក់បញ្ចូលបន្ថែមទៀតឡើយ លុះត្រាតែគ្រូពិតជាជាប់គាំង ឬមានសំណូមពរនេះគឺ ជាបំណិនមូលដ្ឋាននៃការសម្របសម្រួល
- ដើម្បីឆ្លើយសំណួរខ្លះដែលគ្រូបានសួរ ដំបូងត្រូវសួរសំណួរនេះដល់គ្រូដទៃទៀតសិន
- ធ្វើរាល់សកម្មភាពទាំងអស់ដោយខ្លួនឯងឱ្យបានច្រើនដងដើម្បីយល់ដឹង និងឆ្លើយតបទៅនឹងបញ្ហាដែលគ្រូមាន (នេះ គឺជាតម្រូវការមូលដ្ឋាននៅក្នុងការត្រៀមធ្វើការបំប៉ន)
- ពិនិត្យមើលឡើងវិញនូវចម្លើយកិច្ចការរបស់អ្នកចូលរួម និងផ្តល់យោបល់ស្ថាបនា ។ នេះពុំមែនមានន័យថាធ្វើឡើងវិញនូវអ្វីៗទាំងអស់ដែលអ្នកចូលរួមបាននិយាយរួចហើយនោះឡើយ ឬ ក៏មិនមែនមានន័យថា ស្វែងរកអ្វីដែលអ្នកចូលរួមបាននិយាយ មិនត្រូវទាំងស្រុងនោះឡើយ ។ វាពិតជាពុំមែនមានន័យថាកែតម្រូវអក្ខរាវិរុទ្ធ លើរបាយការណ៍របស់អ្នកចូលរួមដោយប្រើប៊ិចក្រហមទេ ។ ការចាប់ផ្តើមផ្តល់យោបល់កែលំអដល់កិច្ចការគ្រូគប្បីលើកសរសើរនូវអ្វីដែលត្រូវ និងល្អរបស់គ្រូ (ការពង្រឹង បន្ថែមជាវិជ្ជមាន) ។ បន្ទាប់មកគ្រូឧទ្ទេសអាចលើកយកបញ្ហាណាមួយប្រសិនបើគ្រូឧទ្ទេសចង់ផ្តល់យោបល់អវិជ្ជមានគាត់គួរតែលើកជាបញ្ហាឡើង "ការធ្វើដូចនេះប្រហែលជាមិនដំណើរការកើតឡើយ" "នេះមានភាពច្រឡំបល់" "នេះផ្ទុយនឹងអ្វីដែលអ្នកបាននិយាយនៅទីនេះ" (នេះគឺជាបំណិនមូលដ្ឋាននៃការសម្របសម្រួល) ។ យោលប់មានប្រយោជន៍ជាងគេបំផុតដែលអ្នកសម្របសម្រួលអាចផ្តល់ឱ្យ គឺការទទួលស្គាល់នូវគំនិតល្អរបស់អ្នកចូលរួម និងត្រូវបន្ថែមអ្វីដែលសំខាន់ដែលអ្នកចូលរួមពុំបានមើលឃើញ (នេះជាបំណិនមូលដ្ឋាននៃ ការសម្របសម្រួល) ។

ប្រសិនបើគ្រូឧទ្ទេសរកឃើញកំហុសឆ្គង (អក្ខរាវិរុទ្ធ កំហុសនៃការគណនា) គាត់គួរតែផ្តល់ឱកាសឱ្យគ្រូធ្វើការកែតម្រូវដោយខ្លួនឯង ជាមុនសិន ។ គាត់អាចធ្វើដូចនេះដោយនិយាយថា "តើនេះត្រឹមត្រូវឬទេ?" "តើអ្នកយល់ស្របនឹងគំនិតនេះទេ" "នេះមើលទៅពុំត្រូវទេ" "តើចំណុចនេះខុសអ្វី" ជំនួសឱ្យការកែតម្រូវដោយប៊ិកក្រហមនៅលើកិច្ចការរបស់គ្រូ ។

# គ្រូបង្រៀនសាលាកុមារមេត្រី

## សារៈសំខាន់នៃគ្រូបង្រៀននៅក្នុងសាលាកុមារមេត្រី

## ឯកសារប្រសិទ្ធភាពនៃការបង្រៀន និងរៀន សម្រាប់អភិវឌ្ឍវិជ្ជាជីវៈ

## គ្រូបង្រៀន គឺជាគន្លឹះសម្រាប់អនុវត្តកម្មវិធីសាលាកុមារមេត្រីប្រកបដោយជោគជ័យ

គ្រូជាអ្នកពាក់ព័ន្ធយ៉ាងសំខាន់ នៅក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ជាតិ ដើម្បីកែលំអគុណភាពសាលារៀន នៅក្នុងប្រព័ន្ធអប់រំ។ គ្រូមានឥទ្ធិពលយ៉ាងច្រើនទៅលើកុមារដែលពួកគាត់បង្រៀន និងថ្នាក់រៀនដែលពួកគាត់គ្រប់គ្រង ។ មនុស្សភាគច្រើនមានការកត់សំគាល់យ៉ាងងាយចំពោះគ្រូល្អ និងគ្រូអន់ ។

គ្រូដើរតួជាគំរូដល់សិស្សនៅក្នុងថ្នាក់រៀនរបស់គាត់ ។ គ្រូអាចបង្ហាញនូវបុគ្គលិកលក្ខណៈល្អ ដែលគ្រួសារភាគច្រើនចង់ ឃើញកូនរបស់ខ្លួនយកតម្រាប់តាម ។ គុណភាពទាំងនេះរួមមាន ការខំប្រឹងប្រែងធ្វើការងារ មានចិត្តសប្បុរស មិនលំអៀង និងគោរពដល់អារម្មណ៏របស់អ្នកដទៃ ជាពិសេសសិទ្ធិរបស់កុមារ ។ គុណភាពទាំងនេះ គឺជាផ្នែកទាំងមូលរបស់បញ្ញត្តិនៃកម្មវិធីសាលាកុមារមេត្រី ។

គ្រូកុមារមេត្រីត្រូវតែស្គាល់កុមារគ្រប់រូបទាំងអស់នៅក្នុងថ្នាក់ខ្លួន ។ គ្រូត្រូវតែស្គាល់ឈ្មោះ ស្ថានភាពគ្រួសារ ចំណុចខ្លាំង ចំណុចខ្សោយ និងចំណង់ចំណូលចិត្តរបស់ពួកគេ ។ គ្រូកុមារមេត្រីត្រូវស្តាប់គំនិត និងមតិរបស់កុមារនៅក្នុងថ្នាក់របស់ខ្លួន ។ គ្រូកុមារមេត្រីត្រូវតែទទូចឱ្យកុមារនៅក្នុងថ្នាក់ស្តាប់គ្នាទៅវិញទៅមកផងដែរ ។ ប្រសិនបើគ្រូពិតជាគោរពតម្លៃនៃបទពិសោធន៏ និងទស្សនៈរបស់កុមារនោះ កុមារក៏នឹងធ្វើដូច្នោះដែរ ។

## ការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន ជាផ្នែកមួយនៃកម្មវិធីសាលាកុមារមេត្រី

ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវកម្មវិធីបំប៉នថ្នាក់ជាតិដល់បុគ្គលិកសិក្សាទាំងអស់ សម្រាប់ជាផ្នែកនៃការពង្រីកកម្មវិធីសាលាកុមារមេត្រី ។ ឯកសារប្រសិទ្ធភាពនៃការបង្រៀន និងរៀន គឺជាកិច្ចខំប្រឹងប្រែងចម្បងរបស់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីឱ្យបានទៅដល់គ្រូគ្រប់រូបទូទាំងប្រទេស ។

កម្មវិធីសាលាកុមារមេត្រីមានឬគ្មានផលប៉ះពាល់ដល់សាលារៀន អាស្រ័យទៅលើអ្វីដែលលោកគ្រូ អ្នកគ្រូបានធ្វើ ។ ឯកសារប្រសិទ្ធភាពនៃការបង្រៀន និងរៀនរួមបញ្ចូលទាំងឯកសារអភិវឌ្ឍវិជ្ជាជីវៈ ក្រសួងនឹងផ្តល់ជូនផ្ទាល់ដល់ដៃគ្រូ ។ ឯកសារទាំងនេះផ្តល់នូវព័ត៌មានអំពីគំនិតថ្មីៗនៅក្នុងការបង្រៀន និងរៀន និងឧទាហរណ៏សម្រាប់អនុវត្តជាក់ស្តែងអំពីរបៀបដែលគ្រូអាចប្រើគំនិតថ្មីៗទាំងនេះនៅក្នុងថ្នាក់រៀន ។

ក្រសួងអប់រំ យុវជន និងកីឡា នឹងផ្តល់ផងដែរនូវការគាំទ្រដល់គ្រូតាមសាលារៀនពេញមួយឆ្នាំសិក្សា តាមរយៈគ្រូឧទ្ទេសមកពីកម្រងសាលារៀន ឬការិយាល័យអប់រំ យុវជន និងកីឡាស្រុក/ខណ្ឌ ។

សៀវភៅកំណត់ត្រាគ្រូ គឺជាផ្នែកមួយរបស់ឯកសារប្រសិទ្ធភាពនៃការបង្រៀន និងរៀន ។ សៀវភៅកំណត់ត្រា នេះគឺសម្រាប់គ្រូកត់ត្រាកិច្ចការដែលបានធ្វើក្នុងឆ្នាំសិក្សា ។ គ្រូអាចយកសៀវភៅកំណត់ត្រារបស់ខ្លួនមកកាន់អង្គប្រជុំអភិវឌ្ឍវិជ្ជាជីវៈ ដែលប្រារព្ធធ្វើនៅកម្រងសាលារៀន ឬ នៅការិយាល័យអប់រំ យុវជន និងកីឡាស្រុក/ខណ្ឌ ។ គ្រូអាចចែករំលែកលទ្ធផលបទពិសោធការងាររបស់ខ្លួនជាមួយគ្រូដទៃទៀតបាន និង ជួយដល់គ្នាទៅវិញទៅមក ដើម្បីបំពេញឱ្យបានចប់សព្វគ្រប់នៅក្នុងកម្មវិធីអភិវឌ្ឍវិជ្ជាជីវៈ ។

នៅដំណាច់ឆ្នាំសិក្សា គ្រូគួរជូនសៀវភៅកំណត់ត្រាគ្រូទៅលោកនាយក/នាយិកាដើម្បីពិនិត្យមើល ។ គ្រូដែលបានអនុវត្តនូវរាល់កិច្ចការទាំងអស់នៅក្នុងថ្នាក់រៀនរបស់ខ្លួន ហើយបានកត់ត្រាលទ្ធផលនានា គ្រូនោះនឹងទទួលបានការលើកទឹកចិត្តពីក្រសួងអប់រំ យុវជន និងកីឡា ដើម្បីលើកទឹកចិត្តដល់ការចូលរួមយ៉ាងសកម្មរបស់គាត់នៅក្នុងកម្មវិធីប្រសិទ្ធភាពនៃការបង្រៀន និងរៀន ។

**កំណត់សំគាល់ :** បច្ចេកទេសនៃការប្រើប័ណ្ណ VIPP នៅក្នុង ២ផ្នែកដូចតទៅ :

- VIPP មានន័យថាការធ្វើ និងឃើញជាក់ស្តែងក្នុងការចូលរួមផែនការ ។ នេះគឺជាវិធីនៃការសម្របួលផ្តុំ និងរកឱ្យឃើញនូវគំនិតសិក្ខាកាមបានច្បាស់លាស់នៅក្នុងវគ្គបំប៉ន ។ ប័ណ្ណ VIPP គឺជាផ្នែកមួយនៃព្យុះគំនិតដែលសិក្ខាកាមមិនទាន់ចាប់ផ្តើមពិភាក្សា ប៉ុន្តែសរសេរគំនិតរបស់គេនៅលើប័ណ្ណ ដែលមានពណ៌ផ្សេងគ្នា ។
- ជំហានសំខាន់បន្ទាប់មក VIPP មានលំនាំដូចជា :

  ១.សិក្ខាកាមស្តាប់សំណួរ និងសរសេរគំនិតគេលើប័ណ្ណដោយមិននិយាយ ឬ សួរគ្នាទេ ។

  ២.ក្រោយមកមានការឯកភាពលើពេលវេលា សិក្ខាកាមឈប់សរសេរលើប័ណ្ណហើយបង្ហាញប័ណ្ណទាំងនោះ ។

  ៣.អ្នកសម្របសម្រួលម្នាក់ជួយសិក្ខាកាមឱ្យពិភាក្សា និងសម្រេចអំពីអ្វីដែលគេបានធ្វើចំណែកថ្នាក់នៃប័ណ្ណនោះទៅតាមក្រុម ។

  ៤.សិក្ខាកាមឯកភាពលើឈ្មោះក្រុមដែលបានបិទលើប័ណ្ណ VIPP ទាំងនោះ ។
- ជាដំបូង សិក្ខាកាមសរសេរគំនិតរបស់គេលើប័ណ្ណពណ៌ស ។ បន្ទាប់មកគេធ្វើចំណែកថ្នាក់ប័ណ្ណពណ៌ស និងសរសេរឈ្មោះក្រុមលើប័ណ្ណពណ៌ផ្សេងៗទៀត ។ មានច្បាប់ ៣ សំខាន់ៗក្នុងការសរសេរប័ណ្ណ VIPP :

  ១.សរសេរគំនិតតែមួយក្នុងប័ណ្ណមួយ

  ២.សរសេរអក្សរឱ្យបានធំៗលើប័ណ្ណ

  ៣.សរសេរលើប័ណ្ណទាំងនោះច្រើនបំផុត៣ បន្ទាត់